# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ




# របាយការណ៍បូកសរុបលទ្ធផល
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២២
# និងទិសដៅអនុវត្ត ឆ្នាំ ២០២៣

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ



# សារលិខិតថ្លែងអំណរគុណ

ក្នុងនាមអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងសហការី សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំកម្ពុជាឲ្យបានដល់ត្រើយសន្តិភាព និងការអភិវឌ្ឍន៍គ្រប់វិស័យ ហើយតែងគាំទ្រ ជម្រុញ និងផ្តល់នូវការលើកទឹកចិត្តដល់គណៈកម្មាធិការជាតិ ប្រឆាំងការជួញដូរមនុស្ស ឲ្យមានលទ្ធភាពផ្តួចផ្តើមនូវគំនិត និងសកម្មភាពថ្មីៗ ដើម្បី ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព និងផ្តល់នូវក្តីសុខក្សេមក្សាន្តជូនប្រជាពលរដ្ឋ ជាក់ស្តែង ព្រះរាជាណាចក្រកម្ពុជា មានទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ និងទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ២០សីហា ជាដើម។

សូមគោរពដឹងគុណ **សម្តេចក្រឡាហោម ស ខេង** ដែលបានដឹកនាំ ណែនាំ ចង្អុលទិសការងារដោយផ្ទាល់ ព្រមទាំងផ្តល់នូវការគាំទ្រ លើកទឹកចិត្ត បង្កលក្ខណៈសម្បត្តិគ្រប់បែបយ៉ាង ឲ្យអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និយាយដោយឡែក និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានក្រសួងទាំង ២២ ជាសមាជិក ស្ថាប័ន មន្ទីរ អង្គភាព អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងដៃគូទាំងអស់ បានសហការគ្នាបំពេញភារកិច្ចយ៉ាងសកម្ម និងឆ្លើយតបបានទៅនឹងគោលការណ៍ ផែនការដែលបានគ្រោងទុក ដោយជោគជ័យ។

សូមថ្លែងអំណរគុណ ចំពោះឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារទាំង០៦ និងជារដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួងស្ថាប័នជាសមាជិក គ.ជ.ប.ជ ដែលបានចូលរួមដឹកនាំ និងផ្តល់ឱកាសឲ្យមន្ត្រីជំនាញពាក់ព័ន្ធ បានចូលរួមសហការបានយ៉ាងល្អប្រសើរជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកន្លងមក ។

សូមថ្លែងអំណរគុណ និងកោតសរសើរ ដល់ ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាល និងជាប្រធានគណៈកម្មាធិការប្រឆាំងការជួញដូរមនុស្ស រាជធានី ខេត្ត រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរអង្គភាព កងកម្លាំងគ្រប់ប្រភេទ អង្គការដៃគូ ជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ដែលបានរួមសហការគ្នាយ៉ាងល្អឆ្ពោះទៅគោលដៅរួមតែមួយ គឺ «លុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់» ពីព្រះរាជាណាចក្រកម្ពុជា និងរួមចំណែកធ្វើឲ្យពិភពលោក មានសុវត្ថិភាព គ្មានអំពើជួញដូរមនុស្ស ។

**អនុប្រធានអចិន្ត្រៃយ៍**

# អារម្ភកថា



ព្រះរាជាគណៈសង្ឃ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីគោរពសក្ការៈ

សម្តេច ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន

ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ទាំងកងកម្លាំង
ប្រដាប់អាវុធគ្រប់ប្រភេទ ទាំងមន្ត្រីរដ្ឋបាលស៊ីវិល គ្រប់ផ្នែក គ្រប់វិស័យ
ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងតាមខ្សែបន្ទាត់ព្រំដែន

លោក លោកស្រី ប្រធាន និងបុគ្គលិក អ្នកស្ម័គ្រចិត្ត ក្នុងអង្គការអន្តរជាតិ
អង្គការសង្គមស៊ីវិល ទូទាំងប្រទេស ដែលបាន និងកំពុងចូលរួមយ៉ាងសកម្ម
ក្នុងការងារប្រឆាំងការជួញដូរមនុស្ស

បងប្អូន ជនរួមជាតិ ជាទីស្រឡាញ់រាប់អាន

ឆ្នាំ២០២២ បានកន្លងផុតទៅហើយ យើងទាំងអស់គ្នា ក៏បានបំពេញភារកិច្ចតាមតួនាទីរៀងៗខ្លួន នៅក្នុងបរិយាកាសមួយ ដែលពិភពលោក កើតមាននូវហេតុការណ៍ប្លែកៗជាច្រើន គួរឲ្យកត់សម្គាល់។ បន្តពីការរាតត្បាតនៃជម្ងឺកូវីដ ១៩ ក៏កើតមានព្រឹត្តិការណ៍ធំៗដទៃទៀត ដែលប៉ះពាល់ដល់ដល់សន្តិសុខ សុវត្ថិភាពរបស់មនុស្ស រួមមាន ការអូសបន្លាយនៃវិបត្តិសេដ្ឋកិច្ចពិភពលោក ផលប៉ះពាល់នៃបម្រែបម្រួល អាកាសធាតុ សង្គ្រាមស៊ីវិល សង្គ្រាមឈ្លានពានដែលប្រដាប់ដោយអាវុធទំនើប និងសាហាវឃោឃៅ គម្រាមកំហែងដល់សន្តិសុខពិភពលោក ជាដើម។ ទន្ទឹមនឹងនោះ ក៏មានការធ្លាក់ចុះនៃសីលធម៌សង្គម ការកើនឡើងនូវទស្សនៈអាត្មានិយម ឈានដល់ការកេងប្រវ័ញ្ច ការជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម ជួញដូរនិងរំលោភបំពានផ្លូវភេទ អំពើហិង្សា ដែលត្រូវបានក្រុមឧក្រិដ្ឋជន និងមនុស្សមួយចំនួន ប្រព្រឹត្តដោយគ្មានខ្លាចញញើត។ រីឯ មធ្យោបាយទំនាក់ទំនង ដែលជាបច្ចេកវិទ្យាព័ត៌មានដ៏ទំនើប ត្រូវបានប្រើប្រាស់ទូទៅយ៉ាងពេញនិយម ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងមធ្យោបាយធ្វើដំណើរក៏កាន់តែជឿនលឿន ដែលបង្កលក្ខណៈឲ្យជនល្មើសកាន់តែងាយស្រួលក្នុងការបង្កើតល្បិចកលទាក់ទាញជនរងគ្រោះជាពិសេសក្នុងចំណោមពលរដ្ឋដែលមានហានិភ័យ ឲ្យហ៊ានសម្រេចចិត្តសាកល្បងដោយប្រថុយប្រថាន តាមការអូសទាញរបស់ជនល្មើស ទាំងមិនធ្លាប់បានស្គាល់គ្នាទាល់តែសោះក៏មាន។ ស្ថានភាពនេះកើតមានស្ទើរតែនៅគ្រប់ទីកន្លែង លើប្រជាពលរដ្ឋនៃបណ្តាប្រទេសក្នុងតំបន់ និងនៅលើពិភពលោក។ ជនបរទេសខ្លះ ក៏ត្រូវបានចាញ់ឧបាយកល មេខ្យល់ ឬឧក្រិដ្ឋជន ឲ្យមករងគ្រោះនៅបណ្តាប្រទេសដទៃទៀត រីឯពលរដ្ឋកម្ពុជាមួយចំនួន ក៏នៅតែបន្តប្រថុយប្រថានជាមួយភាពរងគ្រោះ តាមការអូសទាញរបស់មេខ្យល់ និងឧក្រិដ្ឋជន បើទោះបីជាដឹងហើយ ឮហើយអំពីបទពិសោធន៍ និងរឿងរ៉ាវជាច្រើនរបស់ជនរងគ្រោះមុនៗហើយក៏ដោយ ។

នេះជាកង្វល់ ដែលរាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់ ក្នុងការដោះស្រាយ ដោយបង្កើនការអប់រំផ្សព្វផ្សាយ រឹតបន្តឹងផ្នែកច្បាប់ និងពង្រីកកិច្ចសហការជាមួយបណ្តាដៃគូ និងប្រទេសពាក់ព័ន្ធ ដើម្បីរួមគ្នាទប់ស្កាត់សកម្មភាពដែលឆ្ពោះទៅកាន់ភាពរងគ្រោះទាំងនោះ។ ខ្ញុំក៏សូមអំពាវនាវ ឲ្យ

ប្រជាពលរដ្ឋយើងទាំងអស់ បង្កើនការយកចិត្តទុកដាក់ក្នុងការស្តាប់ការណែនាំរបស់មន្ត្រីជំនាញ ចូលរួមពិភាក្សាក្នុងវេទិកាសាធារណៈឲ្យបានច្រើន ដើម្បីបានស្តាប់មតិយោបល់ពីអ្នកដទៃ និងព្យាយាមស្វែងរកជម្រើស ក្នុងការរស់នៅដែលល្អប្រសើរ មិនប្រថុយប្រថាន មិនចាកចោល ឬបោះបង់គ្រួសារ ឬអ្នកនៅក្រោមអាណាព្យាបាល ដោយដើរផ្សងព្រេងមិនច្បាស់លាស់ ដែលនាំឲ្យប្រឈមនឹងគ្រោះថ្នាក់នោះឡើយ ។

ព្រះរាជាណាចក្រកម្ពុជាយើង គឺជាមាតុភូមិ ដែលផ្តល់ភាពសុខសាន្ត សប្បាយរីករាយដល់យើងទាំងអស់គ្នា នៅពេលដែលយើងចេះប្រើបញ្ញា ចេះជ្រើសរើសយកការរស់នៅប្រកបដោយសុចរឹតភាព ការតស៊ូព្យាយាម ការទទួលខុសត្រូវ ការគោរព ឲ្យតម្លៃគ្នា និងចេះជួយគ្នាទៅវិញទៅមក ។

សូមឆ្នាំថ្មី នាំមកនូវសុខ សិរី ជ័យមង្គល គ្រប់ប្រការ ជូនដល់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងក្រុមគ្រួសារ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ថ្ងៃសុក្រ ១១ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣

**ប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


I. ស្ថានភាពទូទៅ ..... ១

II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ..... ២

ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និង ការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ..... ២

១. ការកសាងច្បាប់ ..... ២

២. សន្ធិសញ្ញា ..... ២

៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់ ..... ២

៤. លិខិតបទដ្ឋានគតិយុត្ត ..... ៣

៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ..... ៤

ខ. ការបង្ការ ទប់ស្កាត់ ..... ៤

១. តាមរយៈការលើកកម្ពស់ការយល់ដឹង ..... ៤

១.១. ការផ្សព្វផ្សាយដោយផ្ទាល់ ..... ៤

១.១.១. វេទិកាអន្តរសាសនា ..... ៥

១.១.២. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ..... ៥

១.១.៣. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ ..... ៦

១.១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ ..... ៧

១.១.៥. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ ..... ៨

១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក ..... ១០

១.៣. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC) ..... ១១

២. ការបង្ការទប់ស្កាត់តាមវិធានការជំនាញ ..... ១២

២.១. ការផ្ដល់ព័ត៌មាន និងបង្កើតកម្មវិធីសិក្សា ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ..... ១២

២.២. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់ ..... ១៣

២.៣. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ ..... ១៣

២.៤. ការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក ..... ១៣

២.៤.១. ការគ្រប់គ្រងស្ថិតិពលករខ្មែរៈ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក ..... ១៣

២.៤.២. ការគ្រប់គ្រងស្ថិតិជនបរទេស បច្ចុប្បន្នភាពចំណូលស្រុក ..... ១៤

២.៥. វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ ..... ១៥

២.៦.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ............ ១៥

៣. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ............ ១៥

៤. ការលើកកម្ពស់ជីវភាព ............ ១៧

**គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស............ ១៧**

**១. ការខាអនុវត្តច្បាប់............ ១៧**

១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ............ ១៧

**២. កិច្ចការយុត្តិធម៌ ............ ១៩**

២.១. ចំណាត់ការផ្តន្ទាទោស............ ១៩

១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត............ ១៩

២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ............ ១៩

៣. ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត............ ២០

២.១.១. ករណីពពោះជំនួស ............ ២១

២.២. ដំណោះស្រាយនៃការវិវាទការងាររវាងពលករទៅធ្វើការនៅក្រៅប្រទេស និងក្រុមហ៊ុនជ្រើសរើសពលករ .. ២១

**ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ ............ ២១**

**១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន( ផ្លូវគោក និងផ្លូវអាកាស ) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ............ ២១**

១.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់ (ផ្លូវគោក និងផ្លូវអាកាស)............ ២១

**២. កិច្ចការពារជនរងគ្រោះ ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស............ ២៣**

២.១. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវា ............ ២៣

២.២. ការស្តារនីតិសម្បទាដល់ជនរងគ្រោះ............ ២៣

**៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនខាយរងគ្រោះ............ ២៣**

**III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល............ ២៤**

**ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា............ ២៤**

១. ការងារបណ្តុះបណ្តាល............ ២៤

២. សិក្ខាសាលា ............ ២៦

**ខ. កិច្ចប្រជុំ សន្និសីទ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ .................................... ២៧**

១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស........................................................................................ ២៧

១.១. កិច្ចប្រជុំក្នុងប្រទេស........................................................................................ ២៧

១.២. កិច្ចប្រជុំក្រៅប្រទេស ........................................................................................ ២៩

២. ជំនួបពិភាក្សាការងារ........................................................................................ ៣០

**គ. ការងារសម្របសម្រួល ........................................................................................ ៣២**

**IV. ការសន្និដ្ឋានវាយតម្លៃ ........................................................................................ ៣៣**

**ក. ចំណុចខ្លាំង ........................................................................................ ៣៣**

**ខ. ចំណុចខ្វះខាត ឬភាពប្រឈម ........................................................................................ ៣៤**

**គ. សន្និដ្ឋាន........................................................................................ ៣៤**

**V. ទិសដៅអនុវត្តបន្ត ឆ្នាំ២០២៣ ........................................................................................ ៣៤**

**ក. ការរៀបចំច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ................................ ៣៤**

**ខ. ការងារបង្ការ ទប់ស្កាត់........................................................................................ ៣៥**

**គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ........................................................ ៣៦**

**ឃ. ការងារការពារជនរងគ្រោះ ........................................................................................ ៣៧**

**ង. ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ.................................... ៣៨**

- កម្រងរូបភាព
- ឧបសម្ព័ន្ធ

# របាយការណ៍ ឆ្នាំ២០២២
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២៣

## ស្ថានភាពទូទៅ

សភាពការណ៍សាកលលោក មានការវិវត្តប្រែប្រួលថ្មីៗ ប្លែកៗ គួរឱ្យកត់សម្គាល់ និងមិនអាចប៉ាន់ស្មានបាន មានដូចជា គ្រោះធម្មជាតិ បម្រែបម្រួលអាកាសធាតុ (ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ ...) ដែលបាន និងកំពុងគំរាមកំហែងដល់ការរស់នៅរបស់មនុស្សសត្វលើផែនដី បន្ថែមពីលើសង្គ្រាមពុំរ៉ៃនៅបណ្តាប្រទេសមួយចំនួន រួមទាំងមានគ្រោះមហន្តរាយដោយការរាតត្បាតនៃវីរុសកូវីដ-១៩ និងមេរោគបំប្លែងថ្មីៗ។ វិបត្តិនៃផលប៉ះពាល់ដោយជំងឺកូវីដ-១៩ មិនទាន់បានបញ្ចប់ផង ក៏មានព្រឹត្តិការណ៍ដ៏អាក្រក់ជាច្រើនដែលកើតឡើងជាបន្តបន្ទាប់នៅក្នុងឆ្នាំ២០២២នេះ នោះ គឺការផ្ទុះសង្គ្រាមរវាងប្រទេសដែលនៅជិតខាងគ្នានៅក្នុងទ្វីបអឺរ៉ុប គឺសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន ដែលបានជះឥទ្ធិពលអវិជ្ជមានធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ច និងសង្គមជាសាកលជាកត្តាជំរុញឱ្យមានលំហូរទេសន្តរប្រវេសន៍។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយ បង្កើតនូវបទល្មើសថ្មីៗ ព្រមជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស។

រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ ផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមដ៏ធំធេង និងខិតខំការពារសន្តិសុខក្នុងប្រទេសនិងក្នុងតំបន់ ខិតខំរកដំណោះស្រាយបញ្ហាដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា ការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហការក្នុងតំបន់ ជាក់ស្តែង ជោគជ័យនៃការដោះស្រាយបញ្ហាតំបន់ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០២២នេះ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងការដោះស្រាយភាពប្រឈមដែលជះឥទ្ធិពលអវិជ្ជមានដល់ជីវភាពប្រជាពលរដ្ឋ និងបង្កភាពរាំងស្ទះដល់ការអនុវត្តសកម្មភាពអភិវឌ្ឍគ្រប់វិស័យ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការនៅគ្រប់កម្រិត បានរៀបចំយុទ្ធសាស្ត្រ និងដាក់ចេញនូវវិធានការចម្បងៗជាច្រើន រាប់ទាំងការកសាងច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តទាំងឡាយ ដើម្បីការពារប្រជាពលរដ្ឋពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនានា។ ក្នុងស្ថានភាពដ៏អាក្រក់នៃភាពប្រឈមនឹងការស្វែងរកការងារនៅក្រៅប្រទេសដោយប្រថុយប្រថាន ក្នុងឋានៈជាពលករមិនស្របច្បាប់ រាជរដ្ឋាភិបាលកម្ពុជា តែងតែស្វះស្វែងរកដំណោះស្រាយជាមួយប្រទេសពាក់ព័ន្ធដើម្បីកាត់បន្ថយភាពរងគ្រោះ និងលើកកម្ពស់សុវត្ថិភាពពលករចំណាកស្រុក ព្រមទាំងដោះស្រាយភាពប្រឈមរបស់ពលករវិលត្រឡប់រាប់សិបម៉ឺននាក់ និងប្រជាពលរដ្ឋក្នុងស្រុកដែលប្រឈមនឹងវិបត្តិកូវីដ-១៩ តាមរយៈការដាក់ចេញនូវគោលនយោបាយសន្តិសុខសង្គមយ៉ាងទូលំទូលាយ ដើម្បីបង្ការទប់ស្កាត់ភាពទ័លច្រក និងប្រថុយប្រថានរបស់ប្រជាពលរដ្ឋ ដែលជឿលើការអូសទាញរបស់មេខ្យល់ ឬឧក្រិដ្ឋជនឱ្យធ្លាក់ក្នុងភាពរងគ្រោះ។

ថ្មីៗនេះ មិនត្រឹមតែប្រជាជនកម្ពុជាទេ តែប្រជាជននៃប្រទេសដទៃក្នុងតំបន់ រហូតដល់ពីបណ្តាប្រទេសធំៗក្នុងពិភពលោក ក៏បានធ្លាក់ក្នុងភាពរងគ្រោះដោយកលល្បិចឧក្រិដ្ឋជន។ បញ្ហាជួញដូរមនុស្ស បានក្លាយជាវិបត្តិសាកល ដែលស្ទើរតែគ្រប់ប្រទេសក្នុងសាកលលោកកំពុងប្រឈម ដោះស្រាយ និងកាន់តែស្មុគស្មាញខ្លាំងឡើង។

ប្រជាជនយើងមួយចំនួន នៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស នាំឱ្យខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរថែមទៀត។

ក្នុងឆ្នាំ២០២២ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ជាសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងមានការចូលរួមគាំទ្រសហការដោយអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានបន្តធ្វើសកម្មភាពប្រតិបត្តិការ តាមយុទ្ធសាស្ត្រដែលបានកំណត់។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌៖** បានបន្តពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស» និងច្បាប់ស្តីពី «អំពើពពោះជំនួស»។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ ស្តីពី« ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

#### ២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌៖**

**ក-សន្ធិសញ្ញាស្តីពី "ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ"** បាននិងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី "**ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ**" ចំនួន៣គឺ៖

- រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋឥណ្ឌា។
- រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋបេឡារុស។
- រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋតួកគី។

**ខ.សន្ធិសញ្ញាស្តីពីបត្យាប័ន៖** បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "**បត្យាប័ន**" រវាងព្រះរាជាណាចក្រកម្ពុជាជាមួយ សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។

**គ.សន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត៖** បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "**ការផ្ទេរទណ្ឌិត**" រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនិង សាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្របែលហ្ស៊ិក។

#### ៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**

១-បានចុះអនុស្សរណៈនៃការយោគយល់ជាមួយអង្គការដៃគូ ចំនួន ០៤ ដូចជា៖

-អង្គការការីតាសស្វីស (Caritas Swiss) ស្តីពី«ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក ឆ្នាំ២០២២-២០២៤»។ (ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២)។

-អង្គការអេរិក (Erikshjalpen) ស្តីពី«សកម្មភាពបង្ការ ទប់ស្កាត់ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ»។ (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២)។

-អង្គការវីនរ៉ក់អន្តរជាតិ (Winrock International) ស្តីពី«ការរួមចំណែកលើកកម្ពស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពវិធានការប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា»។ (ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២)។

-អង្គការដែនដីមនុស្សហូឡង់ដ៏ (Terre des Hommes) ប្រចាំកម្ពុជា ស្តីពី«ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារគ្រប់ទម្រង់»។ (ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២)។

២-បានចុះហត្ថលេខាលើស្តង់ដានីតិវិធីប្រតិបត្តិ (SOP) ស្តីពីកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបន្តរៀបចំផែនការសកម្មភាពនៃ SOP ។

## ៤. លិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានរៀបចំកិច្ចប្រជុំ៖
  - ក្រុមការងារបច្ចេកទេសមន្ត្រីជាន់ខ្ពស់ ដើម្បីពិនិត្យលើសេចក្តីព្រាងអនុស្សរណៈយោគយល់រវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ី ស្តីពី«ការជ្រើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករទូទៅ» និង«ការជ្រើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករការងារផ្ទះ» នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២។
  - បានរៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងប្រកាស ស្តីពីលក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មអំពៅចំនួន៣លើក នៅថ្ងៃទី៧-១៩ ខែកុម្ភៈ ឆ្នាំ២០២២ និងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**
  - ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។
  - បានរៀបចំកិច្ចប្រជុំចុះហត្ថលេខាលើកិច្ចព្រមព្រៀង គម្រោងអភិវឌ្ឍន៍សមត្ថភាពដើម្បីជួយអ្នករស់រានមានជីវិតពីការជួញដូរមនុស្សក្នុងប្រទេសកម្ពុជា រវាងនាយកដ្ឋានគាំពារជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទីភ្នាក់ងារ សហប្រតិបត្តិការ អន្តរជាតិ ជប៉ុន(JICA) ប្រចាំកម្ពុជា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២។
- **ក្រសួងកិច្ចការនារី** បានរៀបចំសេចក្តីព្រាង៖
  - វិសោធនកម្មអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ(COMMIT)។
  - យន្តការបញ្ជូនឆ្លងដែនមានលក្ខណៈស្តង់ដាររួមគ្នាតែមួយ និងរួមទាំងចាត់តាំងគ្រូបង្គោល របស់ប្រទេសជាសមាជិកខមមីត(COMMIT)នីមួយៗ។
  - អនុស្សរណៈនៃការយោគយល់ រវាងក្រសួងកិច្ចការនារី និងអង្គការសម្ព័ន្ធចាប់ដៃ ក្នុងគោលបំណងពង្រឹង៖ ១-ការប្រឹក្សាយោបល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទនៅតាមសហគមន៍។ ២-កិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូក្នុង និងក្រៅប្រទេស ក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ។ ៣-ការផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ជាពិសេសស្ត្រី និងកុមារ។
- **ក្រសួងអប់រំ យុវជន និងកីឡា៖** បានរៀបចំពិធីប្រកាសឱ្យអនុវត្តផ្លូវការនូវសៀវភៅណែនាំប្រតិបត្តិ ស្តីពីកិច្ចគាំពារកុមារនៅក្នុងសាលារៀន។
- **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍៖** កំពុងត្រៀមរៀបចំបង្កើតសេចក្តីណែនាំដល់ប្រតិបត្តិករទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឱ្យបន្តចូលរួមក្នុងសកម្មភាពទប់ស្កាត់ និងការពារកុមារលើប្រព័ន្ធអនឡាញ ព្រមទាំងទប់ស្កាត់ហានិភ័យការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។

### ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

- **គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានរៀបចំកិច្ចប្រជុំ៖
  - ជាមួយសមាជិកគណៈកម្មាធិការ និងមន្ត្រីជំនាញពីបណ្តាក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងអង្គការដៃគូជាតិ និងអន្តរជាតិ ស្តីពី «ការពិនិត្យឡើងវិញនូវលទ្ធផលការងារ និងភាពប្រឈម» (២០១៩-២០២១) និងគំនិតផ្តួចផ្តើមសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្របន្ត(២០២២-២០២៣) តាមប្រព័ន្ធអនឡាញ។
  - ជាច្រើនលើក តាមប្រព័ន្ធអនឡាញ ជាមួយអង្គការសហប្រជាជាតិទទួលបន្ទុកការងារទេសន្តរប្រវេសន៍ នៅទីក្រុងហ្សឺណែវ បណ្តាញអង្គការទេសន្តរប្រវេសន៍របស់អង្គការសហប្រជាជាតិប្រចាំតំបន់ អគ្គលេខាធិការដ្ឋានអាស៊ាន និងជាមួយអន្តរក្រសួង ស្ថាប័ន ក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនាមជាប្រទេសជ័យលាភី (Champion Country) ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន៖**
  - បំពេញបេសកកម្មនៅប្រទេសថៃ ចាប់ពីថ្ងៃទី ០១-១១ ខែមីនា ឆ្នាំ២០២២ ដើម្បីដំឡើងសម្ភារ និងប្រព័ន្ធតភ្ជាប់ជូនស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ សម្រាប់មន្ត្រីស្ថានទូតប្រើប្រាស់ដាក់ឱ្យដំណើរការនូវប្រព័ន្ធបន្តសុពលភាពប័ណ្ណ OCWC និងលិខិតធ្វើដំណើរ TD។
  - ដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារស្នូលកម្ពុជានៃក្រុមការងារមហាអនុតំបន់មេគង្គ ស្តីពីទេសន្តរប្រវេសន៍ការងារ (GMS Task Force on Labour Migration) ជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដើម្បីត្រៀមរៀបចំវេទិកា ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់បណ្តាប្រទេសក្នុងតំបន់ GMS។
  - បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់មន្ត្រីជាន់ខ្ពស់ ស្តីពីការពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ី ស្តីពី"ការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករទូទៅ និងពលករការងារផ្ទះ"។
- **ក្រសួងកិច្ចការនារី៖** បានសហការជាមួយអង្គការ UN Women រៀបចំកិច្ចប្រជុំជាមួយក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារខេមមីតកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្នុងគោលបំណង: **១**-ពិនិត្យលើវឌ្ឍភាព ទម្រង់ថ្មីៗ និងបញ្ហាប្រឈមនៃអំពើជួញដូរមនុស្សនៅកម្ពុជា។ **២**-ការស្វែងយល់ពីអនុសញ្ញា CEDAW ទៅនឹងគោលនយោបាយជាតិ ដែលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីពលករទេសន្តរប្រវេសន៍។ **៣**-ប្រមូលធាតុចូលដើម្បីរៀបចំផែនការ របស់ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារខេមមីតកម្ពុជា ឆ្នាំ២០២២-២០២៣។

## ខ. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១. ការផ្សព្វផ្សាយដោយផ្ទាល់

សរុបការផ្សព្វផ្សាយដោយផ្ទាល់ក្នុងឆ្នាំ២០២២ តាមរយៈ វេទិកាអន្តរសាសនាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**" និងតាមកម្មវិធីផ្សេងៗ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មាន ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ រាជធានី-ខេត្ត បានសហការជាមួយអង្គការដៃគូ សរុបចំនួន **២១៦.៨៣០លើក** មានអ្នកចូលរួមសរុបចំនួន **៦.៤៤១.៨៧៣នាក់** ស្ត្រីចំនួន **៣.១៤២.៣២៩នាក់** (ធៀបនឹងឆ្នាំ២០២១ មានចំនួន **៦.៦៣៣.២៦៧នាក់**) គឺមានការថយចុះចំនួន **១៩១.៣៩៤នាក់** ស្មើនឹង **២,៨៨%** ដូចមានតារាងលម្អិតខាងក្រោម៖

តារាងទិន្នន័យការអប់រំផ្សព្វផ្សាយដោយផ្ទាល់

| ការផ្សព្វផ្សាយដោយផ្ទាល់ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| វេទិកាអន្តរសាសនា | ០៣ | ១.៧៨៣ | ៦១៦ |
| ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ០៩ | ៧.៦១៩ | ៣.០០៤ |
| កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ | ២១៥.០២១ | ៦.០០៧.១៦៩ | ៣.០០០.៤០៨ |
| តាមរយៈកម្មវិធីផ្សេងៗ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ | ១.៣៣៩ | ៣៨៦.៧៨៣ | ១១៨.៥៤៣ |
| អង្គការដៃគូ | ៤៩៨ | ៣៨.៥១៩ | ១៩.៧៥៨ |
| **សរុប** | **២១៦.៨៧០លើក** | **៦.៤៤១.៨៧៣នាក់** | **៣.១៤២.៣២៩នាក់** |

### ១.១.១. វេទិកាអន្តរសាសនា

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ** បានសហការជាមួយអង្គការការីតាសកម្ពុជា ក្រសួងធម្មការនិងសាសនា និងមេដឹកនាំនិកាយសាសនាធំៗ ក្នុងព្រះរាជាណាចក្រកម្ពុជាមាន សាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រឹស្ត រៀបចំកម្មវិធីវេទិកាជាតិអន្តរសាសនានៅកម្ពុជា «សូមកុំយកកម្ពុជាធ្វើជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានអ្នកចូលរួមប្រមាណ **១.៥០០**អង្គ/នាក់ (ស្រី **៥៨៧**នាក់)។ ដើម្បីឱ្យមេដឹកនាំសាសនានីមួយៗ បានបន្តផ្សព្វផ្សាយទៅសាសនិករបស់ខ្លួន តាមរយៈកម្មវិធីសាសនា ការចុះអប់រំយុវវ័យ តាមសហគមន៍ និងតាមសាលារៀន និងកម្មវិធីផ្សព្វផ្សាយអប់រំផ្លូវចិត្ត តាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ(កម្មវិធីពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម.....)។

▪ **គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប** បានសហការជាមួយមន្ទីរធម្មការនិងសាសនាខេត្ត មានសាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រឹស្ត និងសាសនាផ្សេងៗទៀត បានរៀបចំពិធីប្រជុំផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា មានអ្នកចូលរួមប្រមាណ **៥២**អង្គ/នាក់(ស្រី ០៨នាក់)។

▪ **គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តស្វាយរៀង** សហការជាមួយអង្គការដៃគូ បានរៀបចំវេទិកាផ្សព្វផ្សាយ អន្តរសាសនាស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រោមប្រធានបទ ៉ រួមគ្នាបញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើគ្រប់រូបភាព ៉ដោយមានការនិមន្តអញ្ជើញចូលរួម ពីព្រះមន្ត្រីសង្ឃព្រះអនុគណ ព្រះគ្រូចៅអធិការវត្ត លោកគ្រូអាចារ្យវត្ត បូជាចារ្យ គ្រូគង្វាល ថ្នាក់ដឹកនាំនៃគ្រឹស្តសាសនា សាសនាមហាយាន ឥស្លាម សាសនា និងបាហៃសាសនា លោក លោកស្រីអភិបាលរងក្រុង ស្រុកទាំង០៨ មន្ទីរពាក់ព័ន្ធនៃក្រុមការងារទាំង ០៦ កងកម្លាំងទាំង ៣ប្រភេទ សរុបប្រមាណ **២៣១**អង្គ/នាក់ (ស្រី **២១**នាក់)

### ១.១.២. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូជាតិនិងអន្តរជាតិ ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ក្រោមប្រធានបទស្តីពី **«រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព»** និងបានផលិតសម្ភារផ្សព្វផ្សាយអប់រំ បទយកការណ៍ស្តីពីអំពើជួញដូរមនុស្ស បទចម្រៀង ការសម្តែងសិល្បៈចម្រុះរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីបញ្ជ្រាបការយល់ដឹងដល់អង្គពិធីទាំងមូល ដែលមានការចូលរួមពីថ្នាក់ដឹកនាំសំខាន់ៗ ក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ អង្គទូតនានាប្រចាំកម្ពុជា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា និយោជិត និយោជក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋសរុបចំនួន **៣.៥០០**អង្គ/នាក់ (ស្រី **១.២៨០**នាក់) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

▪ **លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ និងមន្ទីរអប់រំ យុវជន និងកីឡា** ទាំង ០៩ខេត្ត រួមមានខេត្តស្វាយរៀង កណ្តាល ត្បូងឃ្មុំ កំពង់ចាម កែប កំពង់ធំ សៀមរាប កោះកុង និងខេត្តឧត្តរមានជ័យ បានសហការជាមួយអង្គភាពពាក់ព័ន្ធ អង្គការដៃគូ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ លើកទី១៦ និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន ០៩លើក អ្នកចូលរួមចំនួន ៤.៦១៩នាក់ (ស្រី ១.៧២៤នាក់)។

### ១.១.៣. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

ឆ្នាំ២០២២នេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**" ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **២១៥.០២១**លើក មានអ្នកចូលរួមសរុបចំនួន **៦.០០៧.១៦៩**នាក់ ស្ត្រីចំនួន **៣.០០០.៤០៨**នាក់ (ធៀបនឹងឆ្នាំ២០២១ មានចំនួន **៥.៥៤១.៥៨៤**នាក់ គឺមានការកើនឡើងចំនួន ចំនួន **៤៦៥.៥៨៥**នាក់ ស្មើនឹង ៨,៤០%) ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងវេទិកាផ្សព្វផ្សាយជាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ប្រជុំផ្សព្វផ្សាយ ភូមិ-ឃុំមានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ | ៤ | ១.១០៣ | ១៦២ | | | |
| ២ | ក្រសួងកិច្ចការនារី | ០១ | ១០៧ | ៧២ | ០១ | ១០៧ | ៧២ |
| ៣ | កាកបាទក្រហមកម្ពុជា | ២៩ | ២០.៤៨៧ | | | | |
| ៤ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤៦២ | ៤១.៦៨៣ | ២២.៩៩០ | ១.៩២៩ | ៨៦.២០៨ | ៤៤.៩៤៣ |
| | **សរុប ក្រសួង ស្ថាប័ន** | ៤៩៦ | ៦៣.៣៨០ | ២៣.២២៤ | ១.៩៣០ | ៨៦.៣១៥ | ៤៥.០១៥ |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | ០៩ | ៨២៨ | ៣៦៤ | ២ | ២៤០ | ១២២ |
| ២ | ខេត្តកណ្តាល | ៨៩.៣៤៣ | ៦២៨.៧១៧ | ៣២៣.៣២៤ | ១៣.៧៧៧ | ៩០៧.៣៤៣ | ៤១០.៦៧៩ |
| ៣ | ខេត្តបាត់ដំបង | ១០.៦០៧ | ៤២៨.១២២ | ១៣០.៧០៣ | ៧.៤៩៨ | ២៣៣.០៩៧ | ១២៦.១៥៤ |
| ៤ | ខេត្តពោធិ៍សាត់ | ៦.១៥៩ | ៥០១.៧០៧ | ២៧៦.០៤០ | ១.៦៣៦ | ៥៨.៦៣៨ | ២៧.០៦២ |
| ៥ | ខេត្តសៀមរាប | ៤.៥០៤ | ១៣៥.១៣៧ | ៧៩.៩១៣ | ២០៧ | ៧.៤៧៣ | ៤.១៩៣ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១៣.២៧៥ | ៣០៤.៥៤២ | ១៧៩.៧៥៨ | ៦.៩៨០ | ១២៦.១១០ | ៦៦.២៩៣ |
| ៧ | ខេត្តកំពង់ចាម | ២២.៣៤៥ | ១.២១៧.៩៧៧ | ៦៣៧.៣៦៧ | ១០.៨៩៨ | ៣៤៥.២២៦ | ១៨១.១៨១ |
| ៨ | ខេត្តព្រះសីហនុ | ១២៥ | ២៣.២០៤ | ១១.៧២៩ | ៥០ | ៤.៣៨៥ | ១.៨៣៦ |
| ៩ | ខេត្តព្រះវិហារ | ១០៩ | ១១.២៦៨ | ៦.១២៦ | ៩៥ | ១.៦៩៦ | ២៩០ |
| ១០ | ខេត្តស្វាយរៀង | ៣.៧២៣ | ១៦៩.៨៤៣ | ៩៣.០៤៣ | ១.១៥២ | ៤១.០២៨ | ២៣.៦១៦ |
| ១១ | ខេត្តប៉ៃលិន | ៩៧១ | ១៨.៥៩៧ | ៥.២២៣ | ៤៨៣ | ១៩.០២៤ | ៥.៩៨៩ |
| ១២ | ខេត្តកោះកុង | ៥៣ | ១.៨១៧ | ៥៣១ | ៥៥១ | ១២.៤៩០ | ៦.៦៤៦ |
| ១៣ | ខេត្តកំពត | ៩៤ | ៣.៣១៣ | ១.៨៥២ | ៣០ | ១.០៦៩ | ៦៧៣ |
| ១៤ | ខេត្តកំពង់ធំ | ៥៥៦ | ២៥.៨១១ | ២១.៧៤៨ | ៣៧៤ | ២៦.១៩២ | ១២.៤៧៦ |
| ១៥ | ខេត្តតាកែវ | ៣.១៦៧ | ១១០.២៩៧ | ៥៥.០៧៨ | ១.០៩៥ | ៣៥.៦២១ | ១៧.៨៥១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៦ | ខេត្តក្រចេះ | ២១៤ | ១០.៨៥៩ | ៥.៥៣៨ | ១១៨ | ៣.៣១០ | ២.១២២ |
| ១៧ | ខេត្តកែប | ៣២១ | ៥០.៥៦៦ | ២១.០៨២ | ៤៨៧ | ២០.៣១៣ | ៨.៩៥០ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៥៩០ | ២៧.៧៧២ | ១៤.៥១៦ | ៨១ | ១០.១១២ | ១.០៤៤ |
| ១៩ | ខេត្តស្ទឹងត្រែង | ៤៥ | ៣២៦ | ២៤៤ | ៥ | ១៣៣ | ៩៩ |
| ២០ | ខេត្តរតនគិរី | ២.៨៩៤ | ៩៩.៧៩៣ | ៤៩.៣១០ | ១៩៤ | ១២.១១៤ | ៥.៣៩២ |
| ២១ | ខេត្តព្រៃវែង | ៦៥០ | ៤៥.៣២៦ | ២៧.៤១១ | ៣១៦ | ១៨.០៧៩ | ៨.៨២៦ |
| ២២ | ខេត្តត្បូងឃ្មុំ | ៤.៣៦៩ | ៥២.០៤០ | ២០.១៨០ | ៧៤៣ | ៥៤.៧២០ | ៣៥.២២៤ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៤៨៨ | ១០.៩៩៧ | ៩.៣២៦ | ១៥៦ | ៣.៤៨៣ | ១.៩៤៩ |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣៥ | ១១.៨៨៣ | ១.៥៧៣ | ១២ | ២.៥២៦ | ១.៩២៥ |
| ២៥ | ខេត្តមណ្ឌលគិរី | ១.០០៩ | ២២.៣១០ | ៩.៥៩៨ | | | |
| **សរុប រាជធានី-ខេត្ត** | | ១៦៥.៦៥៥ | ៣.៩១៣.០៥២ | ១.៩៨១.៥៧៧ | ៤៦.៩៤០ | ១.៩៤៤.៤២២ | ៩៥០.៥៩២ |
| **សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត** | | **ចំនួន ២១៥.០២១ លើក** | | **ចំនួនមនុស្ស ៦.០០៧.១៦៩ នាក់** | | **ចំនួនស្ត្រី ៣.០០.៤០៨ នាក់** | |

### ១.១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធធ្វើការផ្សព្វផ្សាយ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការប្រារព្ធពិធី និងរៀបចំ៖ **១**-ពិធីបុណ្យបញ្ចុះខណ្ឌសីមា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធាន គ.ជ.ប.ជ**។ **២**-ប្រារព្ធពិធីអបអរខួបលើកទី៧៣ ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី២១ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ។ **៣**-បើកយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។ **៤**-ទិវាវប្បធម៌ជាតិ ក្នុងមហោស្រពសិល្បៈយុវជនទូទាំងប្រទេស។ **៥**-យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិតក្រោមប្រធានបទ "រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារតាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ"។ **៦**-កម្មវិធីអបអរសាទរខួបលើកទី១១១ ទិវាអន្តរជាតិនារី ៨មីនា។ **៧**-ការចុះធ្វើបណ្ណាល័យចល័ត ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ **៨**-ការបោះជំរំរបស់យុវជនថ្នាក់ក្រុង/ស្រុក/ខេត្ត។ **៩**-ការរៀបចំបើកបវេសនកាលឆ្នាំសិក្សាថ្មី។ **១០**-ការចុះត្រួតពិនិត្យ និងចុះសួរសុខទុក្ខ នៅតាមគ្រឹះស្ថានសិក្សាវិទ្យាល័យ អនុវិទ្យាល័យ រោងចក្រ សហគ្រាស និងនៅមណ្ឌលទទួលពលករ។ **១១**-ចុះផ្សព្វផ្សាយ ស្តីពីការកំណត់បែបបទ និងនីតិវិធីរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ ជាមួយជនបរទេស។ **១២**-រៀបចំពិធីបើកយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម។ **១៣**-ការចុះត្រួតពិនិត្យ និងណែនាំដល់ម្ចាស់អាជីវកម្ម សេវាកម្មទេសចរណ៍។ **១៤**-ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្នុងកម្មវិធីបុណ្យអុំទូក អកអំបុកសំពះព្រះខែ។ **១៥**-រៀបចំព្យុហយាត្រា «ឆ្ពោះទៅមុខដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស» សរុបចំនួន **១.៨៣៩**លើក មានអ្នកចូលរួមចំនួន **៤២៨.៦៧៦**នាក់ ក្នុងនោះមានស្ត្រី **១៤០.៤២១**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាពការចូលរួម របស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ | ០១ | ៣៥០ | ៨២ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១១ | ១.៤២៧ | ៥៤៨ |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ០៩ | ៧.០៤១ | ៤.០១៧ |
| ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន(គ.ជ.ប.ជ) សហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា. អង្គការ៖ Aple Cambodia, Plan International Cambodia, UNICEF និងក្រុមហ៊ុន Smart Axiata | ០២ | ៦០០ | ២៧០ |

| | | | |
|---|---|---|---|
| ខេត្តបន្ទាយមានជ័យ | ១២ | ៨៩.៥៩០ | ៣.៩១៧ |
| ខេត្តបាត់ដំបង | ៦៣ | ២.៣០៨ | ១.២២១ |
| ខេត្តសៀមរាប | ៨៩ | ៣.០១៩ | ១.៤៦៣ |
| ខេត្តឧត្តរមានជ័យ | ៣៥ | ៣.២៣១ | ២.៣២៦ |
| ខេត្តកំពង់ចាម | ៤០០ | ៩.៨១៥ | ៤.៨១១ |
| ខេត្តត្បូងឃ្មុំ | ៧៩ | ៤.៩២៩ | ២.៩៧៧ |
| ខេត្តស្វាយរៀង | ៦៨ | ១.២៧៦ | ៧៧៦ |
| ខេត្តកណ្ដាល | ២៤ | ៤.៣១០ | ១.៧៦៨ |
| ខេត្តព្រៃវែង | ១១ | ៨៦.៤៧៧ | ១.២៧៨ |
| ខេត្តព្រះសីហនុ | ០២ | ១៦៨ | ៥៧ |
| ខេត្តតាកែវ | ៩២ | ៤.២៩១ | ១.៦៧៥ |
| ខេត្តកែប | ២៣ | ១១.០៤៣ | ៥.៧៩៥ |
| ខេត្តរតនគិរី | ២០ | ៣.៣៦៧ | ១.៦៨៧ |
| ខេត្តមណ្ឌលគិរី | ១៦ | ២.៩២៥ | ១.៣៩៨ |
| ខេត្តកំពង់ស្ពឺ | ៣២១ | ១៤៧.៩៥៤ | ៨០.៧៨៣ |
| ខេត្តកំពង់ឆ្នាំង | ២៤ | ៦១១ | ២៥២ |
| ខេត្តកំពង់ធំ | ៣៧ | ២.០៥១ | ១.៤៤២ |
| សរុប | ១.៣៣៩លើក | ៣៨៦.៧៨៣នាក់ | ១១៨.៥៤៣នាក់ |
| អង្គការតំណក់ទឹក(ខេត្តបន្ទាយមានជ័យ) | ០៩ | ៥១០ | ៣០៣ |
| អង្គការកល្យាណមិត្ត(ខេត្តបន្ទាយមានជ័យ) | ១១ | ៥៨៧ | ២២១ |
| អង្គការហ្វ្រេន្សអ៊ិនធីណាសិនណល(ខេត្តបន្ទាយមានជ័យ) | ០២ | ២០៤ | ១២១ |
| អង្គការមូលនិធិអេ២១(ខេត្តបន្ទាយមានជ័យ) | ១០ | ៧១០ | ៣២០ |
| អង្គការ IOM សហការជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ០៣ | ៦១០ | ២៧៣ |
| អង្គការអន្តរជាតិ(ILO)(ខេត្តបាត់ដំបង) | ០៦ | ៤៩៣ | ២៨៦ |
| អង្គការអន្តរជាតិ(ILO) (ខេត្តសៀមរាប) | ១៣ | ៤៤៩ | ២៧៤ |
| អង្គការបន្ទាយស្រី, អង្គការ IOM, អង្គការទន្លេគ្លីនិក, អង្គការអេ២១ អង្គការ (IJM) (ខេត្តសៀមរាប) | ៣៣៧ | ២៣.២៦៩ | ១៣.៤៦៨ |
| អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប) | ៥៥ | ៣.៩៤៧ | ៩០៩ |
| អង្គការ APLE(ខេត្តសៀមរាប) | ២២ | ៣.៤០៣ | ១.៩៩៣ |
| អង្គការសកម្មភាពដើម្បីកុមារ(ខេត្តសៀមរាប) | ០២ | ៣.៣៧៤ | ២.១២០ |
| អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) (ខេត្តកំពង់ចាម) | ០៥ | ៣៦៥ | ២៤១ |
| អង្គការសម្ព័ន្ធចាប់ដៃ (ខេត្តកំពង់ចាម ) | ០១ | ១៨ | ០៥ |
| អង្គការ ILO និង អង្គការ LSCW (ខេត្តកំពង់ចាម) | ០៣ | ៦៥៦ | ៣១៨ |
| អង្គការសម្ព័ន្ធចាប់ដៃ (ត្បូងឃ្មុំ) | ០៨ | ១.៧៤៤ | ១០៥ |
| អង្គការ(CWCC) (ខេត្តបន្ទាយមានជ័យ) | ០២ | ៣២១ | ២០០ |
| អង្គការ APLE (ខេត្តក្រចេះ) | ០១ | ១២៩ | ៧៥ |
| អង្គការសាម៉ារីតានភឺស (ខេត្តបាត់ដំបង) | ១០ | ១.១០៤ | ៦៤៦ |
| សរុប | ៥០០លើក | ៤១.៨៩៣នាក់ | ២១.៨៧៨នាក់ |
| សរុបរួម | ១.៨៣៩លើក | ៤២៨.៦៧៦នាក់ | ១៤០.៤២១នាក់ |

### ១.១.៥. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិន៖** (១)-ក្នុងកិច្ចពិភាក្សាលើប្រធានបទ "ការផ្សព្វផ្សាយនៃការសិក្សា ស្តីពី ផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃបរិបទកូវីដ-១៩ លើបញ្ហាពលករទេសន្តរប្រវេសន៍នៅកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងប្រទេសថៃ តាមប្រព័ន្ធអនឡាញ (២)-ក្នុងវេទិកា ស្តីពី "មោទនភាពស្ត្រីពលករចំណាកស្រុក" ដែលរៀបចំដោយស្ថានីយវិទ្យុស្ត្រី (៣)-ក្នុងវេទិកាពិភាក្សា ស្តីពី"នីតិវិធីក្នុងការជ្រើសពលករ"។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** មាន៖

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** (ក)-ឯកឧត្តម អគ្គលេខាធិការរង និងលោកប្រធានក្រុម បានអញ្ជើញជាគ្រូបង្គោលធ្វើបទឧទ្ទេសច្បាប់ ជូនដល់កងកម្លាំងរក្សាសន្តិភាពពហុជាតិ ចំនួន **០២លើក៖** (១)-សិក្ខាកាមជាកងកម្ទេចគ្រាប់មិនទាន់ផ្ទុះ(EOD) ដែលត្រៀមចូលរួមបំពេញបេសកកម្ម នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ចំនួន **៤៥នាក់** (ស្រី **០៥**នាក់)។ (២)-បើកវគ្គបណ្តុះបណ្តាល ជូនដល់សិក្ខាកាមជា កងអនុសេនាធំព្រលានយន្តហោះលេខ៧២៩ កងអនុសេនាធំកម្ទេចគ្រាប់មិនទាន់ផ្ទុះ លេខ៨២៨ និងលេខ២៨៨ ដែលត្រូវចេញទៅបំពេញបេសកកម្ម នៅសាធារណរដ្ឋសូម៉ាលី សរុបចំនួន **១០៦នាក់** (ស្រី **១៦**នាក់) និងចេញវិញ្ញាបនប័ត្រជូនសិក្ខាកាមចំនួន **១២៧**នាក់។ (ខ)-ចូលរួមធ្វើបទបង្ហាញ ស្តីពី«ការការពារសុវត្ថិភាពកុមារតាមប្រព័ន្ធអ៊ីនធឺណិត» នៅក្នុងកម្មវិធីកិច្ចពិភាក្សា ស្តីពី«ការលើកកម្ពស់សុវត្ថិភាពស្ត្រី និងកុមារតាមអ៊ីនធឺណិត» ដែលរៀបចំដោយក្រុមហ៊ុន Meta និងអង្គការ auscam freedom project នៅសណ្ឋាគារ Hyatt រាជធានីភ្នំពេញ។ (គ)-លោកប្រធានក្រុមជំនួយកិច្ចការ ចូលរួមជាគ្រូឧទ្ទេស៖ (១).ក្នុងវគ្គបណ្តុះបណ្តាលស្តីពី«ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស» នៅខេត្តសៀមរាប បាត់ដំបង ត្បូងឃ្មុំ កំពង់ធំ និងខេត្តកំពង់ចាម។ (២).វគ្គបណ្តុះបណ្តាលស្តីពី«កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន» នៅខេត្តព្រះសីហនុ។

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖** ឯកឧត្តមអគ្គលេខាធិការរង និងលោកប្រធានក្រុម បានអញ្ជើញជាគ្រូបង្គោលធ្វើបទឧទ្ទេសច្បាប់ដល់សិក្ខាកាមជា៖ (១)-កងអនុសេនាធំវិស្វកម្មសំណង់លេខ៤៣២ ដែលត្រៀមបំពេញបេសកកម្មរក្សាសន្តិភាពនៅសាធារណរដ្ឋលីបង់ ចំនួន **៦៣**នាក់(ស្រី **២២**នាក់) នៅសាលាហ្វឹកហ្វឺនបណ្តុះបណ្តាល កងកម្លាំងរក្សាសន្តិភាពពហុជាតិ។ (២)-កងអនុសេនាធំព្រលានយន្តហោះលេខ៧២៩ កងអនុសេនាធំកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ៨២៨ និងកងអនុសេនាធំកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ២៨៨ ចំនួន **៥៣**នាក់ (ស្រី **១៨**នាក់) ដែលនឹងត្រូវចេញទៅបំពេញបេសកកម្មរក្សាសន្តិភាព អ.ស.ប នៅសាធារណរដ្ឋសូម៉ាលី។

▪ **ខេត្តកំពង់ចាម៖** (ក)-**តំណាងស្នងការដ្ឋាននគរបាល** បានចូលរួមជាវាគ្មិននៅតាមវិទ្យុជាតិខេត្ត ចំនួន ០៧លើក ក្រោមប្រធានបទ ស្តីពី៖ **១**-ការអន្តរាគមន៍និងការពារផ្លូវច្បាប់ដល់ស្ត្រីរងគ្រោះពីអំពើជួញដូរមនុស្ស។ **២**-ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់ក្រោយពីពិធីបុណ្យចូលឆ្នាំថ្មី។ **៣**-ការទប់ស្កាត់បទល្មើសជួញដូរផ្លូវភេទក្នុងវិស័យទេសចរណ៍ និងការទប់ស្កាត់អំពើជួញដូរពលកម្មក្នុងវិស័យទូកនេសាទ។ **៤**-ការអន្តរាគមន៍ និងជួយសង្គ្រោះស្ត្រីរងគ្រោះចាញ់បោកមេខ្យល់នាំទៅក្រៅប្រទេស។ **៥**-សេវាទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានលើស្ត្រី, **៦**- ការចំណាកស្រុកដោយសុវត្ថិភាព, **៧**-ការទប់ស្កាត់អំពើជួញដូរពលកម្ម និងស្ថានភាពពលករចំណាកស្រុកក្រោយវិបត្តិកូវីដ-១៩។ (ខ)-**តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាក្រោមប្រធានបទ បិទបញ្ចប់គម្រោង ស្តីពី ៖ **១**-ការលើកកម្ពស់ និងការការពារសិទ្ធិរបស់ពលករកម្ពុជា ដែលមានជំនាញទាបនៅប្រទេសថៃ" ដែលអនុវត្តដោយ អង្គការ LSCW និង WeWorld Onlus ០១លើក។ **២**-ការអប់រំផ្សព្វផ្សាយចំណេះដឹងដល់ប្រជាពលរដ្ឋ ពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ពង្រឹងប្រសិទ្ធភាពផ្សព្វផ្សាយ និងទប់ស្កាត់ការធ្វើចំណាកស្រុកដោយខុសច្បាប់។ **៣**-ក្នុងវិទ្យុ ក្រោមប្រធានបទ «ការទប់ស្កាត់ការចំណាកស្រុកខុសច្បាប់ ក្រោយពិធីបុណ្យចូលឆ្នាំថ្មី» ចំនួន ០២លើក។ (គ)-**តំណាងមន្ទីរកិច្ចការនារី** បានចូលរួមជាវាគ្មិន ស្តីពីការផ្តល់ជំនាញនិងមុខរបរដល់ស្ត្រី ដើម្បីបង្កើនជីវភាពគ្រួសារកាត់បន្ថយចំណាកស្រុក។ (ឃ)-**រដ្ឋបាលក្រុងកំពង់ចាម** បានចូលរួមជាវាគ្មិន ចំនួន ០២លើក ក្រោមប្រធានបទ៖ **១**-ដំណោះស្រាយបញ្ហាប្រឈម របស់ពលករចំណូលស្រុក និងការផ្តល់សេវាគាំទ្រដល់ពលករ ក្នុងអំឡុងពេលកូវីដ-១៩,**២**-ការទប់ស្កាត់ពលរដ្ឋកុំឱ្យឆ្លងដែនខុសច្បាប់ទៅប្រទេសជិតខាង។

▪ **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរួមចូលជាវាគ្មិនចែករំលែក ស្តីពីនីតិវិធី៖ ១-តាមវិទ្យុជាតិកម្ពុជា បានចំនួន **១៩**លើក នៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពបញ្ជូនជនរងគ្រោះ ដំណោះស្រាយវិវាទពលករ និងសិទ្ធិពលករចំណាកស្រុក មានអ្នកចូលរួមចំនួន **២.៥២១**នាក់ (ស្រី **១.២១៩**នាក់)។ ២-ការបញ្ជូនជនរងគ្រោះ ដំណោះស្រាយវិវាទពលករ និងសិទ្ធិពលករចំណាកស្រុក មានអ្នកចូលរួមចំនួន **០៧នាក់** (ស្រី **០២**នាក់) ដែលរៀបចំឡើងដោយអង្គការសាម៉ារីតាន់គីស។

## ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានពង្រឹង និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈការងារដោយបាន៖ (១)-ផ្សព្វផ្សាយតាមប្រព័ន្ធ Online ចំនួន **១១.៦៧៨**ដង។ (២)-ចងក្រង និងផលិតស្ពតផ្សព្វផ្សាយចំនួន **១៧៥**ដង។ (៣)-ធ្វើកម្មវិធី Roadshow និងផ្សព្វផ្សាយនៅតាមសហគមន៍ បានចំនួន **១២៩**ដង ដែលមានសិស្សចំនួន **៣៤.៨២១**នាក់ (ស្រី **១៤.៤០៣**នាក់)។ (៤)-ប្រជាពលរដ្ឋ សិស្ស និស្សិតចូលប្រើប្រាស់គេហទំព័រការងារទីភ្នាក់ងារជាតិមុខរបរ និងការងារ មានចំនួន **៣៨៣.៩៦៣**លើក និងអ្នកទទួលបានព័ត៌មានអំពីទីផ្សារការងារ តាមរយៈទំព័រ Facebook មានសរុបចំនួន **៤១២.២៤៦**នាក់។ និងមានអ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើទូរស័ព្ទឆ្លាតវៃមានសរុប **១.៣៤៩**នាក់។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ ១-ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** បានសហការជាមួយ និយ័តករទូរគមនាគមន៍កម្ពុជា (TRC) ធ្វើការផ្ញើសារអប់រំតាមរយៈទូរស័ព្ទចល័ត ចំនួន **០២លើក៖** «ទិវាកុមារអន្តរជាតិ ០១ មិថុនា៖ រួមគ្នាលុបបំបាត់រាល់ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ» និង «ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ៖ រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព»និងផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈគេហទំព័រហ្វេសប៊ុក មានអ្នកចូលមើលចំនួន **៦២.៥៧៤**នាក់។ **២-ការិយាល័យស្រាវជ្រាវព័ត៌មាន** បានត្រួតពិនិត្យការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈគេហទំព័រហ្វេសប៊ុក មានអ្នកចូលមើលចំនួន **២៦.៥៩៣**នាក់។

▪ **ខេត្តសៀមរាប៖**

- មន្ទីរព័ត៌មាន បានធ្វើការ៖ ១-ផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីកិច្ចការពារជនរងគ្រោះវិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារក្នុងស្រុកជាជាងការចំណាកដោយប្រថុយប្រថាន ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ចំនួន **១.៩៨៤**លើក (ផ្សាយផ្ទាល់ **៤៨៦**លើក និងចាក់ផ្សាយឡើងវិញ **១.៤៩៨**លើក)។ ២-ផ្សាយបនតផ្ទាល់ និងផ្សព្វផ្សាយនៅក្នុងទូរទស្សន៍ជាតិខេត្តសៀមរាប និងគេហទំព័រហ្វេសប៊ុក ស្តីពីការប្រារព្ធពិធីអបអរសាទរទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ដែលមានអ្នកចូលទស្សនាចំនួន **១.២៣៩**ដង។
- លេខាធិការដ្ឋាន គ.ខ.ប.ជ ផ្សព្វផ្សាយតាមប៉ុស្តិ៍វិទ្យុ ទូរទស្សន៍ បានចំនួន **១.១២៣**លើក ដែលមានអ្នកចូលរួមសរុប **៤២.១០៩**នាក់ ស្រី **២៦ .១៥៩**នាក់។

▪ **ខេត្តព្រៃវែង៖ មន្ទីរព័ត៌មាន** បានធ្វើការផ្សព្វផ្សាយសារអប់រំតាមវិទ្យុបាយណ៍អណ្តែត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **៦០០**លើក ក្នុងមួយថ្ងៃ **០៥**លើក។

▪ **ខេត្តកំពង់ចាម៖ មន្ទីរព័ត៌មាន៖** បានផ្សព្វផ្សាយនៅវិទ្យុជាតិភ្នំប្រុស ភ្នំស្រី ចំនួន **០៥**លើក លើប្រធានបទមួយចំនួនដូចខាងក្រោម៖១-ការទប់ស្កាត់អំពើជួញដូរពលកម្មក្នុងវិស័យចុះទូកនេសាទ, ២-ការអន្តរាគមន៍និងការពារផ្តល់ប្រយោជន៍ដល់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស, ៣-ការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋមុនរៀបការ ឬភ្ជាប់ពាក្យជាមួយជនបរទេស, ៤-ចូលរួមទប់ស្កាត់អំពើជួញដូរផ្លូវភេទតាមរយៈវិស័យទេសចរណ៍, ៥-ផ្សព្វផ្សាយ និងទប់ស្កាត់ការចំណាកស្រុកខុសច្បាប់ ,៦-ការអប់រំផ្សព្វផ្សាយចំណេះដឹងដល់ប្រជាពលរដ្ឋពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស។

▪ **ខេត្តតាកែវ៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស៖ (១)-ទូរទស្សន៍ជាតិគោកធ្លក(តាមរយៈស្ថានីយ៍ទូរទស្សន៍ខ្សែកាបប៉ុស្តិ៍លេខ១៤)សរុបចំនួន **១៩.៧៣៩**លើក។ (២)-ស្ថានីយ៍វិទ្យុសរុបចំនួន **១៨.១០៤**លើក។

▪ **ខេត្តកំពង់ឆ្នាំង៖ មន្ទីរអប់រំ យុវជន និងកីឡា** បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សតាមរយៈការប្រជុំតាមប្រព័ន្ធ Telegram ឬ Google Meet ទៅដល់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកទាំង៨ ដើម្បីធ្វើការផ្សព្វផ្សាយបន្តទៅដល់ នាយក នាយិកា សិស្សានុសិស្ស នៅពេលគោរពទង់ជាតិមុនចូលរៀន និងក្នុងម៉ោងសិក្សាចំពោះមេរៀនដែលពាក់ព័ន្ធ។

▪ **ខេត្តក្រចេះ៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់តាមវិទ្យុ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចំនួន **៣០០**លើក។

▪ **ខេត្តត្បូងឃ្មុំ៖** បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ស្តីពីការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" និងការអប់រំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន **៤៨៤**លើក។

### ១.៣. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

▪ **អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ** សហការជាមួយអង្គការយូនីសេហ្វ(Unicef) បានផលិតរឿងកំប្លែងអប់រំខ្លី២រឿង ដែលស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្សក្នុងសហគមន៍ ក្នុងនោះមាន (១) រឿងអូសមិនបានប្រានមិនដល់ នៅក្នុងវគ្គទី១២នៃកម្មវិធីផ្ទះលេខ១ផ្ទះលេខ២ និង(២) រឿងក្រូចនាំមនុស្សមកផ្ទះ នៅក្នុងវគ្គទី១៧នៃកម្មវិធី១៦៨យប់។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណព័ត៌មានអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពដល់ពលករទេសន្តរប្រវេសន៍ និងប្រជាពលរដ្ឋដែលមានបំណងធ្វើទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច តាមរយៈមណ្ឌលធនធានពលករ (MRC) ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តបាត់ដំបង និងខេត្តកំពត។

▪ **ក្រសួងកិច្ចការនារី៖** បានចែករូបភាពសន្លឹកផ្ទាត់ ស្តីពី "ការលើកកម្ពស់សុវត្ថិភាពសម្រាប់ពលករចំណាកស្រុកជាស្ត្រី តាំងពីមុនចេញដំណើរ" ក្នុងគោលបំណងបណ្តុះបណ្តាលបន្តទៅមន្ត្រីថ្នាក់ខេត្ត/ស្រុក ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋបានយល់ដឹងពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសេវាគាំទ្រផ្សេងៗ បានចំនួន ២៥ច្បាប់ ដល់មន្ត្រីកិច្ចការនារីទាំង ២៥រាជធានី-ខេត្ត។

▪ **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ៖** នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បាន៖

- បញ្ចូលសារអប់រំពាក់ព័ន្ធការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សទៅក្នុង CD, VCD, DVD របស់ផលិតកម្មភាពយន្ត និងក្រុមហ៊ុននាំចេញ-នាំចូលខ្សែភាពយន្តបានចំនួន **៦៣**រឿង និងបានបញ្ចាំងខ្សែភាពយន្តចំនួន **១៨៩**លើក។

- ចូលរួមសម្តែងសិល្បៈក្នុងកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ នៅសាលមហោស្រពកោះពេជ្រ ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងចូលរួមសម្តែងនៅគណៈកម្មាធិការ គ.ខ.ប.ជ ខេត្តស្វាយរៀង។

▪ **កាកបាទក្រហមកម្ពុជា៖** បានចែកខិត្តប័ណ្ណ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន **៧៣.១៨៨**សន្លឹក ដល់ប្រជាពលរដ្ឋនៅតាមបណ្តារាជធានី-ខេត្ត។

▪ **ខេត្តសៀមរាប៖**

○ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចែកខិត្តប័ណ្ណចំនួន **៣០០**សន្លឹក ផ្តល់ព័ត៌មានតាមរយៈទូរស័ព្ទសម្រាប់ជួយធ្វើអន្តរាគមន៍នៅពេលប្រជាពលរដ្ឋជួបនូវបញ្ហាដូចជាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការរំលោភបំពានលើពលករទេសន្តរប្រវេសន៍ជាស្ត្រី។

○ **មជ្ឈមណ្ឌលការងារខេត្តសៀមរាប** បានបង្កើតកម្មវិធី និងចែកខិតប័ណ្ណពត៌មានទីផ្សារការងារ ដែលមានអ្នកទទួលបានសរុប ៨ ០១២នាក់ ស្រី ៤.១៦៤នាក់។

- **អង្គការមូលនិធិអេ២១ (A21)** បានចែកជូននូវសៀវភៅ ស្ដីពីកិច្ចការពារខ្លួនពីអំពើជួញដូរមនុស្ស និងប័ណ្ណផ្ដល់ព័ត៌មានស្ដីពីករណីជួញដូរមនុស្ស បានចំនួន **២០.៧៧៤**ប័ណ្ណ។

▪ **ខេត្តបន្ទាយមានជ័យ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអង្គភាពពាក់ព័ន្ធ អាជ្ញាធរ ក្រុង ស្រុក បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដូចជា៖

- **អង្គការសាម៉ារីតាន់ភឺស (Samaritan Purse)** បានអប់រំផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណ សរុបចំនួន **៣០.៨៤២**នាក់(ស្ត្រី **២១.៩២៣**នាក់) កុមារ **៣.០៩១**នាក់(កុមារី **១.៥៣៨**នាក់)។
- **អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)** បានអប់រំផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណ សរុបចំនួន **៧.៤៨១**នាក់(ស្រី **៣.២៩៧**នាក់)។
- **អង្គការដំណក់ទឹក** បានអប់រំផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណ សរុបចំនួន **៤៨០**នាក់(ស្រី **២៦៩**នាក់)។

▪ **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស(Samaritan Purse)** តាមរយៈកម្មវិធី "ស្ពាន (BRIDGE)" និងកម្មវិធី "មជ្ឈមណ្ឌលផ្ដល់ជំនួយផ្នែកចំណាកស្រុក(L-MA)" បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំនួន **២.៧២៨**នាក់ (ស្ត្រី **១.២៦៧**នាក់) កុមារ **៣៨១**នាក់។

▪ **ខេត្តស្វាយរៀង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការផ្សព្វផ្សាយសារអប់រំ ស្ដីពីចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ តាមរយៈបិទបដាចំនួន **៥០០**ផ្ទាំង នៅតាមកន្លែងពិធីប្រណាំងទូកទន្លេវៃគោ។

▪ **ខេត្តត្បូងឃ្មុំ៖** បានចងបដាពាក្យស្លោកផ្សព្វផ្សាយពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ៤០បដា ក្នុងឱកាសពិធីបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ។

▪ **អង្គការសម្ព័ន្ធចាប់ដៃ៖** បានចែកជូននូវសៀវភៅច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **១៥០**ក្បាល ដល់សិក្ខាកាម ដែលចូលរួមវគ្គបណ្ដុះបណ្ដាលក្នុងខេត្តចំនួន ០២ (ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ)។

## ២. ការបង្ការទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការផ្ដល់ព័ត៌មាន និងបង្កើតកម្មវិធីសិក្សា ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

▪ **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** បាន៖ (១)-រៀបចំវគ្គណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅបរទេសចំនួន **៤៩៨**លើក ដែលមានពលករចំនួន **២៥.២២៤**នាក់ (ស្រី **៩.៩៤៩**នាក់) **(២)**-ប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មបានចំនួន **១០៥.៣៨៧**កន្លែង **(៣)**-ផ្ដល់វគ្គបណ្ដុះបណ្ដាលផ្នែកអាហារូបករណ៍ចំនួន **៥៤៥**វគ្គ **(៤)**-ផ្ដល់វគ្គបណ្ដុះបណ្ដាលផ្នែកជំនាញទន់បានចំនួន **១៥**វគ្គ មានអ្នកចូលរួមចំនួន **៩៧២**នាក់ **(៥)**-ផ្ដល់សេវាប្រឹក្សាយោបល់ អំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកមកទទួលសេវាចំនួន **១២.៤៨៨**នាក់ **(៦)**-ផ្ដល់កម្មវិធីតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅ ៤៦៩សាលា ដែលមានសិស្សសរុបចំនួន **៩២.៧៥៩**នាក់ (ស្រី **៤៨.៩១៥**នាក់) **(៧)**-ចូលរួមផ្ដល់វិធីធ្វើបទបង្ហាញ និងសម្របសម្រួលវគ្គបណ្ដុះបណ្ដាល ស្ដីពីប្រព័ន្ធអន្តរជាតិនៃការជ្រើសរើសពលករដោយសុចរិត (IRIS) **(៨)**-សហការជាមួយអង្គការ ILO រៀបចំសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិ និងការចែករំលែកបទពិសោធន៍ពីកម្មវិធី SaverAsia ៖ សេវាឌីជីថលក្នុងការលើកកម្ពស់សុវត្ថិភាពផ្នែកហិរញ្ញវត្ថុ សម្រាប់ពលករទេសន្តរប្រវេសន៍ និងការរៀបចំពិធីផ្សព្វផ្សាយតាមរយៈការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលការងារទេសន្តរប្រវេសន៍ខេត្តពោធិ៍សាត់ **(៩)**-បានសហការរៀបចំកម្មវិធីសិក្ខាសាលា ស្ដីពីការណែនាំសៀវភៅភាសាជប៉ុន អ៊ីរ៉ូដូរី និងតេស្តភាសាជប៉ុន JFT-Basic ក្នុងគម្រោងពលករជំនាញកម្ពុជាទៅប្រទេសជប៉ុន។

## ២.២. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់

- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលចំនួន ០៤ខេត្ត បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ចំនួន **១០៩**លើក មនុស្សចំនួន **១.៦៦៣**នាក់ (ស្រី **៦៣៦**នាក់) អនីតិជន **២០៣**នាក់ បានធ្វើកិច្ចសន្យាការអប់រំណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត ក្នុងនោះមាន៖
  - ខេត្តបាត់ដំបង ចំនួន **១០**លើក មនុស្សចំនួន **១១៤**នាក់(ស្រី **៥៣**នាក់) អនីតិជន **២៩**នាក់ ។
  - ខេត្តបន្ទាយមានជ័យ ចំនួន **៩៦**លើក មនុស្សចំនួន **១.៥៣២**នាក់(ស្រី **៥៧៨**នាក់) អនីតិជន **១៧៤**នាក់។
  - ខេត្តឧត្តរមានជ័យ ចំនួន **០២**លើក មនុស្សចំនួន **១១**នាក់ (ស្រី **០៤**នាក់)។
  - ខេត្តសៀមរាប ចំនួន **០១**លើក មនុស្សចំនួន **០៦**នាក់ (ស្រី **០១**នាក់)។
- **ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** បានធ្វើការសហការ និងសម្របសម្រួលជាមួយអាជ្ញាធរថៃ ដោយបានចាប់ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ចំនួន **៥៩**នាក់(ស្រី **៣១**នាក់) ឱ្យធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ និងបញ្ជូនមេខ្យល់ ០១នាក់ ទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។

## ២.៣. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ថ្នាក់ជាតិ៖**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖ ចុះអធិការកិច្ចការងារកុមារក្នុងវិស័យវាយនភ័ណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប សិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម ចំនួន **៥៤**លើក ក្នុងនោះវិស័យសិប្បកម្មផលិតឥដ្ឋ បានចំនួន១០សិប្បកម្ម និងកសិឧស្សាហកម្មចំនួន ០៨សហគ្រាស។ បានដាក់កំហិតរោងចក្រ សហគ្រាស គ្រឹះស្ថានចំនួន ០៧សហគ្រាស និងផាកពិន័យចំនួន ០១សហគ្រាស។ បានចុះពិនិត្យវាយតម្លៃប្រភេទការងារ លក្ខខណ្ឌការងារ និងកំណត់អត្តសញ្ញាណកម្មករ នយោជិតវ័យក្មេងតាមការស្នើសុំរបស់រោងចក្រ សហគ្រាស គ្រឹះស្ថានចំនួន០៧។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)៖**
  - **ក្រុមការងារនៃការិយាល័យនីតិកម្ម និងអធិការកិច្ច** បានចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលមានកិច្ចព្រមព្រៀង ជាមួយក្រសួង ស.អ.យ និងមណ្ឌលសំចត សរុបចំនួន **១៨**មណ្ឌល (មជ្ឈមណ្ឌលរបស់អង្គការមាន ១៧មណ្ឌល និងមណ្ឌលសំចតប៉ោយប៉ែតរបស់នាយកដ្ឋានគាំពារជនរងគ្រោះចំនួន០១មណ្ឌល) ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីត្រួតពិនិត្យដល់មជ្ឈមណ្ឌលទាំងអស់នោះត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ក្រសួង។
  - **ក្រុមការងារនៃការិយាល័យគ្រប់គ្រងករណី និងការិយាល័យសង្គ្រោះ** បានសហការជាមួយបណ្តាញ Partnership Program for Protect Children (3PC)ធ្វើការចុះស្វែងរក និងប៉ាន់ប្រមាណគ្រួសាររងគ្រោះដោយអំពើជួញដូរមនុស្ស មុនមាតុភូមិនិវត្តន៍ ដើម្បីបញ្ជូនជនរងគ្រោះទៅទទួលសេវាបន្តនៅអង្គការដៃគូ និងទៅសហគមន៍វិញ បន្ទាប់ពីធ្វើចត្តាឡីស័ក្ករួច ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ(Unicef)។
- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ៖** បានធ្វើការណែនាំដល់ចាងហ្វាងផលិតកម្មភាពយន្តឯកជន ឱ្យដំឡើងសារអប់រំផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃអំពើជួញដូរផ្លូវភេទ ទេសន្តរប្រវេសន៍ខុសច្បាប់ អំពើពោះជំនួស និងអំពើជួញដូរស្រីពេស្យា ទៅក្នុងផលិតផលខ្សែភាពយន្ត ចម្រៀងកាយវិការ និងចម្រៀងខារ៉ាអូខេ នៅរៀងរាល់ពេលដែលសុំទិដ្ឋាការ បានចំនួន ៧០ក្រុមហ៊ុន និងផលិតកម្ម។

## ២.៤. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

### ២.៤.១. ការគ្រប់គ្រងស្ថិតិពលករខ្មែរ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** យោងតាមតាមរបាយការណ៍ឆ្នាំ២០២២នេះ ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System (EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប **៣៣.៧៤២**នាក់ (ស្រី **១៣.០០៥**នាក់) ក្នុងនោះមាន៖

| | | |
|---|---|---|
| - សាធារណរដ្ឋកូរ៉េ | ចំនួន **៨.៨៨០**នាក់ | (ស្រី **២.៤៥៧**នាក់) |
| - ប្រទេសជប៉ុន | ចំនួន **៦.៣៦៥**នាក់ | (ស្រី **២.៧៥៥**នាក់) |
| - ប្រទេសថៃ | ចំនួន **១៨.៤១៧**នាក់ | (ស្រី **៧.៧១៣**នាក់) |
| - ប្រទេសសិង្ហបុរី | ចំនួន **៤៧**នាក់ | (ស្រី **៤៧**នាក់) |
| - តំបន់រដ្ឋបាលពិសេសហុងកុង | ចំនួន **៣៣**នាក់ | (ស្រី **៣៣**នាក់)។ |

➢ **និងបាន៖** **១**-ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន និងប្រព័ន្ធតាមដាន ជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ រហូតដល់ពលករវិលត្រឡប់មកមាតុប្រទេសវិញ។ **២**-បានរៀបចំ និងពង្រឹងប្រព័ន្ធ OCWC (Oversea Cambodian Working Card) ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ ដូចជាការបែងចែកទៅតាមភេទ អាយុ កម្រិតអប់រំ និងប្រភេទការងាររបស់ពលករជាដើម សម្រាប់ធ្វើជាធាតុចូល ក្នុងការរៀបចំគោលនយោបាយ ឬបទដ្ឋានគតិយុត្ត។ **៣**-បានពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីតាមដានលំហូរនីតិវិធីនៃការធ្វើទេសន្តរប្រវេសន៍ការងារនៅគ្រប់ប្រទេសទទួល។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖**
  - ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទាំង២៥ បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរធ្វើចំណាកស្រុកទៅក្រៅប្រទេស ទាំងស្របច្បាប់ មិនស្របច្បាប់ និងជាប់ការទាក់ទង សរុបចំនួន **២៣០.៣៣១**នាក់ (ស្រី **១០១.៦៦០**នាក់) អនីតិជន **៣.៣៨០**នាក់ (ស្រី **៤២៩**នាក់) ក្នុងនោះ៖
    - ចេញដោយស្របច្បាប់ចំនួន **១៧២.៩៦០**នាក់ (ស្រី **៧៧.០៥៤**នាក់) អនីតិជន **៣៣៥**នាក់ (ស្រី **១០៣**នាក់)។
    - ចេញដោយមិនស្របច្បាប់ចំនួន **៥៦.៦៨៨**នាក់ (ស្រី **២៤.៣០៩**នាក់) អនីតិជន **២.៩៤១**នាក់ (ស្រី **២៩៧**នាក់)។
    - ជាប់ការទាក់ទងចំនួន **៦៨៣**នាក់ (**ស្រី ២៩៧**នាក់) អនីតិជន **១០៤**នាក់ (ស្រី **២៩**នាក់)។
  - ទិន្នន័យពលរដ្ឋត្រឡប់ពីក្រៅប្រទេសដោយខ្លួនឯង ទាំងស្របច្បាប់ និងមិនស្របច្បាប់ ពីស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សរុបចំនួន **៨០.៧៤៤**នាក់ (ស្រី **៣៤.៥៣៩**នាក់) អនីតិជន **៤៤៩**នាក់ (ស្រី **១៦៤**នាក់)។

### ២.៤.២. ការគ្រប់គ្រងស្ថិតិជនបរទេស បច្ចុប្បន្នភាពចំណូលស្រុក

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖**

**១-ការគ្រប់គ្រងស្ថិតិជនបរទេសចូលមកកម្ពុជាស្របច្បាប់៖** ក្រោយបញ្ចប់យុទ្ធនាការជំរឿនស្ថិតិ និងដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី អគ្គនាយកដ្ឋានបានបង្កើនការគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត ដោយបានរៀបចំបែបបទស្នើសុំក្រសួងមហាផ្ទៃ ផ្តល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍មានរយៈពេល ០២ឆ្នាំម្តង ជូនអ្នកដែលមានអាយុ ១៨ឆ្នាំឡើង សរុបចំនួន **១០០.៨០០**បណ្ណ ក្នុងនោះស្នើសុំលើកដំបូងចំនួន **៦៥.៩៣០**បណ្ណ ហើយបានបន្តសុពលភាពលើកទី១ ចំនួន **២៨.៤២៥**នាក់, លើកទី២ ចំនួន **៦.២៦៣**នាក់, លើកទី៣ ចំនួន **១៧៣**នាក់ និងលើកទី៤ ចំនួន **០៩**នាក់។ តាមការស្រាវជ្រាវទិន្នន័យនៃការផ្តល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍ ពិនិត្យឃើញថា មានជនអន្តោប្រវេសន្តចំនួន **១៧.២៥១**នាក់ ដែលមិនទាន់មកដាក់ពាក្យស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍ ដែលបញ្ហានេះអគ្គនាយកដ្ឋានកំពុងមានវិធានការ ដើម្បីជំរុញឱ្យពួកគេគោរពតាមគោលការណ៍ច្បាប់ជាធរមាន។

ក្រៅពីនេះក៏បានអនុវត្តនូវវិធីស្ទេន និងបញ្ចូលសំណុំឯកសារជនបរទេសអន្តោប្រវេសន្ត ដើម្បីថែរក្សាទុកយូរក្នុងប្រព័ន្ធ IMS មាន៖ (១)-បញ្ចូលទិន្នន័យបានចំនួន **១០.៨៣០**នាក់ (ស្រី **៥.៣៨៩**នាក់) ស្មើ **២.៧៤៧**គ្រួសារ ទូទាំង២៥រាជធានី ខេត្ត (២)-ស្ទេនសំណុំឯកសារក្នុងប្រព័ន្ធ (IMS) នៅឆ្នាំ២០២២នេះ បានចំនួន **៦.៧៣៤**សំណុំឯកសារ មនុស្សរួម **៩.៤៣៣**នាក់ ស្មើនឹង **១១%** (ប្ញកយោងស្ទេនរក្សាទុកក្នុងប្រព័ន្ធ IMS

បានចំនួន **៤៨.៩៣៦**សំណុំឯកសារ ស្មើនឹង **៧៧%**) (៣)-ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សំណុំឯកសាររបស់ជនបរទេស ជាមួយនឹងទិន្នន័យដែលបានបញ្ចូលក្នុងប្រព័ន្ធ(IMS) ក្នុងឆ្នាំ២០២២បាន **៥១%**(បូកយោងបានចំនួន **៧២%**)។

- ដើម្បីជានាការគ្រប់គ្រងវត្តមានជនបរទេស បម្រើឱ្យសំណូមពរក្សាសន្តិសុខ សុវត្ថិភាពសង្គម ក្នុងឆ្នាំនេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់តាំងអនុវត្តសេចក្តីណែនាំលេខ ០២៨ ស.ណ.ន របស់ក្រសួងមហាផ្ទៃ ស្តីពីការរាយការណ៍វត្តមានស្នាក់នៅរបស់ជនបរទេសតាមមូលដ្ឋាន ការពង្រឹងសំណុំឯកសារ បែបបទពេលមកស្នើសុំបន្តទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន និងរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដោយបាន៖ (១)ផ្តល់ទិដ្ឋាការចូលប្រទេសនៅតាមច្រកទ្វារអន្តរជាតិចំនួន **៣៥០.២៤២**នាក់។ (២)ផ្តល់ទិដ្ឋាការចេញចំនួន **២.៣៩៨**នាក់ (៣)បានផ្តល់ទិដ្ឋាការពិសេស ប្រភេទ K ចំនួន **៩៧០**នាក់ ជូនពលរដ្ឋខ្មែរដែលរស់នៅប្រទេសក្រៅ (៣)ផ្តល់ទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នចំនួន**៤០៩.៣៨៧**នាក់។
- **ដោយឡែក** ចំពោះអ្នកស្នាក់នៅហួសរយៈពេលកំណត់ក្នុង ឆ្នាំ២០២២នេះ មានចំនួន **២.៣១៥**នាក់ មាន **៧៣**សញ្ជាតិ បានធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន **៦៩៥.៩៥០**ដុល្លារ បង់ចូលថវិកាជាតិ។

**២-ការគ្រប់គ្រងស្ថិតិជនបរទេសចូលមកកម្ពុជាដោយមិនស្របច្បាប់៖** បទល្មើសសរុបចំនួន **២.៨០២**លើក មានជនល្មើសចំនួន**៥.៣៧៣**នាក់ ក្នុងនោះមានករណីរកឃើញ៖

-**ការលួចឆ្លងដែនដោយខុសច្បាប់ ១៣៩**លើក ជនល្មើស **៩៤៦**នាក់ មាន**១៣**សញ្ជាតិ៖ វៀតណាម ថៃ, ចិន ,ម៉ាឡេស៊ី,មីយ៉ាន់ម៉ា, ចិនតៃវ៉ាន់, អង់គ្លេស, បែលហ្សិក, កូរ៉េខាងត្បូង , បង់ក្លាដេស, តួកគី, អាល្លឺម៉ង់ និងជនជាតិហូឡង់។

-**ការស្នាក់នៅ និងធ្វើការខុសច្បាប់** មានជនល្មើស **២.១១២**នាក់ មាន**៣៤**សញ្ជាតិ៖ ថៃ, ចិន, វៀតណាម ឥណ្ឌូនេស៊ី, នីហ្សេរីយ៉ា, អាមេរិក, មីយ៉ាន់ម៉ា, ម៉ាឡេស៊ី, កូរ៉េខាងត្បូង, អង់គ្លេស, ប៉ាគីស្ថាន, និងជនជាតិរុស្ស៊ី ។

-**ការស្នាក់នៅលើសទិដ្ឋាការកំណត់** មានជនល្មើស**២.៣១៥**នាក់ មាន **៧៣**សញ្ជាតិ មានជនជាតិ៖ ចិន, វៀតណាម, ឥណ្ឌូនេស៊ី, កូរ៉េខាងត្បូង, នីហ្សេរីយ៉ា, ឥណ្ឌា, តៃវ៉ាន់, ថៃ, ម៉ាឡេស៊ី,បង់ក្លាដែស ហ្វីលីពីន, បារាំង, អាមេរិក, អង់គ្លេស, នេបាល់, កាមីរូន, ជប៉ុន, ប៉ាគីស្ថានសឹង្ហបូរី, អាល្លឺម៉ង់, អូស្ត្រាលី, ប៉ូឡូញ។

### ២.៥. វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ** ៖ ស្នងការដ្ឋាននគរបាល និងកងរាជអាវុធហត្ថរាជធានី-ខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន **១៥៩**លើក និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់ជាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សាខារ៉ាអូខេ ជាប្រចាំ បានចំនួន **២.១៩១**គោលដៅ មានចំនួនមនុស្សសរុប **៥.៩២០**នាក់(ស្រី **៤.៤៩៣**នាក់)។

### ២.៦.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

**ក្រសួងមហាផ្ទៃ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន **១.៣៤១**នាក់ ក្នុងនោះ(ស្ត្រីខ្មែរ **១.១៥៦**នាក់ និងស្ត្រីបរទេស **១៨៥**នាក់) មាន**៣៧** សញ្ជាតិ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ និងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន **៩៥**នាក់(ស្រី **៦៦**នាក់)។

## ៣. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះ៖ ១- ធ្វើអន្តរាគមន៍ ទប់ស្កាត់ដកហូតការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្មបានចំនួន ៤០០ករណី នៅក្នុងខេត្តចំនួន ០៥ មានខេត្តសៀមរាប បាត់ដំបង កំពង់ចាម ត្បូងឃ្មុំ និងខេត្តកណ្តាល។ ២-យុទ្ធនាការផ្សព្វផ្សាយការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ តាមរយៈការចុះអធិការកិច្ចការងារក្នុងវិស័យរោងចក្រវាយនភ័ណ្ឌកាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូប សិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម បានចំនួន **៣៩**លើក ដែលមានអ្នក

ចូលរួមសរុបចំនួន ៩.១២២នាក់ (ស្រី ៣.៣៨៩នាក់) ៣-បានផ្តល់ទិដ្ឋាការប្រើប្រាសកម្មករនិយោជិតវ័យក្មេង ចំនួន ០៤សហគ្រាស។

▪ **ខេត្តក្រចេះ៖** មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះទៅណែនាំផ្សព្វផ្សាយ ទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ នៅតាមបណ្តារោងចក្រសិប្បកម្មផលិតទឹកពិសា(ដប) ជញ្ជីងថ្លឹងទម្ងន់ (ជញ្ជីងតោន) ស្ថានីយ៍ប្រេងឥន្ទនៈបានចំនួន **២៧**មូលដ្ឋាន មានបុគ្គលិកចំនួន **៨៨**នាក់(ស្រី **៣១**នាក់)។

▪ **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះទៅណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រសហគ្រាស កន្លែងលាងរថយន្ត និងកន្លែងកំសាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ ០-៣ឆ្នាំ តាមស្រុក ឃុំ ភូមិ គោលដៅទូទាំងខេត្ត។

▪ **ខេត្តបន្ទាយមានជ័យ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន៖១-សហការជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ បានធ្វើការចុះផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារក្នុងវិស័យផលិតឥដ្ឋ នៅឃុំទឹកជោរស្រុកព្រះនេត្រព្រះ បានចំនួន **០៥**លើក។ **២**-បានបញ្ជ្រាបផ្សព្វផ្សាយការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ និងការប្រើអំពើហិង្សាលើកុមារ ដល់មាតាបិតា អាណាព្យាបាល សិស្សានុសិស្ស ក្នុងពិធីសម្ពោធអគារសាលប្រជុំថ្មី ដែលមានអ្នកចូលរួមចំនួន **៦៧៥**នាក់(ស្រី **២៧៨**នាក់)។

▪ **ខេត្តប៉ៃលិន៖** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សេឡូ(ស្នាក់ការទទួលទិញផលិតផលកសិកម្ម) កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន **៨០**កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំងពលកម្មកុមារទេ។

▪ **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន៖ ១-សហការជាមួយ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ បានបញ្ជ្រាបការផ្សព្វផ្សាយការលុបបំបាត់ពលកម្មកុមារ ក្នុងវិស័យផលិតឥដ្ឋ តាមរយៈកម្មវិធីចែកកង់ និងសម្ភារសិក្សាដល់កុមារ មានសមាសភាពចំនួន **១៣៤**នាក់(ស្រី **៦៤**នាក់)។ ២-ចុះពិនិត្យ និងសម្រង់ឈ្មោះកុមារ ដើម្បីកំណត់អត្តសញ្ញាណកុមារក្រីក្រក្នុងវិស័យកសិឧស្សាហកម្ម (ដំឡូងមី) និងបានផ្សព្វផ្សាយប្រកាសលេខ២៤០ ស្តីពីលក្ខខណ្ឌការងារកុមារក្នុងមុខរបរផលិតកម្មដំឡូងមី ជូនដល់មន្ត្រីពាក់ព័ន្ធនៅស្រុករតនមណ្ឌលចំនួន **០២**លើក មានអ្នកចូលរួមសរុប **៤៣**នាក់ ស្រី **០៨**នាក់។ ៣-ចុះអធិការកិច្ចនៅតាមសិប្បកម្មផលិតឡឥដ្ឋសរុបចំនួន ១៦ ឡឥដ្ឋ ដើម្បីទប់ស្កាត់ និងដកហូតកុមារក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ មានកម្មករនិយោជិកសរុបចំនួន **២៤៤**នាក់ ស្រីចំនួន **១៥៤** នាក់ ក្នុងនោះ កុមារក្នុងបន្ទុក ចំនួន **៨១**នាក់ ស្រី **៤២**នាក់ តែពុំបានរកឃើញនូវការប្រើប្រាស់ពលកម្មកុមារទេ។

▪ **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយស្នងការដ្ឋាននគរបាល និងកងរាជអាវុធហត្ថ៖ **១**-ចុះតាមដាន និងបានធ្វើការផ្សព្វផ្សាយអំពីប្រកាសពាក់ព័ន្ធនឹងពលកម្មកុមារ ក្នុងវិស័យកសិកម្ម(ដំឡូងមី) ដល់អាណាព្យាបាល និងកុមារ នៅស្រុកអង្គរជុំ បានចំនួន **០១**លើក មានអ្នកចូលរួមសរុប **៥០**នាក់(ស្រី **២២**នាក់)។ **២**-បានកំណត់នីតិវិធីក្នុងការទប់ស្កាត់ និងដកហូតកុមារក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ នៅតាមសហគ្រាសអាជីវកម្មផលិតឥដ្ឋ និងបានចុះតាមដាន ស្រង់ស្ថិតិ កម្មករ និងកុមារ ដែលស្នាក់ជាមួយឪពុកម្តាយនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ដោយបានផ្សព្វផ្សាយបន្ថែមអំពីកម្រងប្រកាសទាំង១៣ ពាក់ព័ន្ធនឹងទម្រង់ពលកម្ម តាមសេចក្តីណែនាំលេខ០៥៦/១៩ ក.ប/ស.ណ.ន.ខ.ល ស្តីពីការហាមក្មេងចូលទៅក្នុងបរិវេណឡៃ្សប្រវាក់ផលិតកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្មដល់ម្ចាស់អាជីវកម្ម អាណាព្យាបាល និងកុមារ បានចំនួន **០៤**លើក ដែលមានអ្នកចូលរួមសរុប **១៤៨**នាក់ (ស្រី **៨៣**នាក់)។

▪ **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍សរុបចំនួន **១.១៣៣**នាក់។

- **ខេត្តរតនគិរី៖** មន្ទីរអប់រំ យុវជន និងកីឡា បានចុះពង្រឹងការងារក្រុមប្រឹក្សាកុមារកម្ពុជា និងបានធ្វើការផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញមនុស្ស ការរំលោភបំពាននានាលើកុមារ ដល់លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មានអ្នកចូលរួមសរុប **៥៥**នាក់។
- **ខេត្តមណ្ឌលគិរី៖** បានចុះអធិការកិច្ច ត្រួតពិនិត្យ និងស្រង់ស្ថិតិនៅតាមរីស៊តនានាចំនួន ១៩រីស៊តនៅជុំវិញខេត្ត ចំនួន **២៣**កន្លែង ដើម្បីផ្សព្វផ្សាយច្បាប់ការងារ ស្តីពីការទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរផ្សេងៗដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ ដែលមានកម្មករ និយោជកចូលរួមចំនួន **២៥១**នាក់( ស្រី **៩១**នាក់ )។
- **ខេត្តពោធិ៍សាត់៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយប្រតិភូក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះអធិការកិច្ច ត្រួតពិនិត្យដើម្បីផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់ពលកម្មកុមារក្នុងវិស័យឡូតដ្ឋ នៅស្រុកបាកាន និងវិស័យកសិកម្មនៅស្រុកវាលវែង។

### ៤. ការលើកកម្ពស់ជីវភាព

ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈគម្រោងឥណទានជនបទ ដែលដឹកនាំ និងត្រួតពិនិត្យដោយនាយកដ្ឋានសេដ្ឋកិច្ចជនបទ ដែលកំពុងអនុវត្តផ្ទាល់ដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត សហការជាមួយដៃគូ និងសកម្មភាពការងារឥណទាន ដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានចំនួន ៣.៦៦៦.៣៤២.៩៧៥រៀល មានអ្នកខ្ចីសរុបចំនួន ៣.១៦១នាក់ (ស្រី ២.៤០០នាក់) នៅភូមិគោលដៅចំនួន ១៧៩ភូមិ ៦៧ឃុំ ៣០ស្រុក ក្នុងខេត្តគោលដៅចំនួន ១៤ខេត្ត។ បានជួយផ្តល់នូវជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ តាមរយៈវគ្គបណ្តុះបណ្តាលចិញ្ចឹមត្រី មាន់ ជ្រូក បណ្តុះផ្សិត ដាំដំណាំគ្រួសារ អនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកជនបទ កម្មវិធីថែទាំសុខភាព និងអនាម័យជនបទ កម្មវិធីអភិវឌ្ឍផ្លូវជនបទ ៗ ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ) ការអភិវឌ្ឍភូមិចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ ការបណ្តុះបណ្តាលជំនាញមូលដ្ឋានក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជពលរដ្ឋនៅជនបទ ដើម្បីកាត់បន្ថយប្រជាពលរដ្ឋចំណាកស្រុក។



## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

#### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ( ថ្ងៃទី ០១ ខែមករា ដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២ )

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១៦៦**ករណី( ធៀបនឹង ឆ្នាំ២០២១ មានចំនួន **៣៥៩**ករណី ថយចុះចំនួន **១៩៣**ករណី ) ស្មើនឹង **៥៥,៧៦%** ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **២០២**នាក់/**៥៣៨**នាក់ ( ស្រី **២៧**នាក់ ) អនីតិជន **២០**នាក់។ ក្នុងនោះជនសង្ស័យបរទេសចំនួន **៣៣**នាក់( ស្រី **០២**នាក់ ) មាន **០៤**សញ្ជាតិ គឺជនជាតិចិន **២២**នាក់ ជនជាតិថៃ **០១**នាក់ វៀតណាម **០៧**នាក់ អាឡឺម៉ង់ **០១**នាក់ និងជនជាតិបង់ក្លាដេស **០២**នាក់។

- សង្គ្រោះជនរងគ្រោះ ចំនួន **៣៥៨**នាក់/**១.៥៧៧**នាក់(ស្រី **២៦៥**នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ **១៣៨**នាក់ អាយុ១៥-១៧ឆ្នាំ **៣៧**នាក់ និងអាយុពី១៨ឆ្នាំឡើង **១៨៣**នាក់(ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **៨០**នាក់(ស្រី **៦៣**នាក់) និងប្រគល់ឱ្យគ្រួសារ **២៧៨**នាក់(ស្រី **១៩៩**នាក់) ក្នុងនោះចែកជា៖

### ១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន **៣៦**ករណី/**២៣៥**ករណី(ថយចុះ **១៩៩**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **៥៣**នាក់(ស្រី **០៦**នាក់) អនីតិជន **០១**នាក់ និងជនបរទេស **២៣**នាក់ មាន ០៤សញ្ជាតិ មានជនជាតិចិន ១៥នាក់ វៀតណាម ០៦នាក់ ជនជាតិថៃ ០១នាក់ និងបង់ក្លាដេស ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន **១៣៣**នាក់(ស្រី **៥៧**នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ **១៤**នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ១១៣នាក់ ប្រគល់ឱ្យមន្ទីរសង្គមកិច្ចចំនួន **៣២**នាក់(ស្រី **១៦**នាក់) និងប្រគល់ឱ្យគ្រួសារ **១០១**នាក់(ស្រី **៤១**នាក់)។

### ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន **១៣០**ករណី/**១២៤**ករណី(កើន **០៦**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១៤៩**នាក់(ស្រី **២១**នាក់) អនីតិជន **១៩**នាក់ និងជនបរទេស **១០**នាក់(ស្រី **០២**នាក់) មាន **០៣**សញ្ជាតិ៖ ជនជាតិបង់ក្លាដេស **០១**នាក់ ចិន **០៧**នាក់ វៀតណាម **០១**នាក់ និងអាលឺម៉ង់ **០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **២២៥**នាក់(ស្រី **២០៨**នាក់) មាន៖ អាយុក្រោម១៥ឆ្នាំ **១២៤**នាក់ អាយុ១៥-១៧ឆ្នាំ **៣១**នាក់ និងអាយុ១៨ឆ្នាំឡើង **៧០**នាក់(ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **៤៨**នាក់(ស្រី **៤៧**នាក់) និងប្រគល់ឱ្យគ្រួសារ **១៧៧**នាក់(ស្រី **១៦១**នាក់)។




➢ **មានតារាងលម្អិតនៅក្នុង(ឧបសម្ព័ន្ធ ១)**

**<u>ដោយឡែក</u>** ការដាក់ចេញនូវ ផែនការប្រតិបត្តិការបង្កើនការបង្ក្រាបអំពើជួញដូរមនុស្ស គ្រប់ទម្រង់ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ក្នុងខណៈបទល្មើសដែលបានកើតឡើងថ្មីៗក្នុងទឹកដីកម្ពុជា ។ ក្រុមសមត្ថកិច្ច ក្រោមការដឹកនាំផ្ទាល់ដោយ អគ្គស្នងការនគរបាលជាតិ បានចេញប្រតិបត្តិការយ៉ាងសកម្ម តាមការទទួលនូវបណ្តឹង និងសេចក្តីរាយការណ៍ យ៉ាងទូលំទូលាយ ក្នុងគេហទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម **ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**ដោយផ្ទាល់ គេហទំព័រ និងទូរស័ព្ទទាន់ហេតុការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ គេហទំព័ររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ជាដើម និងបានបង្ក្រាបបទល្មើសបានទាន់សភាពការណ៍ ធ្វើឱ្យបទល្មើសបានថយចុះ ស្ទើរទាំងស្រុង។

ជាលទ្ធផល គិតពី១៨ ខែសីហា ដល់ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០២២ សមត្ថកិច្ច បានរកឃើញ ជនបរទេស **៨៧១នាក់ មកពី ១២ប្រទេស** ដែលក្នុងនោះ **មាន១៦២នាក់** ត្រូវបានកំណត់អត្តសញ្ញាណរកឃើញថា

ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងតាមរយៈការរត់ពន្ធមនុស្ស ហើយ ៨០នាក់ទៀត ត្រូវបានកំណត់ថា ជាជនសង្ស័យប្រព្រឹត្តបទល្មើស ដែលត្រូវបានឃាត់ខ្លួន បញ្ជូនទៅតុលាការ។

## ២. កិច្ចការយុត្តិធម៌

### ២.១. ចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារជំនាញកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

**១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖**

សំណុំរឿងសរុបមានចំនួន **៣១៩** (ក្នុងនោះសំណុំរឿងចាស់មានចំនួន **៣៥**)

-**ជនរងគ្រោះ** សរុបចំនួន **៥៦៧** នាក់(ស្រី **៣០៦**នាក់) ក្នុងនោះអនីតិជន **៣៥៤**នាក់ (ស្រី **២២៦**នាក់) និងជនបរទេស **៤៩**នាក់(ស្រី **១២**នាក់)។

-**ជនល្មើស** សរុបមានចំនួន **៦១៧** នាក់ (ស្រី **៨៨**នាក់) ក្នុងនោះអនីតិជន **១៩**នាក់(ស្រី គ្មាន) ជនបរទេស **១៤៦**នាក់(ស្រី**០៩**នាក់) រួមទាំងអញ្ញាតជន ០៤នាក់។

❖ **សំណុំរឿងចាត់ការរួច៖ ២៧០ សំណុំរឿង** មានដូចជា៖ បញ្ជូនទៅស៊ើបសួរ **២៤២**សំណុំរឿង បញ្ជូនរឿងទៅជម្រះ **០២**សំណុំរឿង នីតិវិធីបង្ហាញខ្លួនភ្លាម(**គ្មាន**) តម្កល់រឿងទុកឥតចាត់ការ **២៥**សំណុំរឿង បញ្ចូលសំណុំរឿង**០១** ផ្ទេរសមត្ថកិច្ច(**គ្មាន**) និងកំពុងចាត់ការ **៤៩**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោម៖

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនល្មើស | | | | | | | សំណុំរឿងចាត់ការរួច | | | | | រឿងកំពុងចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | អញ្ញាតជន | បញ្ជូនទៅស៊ើបសួរ | បញ្ជូនរឿងទៅជម្រះ | នីតិវិធីបង្ហាញខ្លួនភ្លាម | តម្កល់រឿងទុកឥតចាត់ការ | បញ្ចូលសំណុំរឿង | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | | |
| ៣១៩ | ៩៦ | ៦៨ | ១២៨ | ២២៦ | ៣៧ | ១២ | ៣៦៩ | ៧៩ | ១៩ | ០ | ១៣៧ | ០៩ | ០៤ | ២៤២ | ០២ | ០ | ២៥ | ០១ | ៤៩ |
| សរុប | ១៦៤ | | ៣៥៤ | | ៤៩ | | ៤៤៨ | | ១៩ | | ១៤៦ | | ០៤ | | | | | | |
| សរុបរួម | ៥៦៧ នាក់ | | | | | | ៦១៧ នាក់ (រួមទាំងអញ្ញាតជន ០៤នាក់) | | | | | | | ២៧០ សំណុំរឿង | | | | | ៤៩ សំណុំរឿង |

**២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត៖**

សរុបមានចំនួន **៣៧០**សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់មាន **១៤៩**)

- **ជនរងគ្រោះ** ចំនួន **៣០៨**នាក់(ស្រី **២២២**នាក់) ក្នុងនោះអនីតិជន **១៦៤**នាក់ (ស្រី **១៤៥**នាក់) និងជនបរទេស **៥៧**នាក់(ស្រី **១៧**នាក់) ។

-**ជនត្រូវចោទ** ចំនួន **៦៦៤**នាក់ (ស្រី **៦៩**នាក់) ក្នុងនោះអនីតិជន **៥៣**នាក់ (ស្រី **០៣**នាក់) ជនបរទេស **១១១**នាក់(ស្រី ០៥នាក់) រួមទាំងអញ្ញាតជន០៩នាក់ ។

❖ **បានធ្វើចំណាត់ការដោយ៖** បញ្ជូនរឿងទៅជម្រះចំនួន **២១៣**សំណុំរឿង លើកលែងចោទ ០១សំណុំរឿង ផ្ទេរសមត្ថកិច្ច(គ្មាន) បណ្តឹងឧទ្ធរណ៍(គ្មាន) សរុប **២១៤សំណុំរឿង** និងកំពុងចាត់ការ**១៥៦ សំណុំរឿង**។ ដូចមានតារាងលម្អិតខាងក្រោម៖

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនត្រូវចោទ | | | | | | | ប្រភេទចំណាត់ការរួច | | | បណ្តឹងឧទ្ធរណ៍ | កំពុងចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | អញ្ញាតជន | បញ្ជូនរឿងទៅជំនុំជម្រះ | លើកលែង | ផ្ទេរសមត្ថកិច្ច | | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | |
| ៣៧០ | ២៧ | ៦០ | ១៩ | ១៤៥ | ៤០ | ១៧ | ៤៣០ | ៦១ | ៥០ | ០៣ | ១០៦ | ០៥ | ០៩ | ២១៣ | ០១ | ០ | ០ | ១៥៦ |
| សរុប | ៨៧ | | ១៦៤ | | ៥៧ | | ៤៩១ | | ៥៣ | | ១១១ | | ០៩ | | | | | |
| សរុបរួម | ៣០៨ នាក់ | | | | | | ៦៦៤ នាក់ (រួមទាំងអញ្ញាតជន ០៩នាក់) | | | | | | | ២១៤ សំណុំរឿង | | | គ្មាន | ១៥៦ សំណុំរឿង |

### ៣. ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត៖

សរុបមានចំនួន **៤១៨**សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់ **១៤៦**)

-**ជនរងគ្រោះ** ចំនួន **៣៥៦**នាក់ (ស្រី **២៤៨**នាក់) ក្នុងនោះអនីតិជន **២២៣**នាក់(ស្រី **១៨៨**នាក់) និងជនបរទេស **០៩**នាក់(ស្រី **០១**នាក់)។

- **ជនជាប់ចោទ និងពិរុទ្ធជន**ចំនួន **៦៤១**នាក់(ស្រី **៥៩**នាក់) ក្នុងនោះអនីតិជន **០៦**នាក់(ស្រី គ្មាន) ជនបរទេស **៣៤**នាក់(ស្រី **០២**នាក់) អញ្ញាតជន **០១**នាក់។

❖ **សំណុំរឿងចាត់ការរួច**: បានជំនុំជម្រះ **២៨៦សំណុំរឿង** ផ្ទេរសមត្ថកិច្ច**គ្មាន** **ប្រកាសសាលក្រមឱ្យ**: រួចផុតពីបទចោទ **០៤**សំណុំរឿង មនុស្សចំនួន **០៣**នាក់(ស្រី **០១**នាក់), **ផ្តន្ទាទោសដោយ**: ពិន័យជាប្រាក់ **៤៥** សំណុំរឿង ដាក់ពន្ធនាគារ **២៤២**សំណុំរឿង មនុស្សចំនួន **២៧៥**នាក់(ស្រី **១៦**នាក់), **ទោសព្យួរ**: ព្យួរទោសសាកល្បង **០២**សំណុំរឿង ព្យួរទោសធម្មតា**គ្មាន** មនុស្សចំនួន **០៤**នាក់(ស្រី០៣នាក់), **បណ្តឹងឧបាស្រ័យ**: បណ្តឹងជំទាស់**គ្មាន** បណ្តឹងឧទ្ធរណ៍**គ្មាន** សរុបរឿងចាត់ការរួច **២៨៦**សំណុំរឿង និងកំពុងចាត់ការ **១៣១**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោម៖

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនជាប់ចោទ | | | | | | | ប្រភេទចំណាត់ការរួច | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | អញ្ញាតជន | បញ្ជូនរឿងទៅជំនុំជម្រះ | ផ្ទេរសមត្ថកិច្ច | ប្រកាសសាលក្រម | | | | | | | | | | | បណ្តឹងឧបាស្រ័យ | | សរុបចាត់ការរួច | រឿងកំពុងចាត់ការ |
| | | | | | | | | | | | | | | | | រួចផុតបទចោទ | | | ផ្តន្ទាទោស | | | | ទោសព្យួរ | | | | | | | |
| | | | | | | | | | | | | | | | | | ចំនួនមនុស្ស | | | | ចំនួនមនុស្ស | | | | ចំនួនមនុស្ស | | | | | |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | សំណុំរឿង | សរុប | ស្រី | ពិន័យជាប្រាក់ | ដាក់ពន្ធនាគារ | សរុប | ស្រី | ទោសព្យួរសាកល្បង | ទោសព្យួរធម្មតា | សរុប | ស្រី | បណ្តឹងជំទាស់ | បណ្តឹងឧទ្ធរណ៍ | | |
| សរុប ៤១៨ | ៦៥ | ៥៩ | ៣៥ | ១៨៨ | ០៨ | ០១ | ៥៤៤ | ៥៧ | ០៦ | ០ | ៣២ | ០២ | ០១ | ២៨៦ | ០ | ០៤ | ០៣ | ០១ | ៤៥ | ២៤២ | ២៧៥ | ១៦ | ០២ | ០ | ០៤ | ០៣ | ០ | ០ | ២៨៦ | ១៣១ |
| | ១២៤ | | ២២៣ | | ០៩ | | ៦០១ | | ០៦ | | ៣៤ | | ០១ | | | | | | | | | | | | | | | | ៤១៨ | |
| | ៣៥៦ នាក់ | | | | | | ៦៤១ នាក់ (រួមទាំងអញ្ញាតជន០១នាក់) | | | | | | | | | | | | | | | | | | | | | | ករណី | |

ក្រាហ្វិកប្រៀបធៀបរបស់ចៅក្រមជំនុំជម្រះ ឆ្នាំ២០២១-២០២២




➢ (មានតារាងលំអិតនៅក្នុងឧបសម្ព័ន្ធ ២)

### ២.១.១. ករណីពពោះជំនួស

ចំពោះករណីស្ត្រីពពោះជំនួស ០២នាក់ ដែលត្រូវបានឃាត់ខ្លួនដោយសមត្ថកិច្ចវៀតណាម ឆ្នាំ ២០២១ ក្នុងឆ្នាំ២០២២ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

### ២.២. ដំណោះស្រាយនៃការវិវាទការងាររវាងពលករទៅធ្វើការនៅក្រៅប្រទេស និងក្រុមហ៊ុនជ្រើសរើសពលករ

- **ខេត្តកំពង់ចាម មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន៖**
  - សហការជាមួយការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិង ការពារអនីតិជន និង ក្រុមការងារទេសន្តរប្រវេសន៍នៃក្រសួងការងារ ជួយអន្តរាគមន៍នាំយកពលការិនីចំនួន ០១នាក់ វិលត្រលប់ពីប្រទេសម៉ាឡេស៊ីវិញ ព្រមទាំងបានទទួលសំណង ចំនួន ១,៥០០ ដុល្លារអាមេរិក។
  - ជួយសម្របសម្រួលករណីពលការិនីម្នាក់ស្នើសុំឱ្យជួយអន្តរាគមន៍ជាមួយ ក្រុមហ៊ុនជ្រើសរើសពលករ និងបានទាមទារសំណង ៦៥០ដុល្លារត្រលប់មកវិញចំពោះការបង់ប្រាក់ហើយមិនទាន់បានបញ្ជូនទៅធ្វើការនៅប្រទេសជប៉ុន តែករណីនេះក្រុមហ៊ុនបានយល់ព្រមបញ្ជូនទៅធ្វើការងារខាងកសិកម្មនៅប្រទេសជប៉ុន នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២។

- **ខេត្តសៀមរាប៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ដោយបានធ្វើការសម្របសម្រួលផ្សះផ្សាវិវាទការងារបុគ្គល ចំនួន ២០សហគ្រាស ស្មើនឹង៥១ករណី ពាក់ព័ន្ធនឹងបញ្ហាប្រាក់ឈ្នួល ការបញ្ឈប់ពីការងារ និងបញ្ហាផ្សេងៗ ដែលមានកម្មករនិយោជិតពាក់ព័ន្ធនឹងវិវាទការងារចំនួន ៥១នាក់ លើកម្មករនិយោជិតសរុប ចំនួន ៤៩២នាក់ និងវិវាទការងាររួម ចំនួន ០៣សហគ្រាស ស្មើនឹង០៣ករណី ពាក់ព័ន្ធនឹងបញ្ហាផ្សេងៗ ដែលមានកម្មករនិយោជិតពាក់ព័ន្ធនឹងវិវាទការងារចំនួន ១៣០នាក់ លើកម្មករនិយោជិតសរុប ២០៩នាក់។

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្អាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន( ផ្លូវគោក និងផ្លូវអាកាស )ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

### ១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់ (ផ្លូវគោក និងផ្លូវអាកាស)

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ទីរសង្គមកិច្ចរាជធានី-

**ខេត្ត** ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន **១០០.៣៦៧**នាក់(ប្រុស **៤៧.១៣៣**នាក់ ស្រី **៤១.១៨៤**នាក់ កុមារា **៦.៤២២**នាក់ កុមារី **៥.៩០២**នាក់)សកម្មភាពមានដូចជា៖

**១-នាយកដ្ឋានគាំពារជនរងគ្រោះ** នៃក្រសួង ស.អ.យ បានទទួល ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាតាមផ្លូវអាកាស សរុប **២៨៨**នាក់(ប្រុស **៦១**នាក់ ស្រី **២០៣**នាក់ កុមារា **០៣**នាក់ កុមារី **២១**នាក់) មកពីប្រទេសចិន **១៩៨**នាក់ ម៉ាឡេស៊ី **៥២**នាក់ វៀតណាម **០៥**នាក់ ថៃ **៣២**នាក់ និងនីហ្សេរីយ៉ា **០១**នាក់ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ **១៧០**នាក់ ជួញដូរកម្លាំងពលកម្ម **៤៤**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម **២៤**នាក់ ជួញដូរផ្លូវភេទ **០៤**នាក់ ងាយរងគ្រោះ **៤៥**នាក់ និងសង្ស័យថាជាមេខ្យល់ **០១**នាក់) បានសម្ភាសកំណត់អត្តសញ្ញាណរួចបញ្ជូន ទៅទទួលសេវាបន្តនៅអង្គការដៃគូ។

**២-មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពលករចំណាកស្រុកពីប្រទេសថៃតាមផ្លូវគោកចំនួន **៩៧.០៥២**នាក់ (ប្រុស **៤៥.៣៧៦**នាក់ ស្រី **៣៩.៦៥០**នាក់ កុមារា **៦.២៦២**នាក់ កុមារី **៥.៧៦៤**នាក់) បានសម្ភាសកំណត់អត្តសញ្ញាណកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ ចំនួន **២៩**នាក់ (ប្រុស **២៥**នាក់ ស្រី **០៣**នាក់ កុមារី **០១**នាក់) ក្នុងនោះរកឃើញ៖ ករណីជួញដូរកម្លាំងពលកម្ម **២៨**នាក់ ជួញដូរផ្លូវភេទ **០១នាក់** និងងាយរងគ្រោះ **៨៨៦**នាក់ (ប្រុស **៤៩២**នាក់ ស្រី **២៦៤**នាក់ កុមារា **៦៥**នាក់ កុមារី **៦៥**នាក់) និងកុមារមិនមានមនុស្សអមដំណើរមកជាមួយដោយផ្តល់ការស្នាក់នៅរយៈពេលខ្លីចំនួន **៤៩**នាក់(កុមារា **២៥**នាក់ កុមារី**២៤**នាក់) មុនពេលបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ និងបញ្ជូនទៅសហគមន៍វិញ។

**៣-បានទទួល** ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សជាជនជាតិបរទេស ពីកម្លាំងនគរបាលនៅក្នុងស្រុកសរុបចំនួន **២៤**នាក់ (ប្រុស **១៧**នាក់ ស្រី **០៧**នាក់) ក្នុងនោះមានដូចជា ជាជនជាតិភូមា **០៩**នាក់(ប្រុស) និង ជនជាតិអេស្ប៉ុប **០១**នាក់(ស្រី) និងជនជាតិខ្មែរ **១៤**នាក់ មានករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម **១០**នាក់ និងងាយរងគ្រោះ **១៤**នាក់ ក៏បានបញ្ជូនបន្តទៅទទួលសេវាបណ្តោះអាសន្ន មុនពេលធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសកំណើតវិញ នៅអង្គការដៃគូមានៈ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) អង្គការការីតាសកម្ពុជា(Caritas Cambodia) និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)។

**៤-មណ្ឌលទទួលពលករកំរៀង របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** (គិតចាប់ពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០២២ ដល់ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២) បានទទួលពលករខ្មែរដែលវិលត្រលប់សរុបចំនួន **៣.០០១**នាក់ (ប្រុស **១.៦៧៩**នាក់ ស្រី **១.៣២២**នាក់) ក្នុងនោះមាន៖ កុមាររួមដំណើរ **២៧៤**នាក់ (កុមារា **១៥៧**នាក់ កុមារី **១១៧**នាក់) ស្ត្រីមានកូនតូច **១៤៦**នាក់ ស្ត្រីមានផ្ទៃពោះ **១០៤**នាក់ និងជនពិការ **២៨**នាក់ (ស្រី **០៧**នាក់)។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** ស្នងការដ្ឋាននគរបាលខេត្ត ចំនួន ០៦ បានទទួល និងសម្ភាសពលករខ្មែរដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ក្នុងនោះមាន(ច្រកចាំយាម ច្រកធម្មជាតិ ច្រកដាំ ច្រកអូរស្មាច់ ច្រកអូរបីជាន់ ច្រកម៉ាឡៃ ច្រកបឹងត្រកួន និងច្រកអន្តរជាតិប៉ោយប៉ែត) និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម បានចំនួន **៤៥២**លើក សរុបមនុស្សចំនួន **២៩.៤៨៧**នាក់(ស្រី **១០.០៥១**នាក់ អនីតិជន **៣.៧១៦**នាក់) ក្នុងនោះមាន៖
  - **ខេត្តបន្ទាយមានជ័យ** ចំនួន **២១៥**លើក មនុស្សចំនួន **២៣.០៩១**នាក់ (ស្រី **៧.៧៥១**នាក់ អនីតិជន **២.៨២៩**នាក់)។
  - **ខេត្តបាត់ដំបង** ចំនួន **០៥**លើក មនុស្សចំនួន **១៥០**នាក់ (ស្រី **៥៧**នាក់ អនីតិជន **១៣**នាក់)។

- **ខេត្តកោះកុង** ចំនួន **២០២**លើក មនុស្សចំនួន **២.៤៨១**នាក់(ស្រី **៧៧៦**នាក់ អនីតិជន **៤០៩**នាក់)។
- **ខេត្តប៉ៃលិន** ចំនួន **១៥**លើក មនុស្សចំនួន **៣.៦៨៩**នាក់ (ស្រី**១.៤២៥**នាក់ អនីតិជន **៤៥៤**នាក់)។
- **ខេត្តឧត្តរមានជ័យ** ចំនួន **១០**លើក មនុស្សចំនួន **៤៤**នាក់(ស្រី**២២**នាក់ កុមារី **០១**នាក់)។
- **ខេត្តស្វាយរៀង** ចំនួន **០៥**លើក មនុស្សចំនួន **៣២**នាក់ (ស្រី **២០**នាក់ កុមារា **០៣**នាក់ កុមារី **០៨**នាក់)។

## ២. កិច្ចការពារជនរងគ្រោះ ការផ្ដល់សេវា និងការស្ដារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

### ២.១. កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវា

- នៅក្នុងឆ្នាំ២០២២ **គ.ជ.ប.ជ និង គ.រ.ប.ជ/គ.ខ.ប.ជ** បានសហការជាមួយអង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ បានផ្ដល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយរៀបចំបណ្ដឹងទាមទារសំណង ដល់ជនរងគ្រោះចំនួន **០៤**នាក់ សរុបជាទឹកប្រាក់ទទួលបានសំណងចំនួន **៦.៨០០ដុល្លារ** (ប្រាំមួយពាន់ប្រាំបីរយដុល្លារសហរដ្ឋអាមេរិកគត់) និង**២២.០០០.០០០**រៀល(ម្ភៃពីរលានរៀលគត់) ដែលអង្គការដៃគូសហការគាំទ្រ និងផ្ដល់សេវាផ្នែកច្បាប់រួមមាន៖
    - **អង្គការសកម្មភាពដើម្បីកុមារ (APLE)** ជនរងគ្រោះ (ករណីរូបភាព និងសម្ភារអាសអាភាសនៃកុមារ) ចំនួន **០១**នាក់ ទទួលសាលក្រមប្រកាសសម្រេចផ្ដល់ប្រាក់សំណងចំនួន **៣.៨០០ដុល្លារ** (បីពាន់ប្រាំបីរយដុល្លារសហរដ្ឋអាមេរិកគត់)។
    - **អង្គការចាប់ដៃ** ជនរងគ្រោះ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធនធ្ទុះ/បង្ខំ) ចំនួន **០១**នាក់ ទទួលសាលក្រមប្រកាសសម្រេចផ្ដល់ប្រាក់សំណងចំនួន **៣.០០០ដុល្លារ**(បីពាន់ដុល្លារសហរដ្ឋអាមេរិកគត់)។
    - **អង្គការក្ដីសង្ឃឹម និងយុត្តិធម៌** ជនរងគ្រោះ(ករណីសញ្ជារកម្ម) ចំនួន **០២**នាក់ទទួលសាលក្រមប្រកាសសម្រេចផ្ដល់ប្រាក់សំណងសរុបចំនួន **២២.០០០.០០០**រៀល(ម្ភៃពីរលានរៀលគត់)។

### ២.២. ការស្ដារនីតិសម្បទាដល់ជនរងគ្រោះ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅស្ដារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូ សរុប **២.២១៨**នាក់(ប្រុស **៣៦**នាក់ ស្រី **៦៧៤**នាក់ កុមារា **៥៩៨**នាក់ កុមារី **៩០៧**នាក់) ក្នុងនោះករណី(អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ **៤៧**នាក់ ជួញដូរកម្លាំងពលកម្ម **០៨**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម **១៩៤**នាក់ ជួញដូរផ្លូវភេទ **៥៤៧**នាក់ រំលោភបំពានផ្លូវភេទ **៥៦១**នាក់ សញ្ជារកម្ម **១៨**នាក់ កេងប្រវ័ញ្ចផ្លូវភេទ **០៥**នាក់ ជួញដូរប្រព័ន្ធអនឡាញ **០១**នាក់ និងងាយរងគ្រោះ **៨៣៥**នាក់)។ ក្នុងនោះបញ្ជូនទៅមន្ទីរ ស.អ.យ រាជធានី-ខេត្ត ចំនួន **៤៩**នាក់ និងអង្គការដៃគូចំនួន **២.១៦៩**នាក់។

## ៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប **១០១**នាក់(ប្រុស **១៦**នាក់ ស្រី **៦៦**នាក់ កុមារា **០៤**នាក់ កុមារី **១៥**នាក់) ក្នុងនោះករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ **៣៣**នាក់ ជួញដូរកម្លាំងពលកម្ម **២៨**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម **០៩**នាក់ ជួញដូរផ្លូវភេទ **២៧**នាក់ រំលោភបំពានផ្លូវភេទ **០១**នាក់ កេង

ប្រព័ន្ធផ្លូវភេទ ០១នាក់ សញ្ញារកម្ម ០១នាក់ និងងាយរងគ្រោះ ០១នាក់ ដោយមានការចូលរួមសហការគាំទ្រពីអង្គការដៃគូ។

➢ យោងតាមដីកាសម្រេចដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នូវជនត្រូវចោទជាស្ត្រីពពោះជំនួសចំនួន០២នាក់ ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជនយុវនិតិសម្បទា បានធ្វើសមាហរណកម្មស្ត្រីទាំងពីរនាក់នេះ រួមទាំងកូនចំនួន៤នាក់ (ភ្លោះ២គូរ)ដែលកើតពីការពពោះជំនួស ទៅថៃរក្សានៅសហគមន៍វិញ ។

➢ និងត្រូវបានធ្វើមាតុភូមិនិវត្តន៍ជនជាតិភូមាទៅប្រទេសដើមវិញសរុបចំនួន ០៩នាក់ (បុរស) ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយមានកិច្ចសហការចូលរួមពីអ្នកពាក់ព័ន្ធ និងអង្គការដៃគូ ដូចជា(អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) និងអង្គការការីតាសកម្ពុជា)។

➢ បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ៨០នាក់(ស្ត្រី ៦៤នាក់ កុមារី ០៦នាក់) មាន: (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ១០នាក់ ជួញដូរផ្លូវភេទ ៤៩នាក់ រំលោភបំពានផ្លូវភេទ ០៣នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ១៨នាក់ ក្នុងនោះនៅមន្ទីរ ស.អ.យ ខេត្តបាត់ដំបង ០១នាក់មន្ទីរ ស.អ.យ ខេត្តកំពត ០១នាក់ អង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា ០២នាក់ អង្គការក្តីសង្ឃឹម និងយុត្តិធម៌ ០១នាក់ អង្គការតេនៈអ៊ុនជើណេសិនណល ៦៥នាក់។

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** យោងតាមផែនការលេខ **១៤៣/២២ផ.ក** ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផែនការលេខ **១៤៤/២២ផ.ក** ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ របស់ក្រុមការងារអនុវត្តច្បាប់ គណៈបញ្ជាការដឹកនាំក្រុមប្រតិបត្តិការ អគ្គនាយកដ្ឋានបានបណ្តេញចេញជនបរទេសល្មើសច្បាប់ ចំនួន **២.៤៥៥**នាក់(ស្រី **៣៤៦**នាក់) មាន ២៨សញ្ជាតិ ក្នុងនោះ ១១សញ្ជាតិមាន ចិន **១.០២៨**នាក់ វៀតណាម **៨៨៣**នាក់, ថៃ **១៧៧**នាក់, ម៉ាឡេស៊ី **១១២**នាក់, ចិនតៃវ៉ាន់ **៩៥**នាក់ ឥណ្ឌូនេស៊ី **៤៩**នាក់, ឥណ្ឌា **៤១**នាក់,បង់ក្លាដេស **៣៣**នាក់, កូរ៉េខាងត្បូង **១៣**នាក់, នីហ្សេរីយ៉ា **១២**នាក់, ហ្វីលីពីន **១២**នាក់ និង ១៧ សញ្ជាតិទៀតមានពី០១នាក់ ដល់០៤នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ជាតិ ក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត(គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយ អង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលចំនួន **៣២៩**វគ្គ មានសិក្ខាកាមចូលរួមចំនួន **១១.៦២១**នាក់ ក្នុងនោះមានស្ត្រី **៥.៣៤៦**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោម៖

| |
|---|
| ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូមានៈ សម្ព័នចាប់ដៃ, សកម្មភាពដើម្បីកុមារ(APLE) ទេសន្តរប្រវេសន៍អន្តរជាតិ(IOM) មូលនិធិអេ២១(A21) មេត្រីអន្តរជាតិ(AIM) វីនរ៉ក់(Winrock) យូនីសេហ្វ(Unicef) UNFPA មូលនិធិហាការអន្តរជាតិ(Hagar International), ASEAN-ACT បេសកកម្មយុត្តិធម៌(IJM) ជីវិតនៅកម្ពុជា(TLC) ម្លប់ឬស្សី ជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី(LSWCW) អង្គការសាម៉ារីតាន់ភឺស ស្ថានទូតបារាំង និងអង្គភាពFBI, HSI បានរៀបចំបើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្តកសាងសមត្ថភាព ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ដល់អ្នកផ្តល់ប្រឹក្សាយោបល់ អ្នកធ្វើការងារនៅមណ្ឌលធនធានពលករទេសន្តរប្រវេសន៍(MRC) គ្រូបង្គោល នាយនគរបាល នៃស្នងការនគរបាលរាជធានី-ខេត្ត អាជ្ញាធរ ក្រុង/ស្រុក/សង្កាត់/ឃុំ/ភូមិ និងមន្ត្រីអធិការកិច្ចការងារ **ស្តីពី៖** ១-ការណែនាំតម្រង់ទិសពេលកម្មុនពេលចេញដំណើរទៅបរទេស។ ២-កម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ៣-ជំនាញទន់ និងការត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារធ្វើ។ ៤-នីតិវិធីនៃការចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម។ ៥-ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកខុសច្បាប់ និងកិច្ចការពារកុមារ។ ៦-កិច្ចការពារជនរងគ្រោះ និងគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី |

នៃការកំណត់អត្តសញ្ញាណរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងការសម្ភាសបែបកោសល្យវិច្ច័យដល់មន្ត្រីជួរមុខថ្នាក់ក្រោមជាតិ។ **៧**-ការគាំទ្រដល់កុមាររងគ្រោះ និងបច្ចេកទេសធ្វើការជាមួយកុមារក្នុងនីតិវិធីព្រហ្មទណ្ឌ និងការឆ្លើយតបបទល្មើសផ្លូវភេទលើកុមារ។ **៨**-សេចក្តីណែនាំអំពីការស៊ើបអង្កេតអំពើកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ។ **៩**-ការគ្រប់គ្រង និងការបញ្ជូនករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅកាន់សេវាគាំទ្រ។ **១០**-ការមិនបង្កហានិភ័យ និងការគ្រប់គ្រងករណីសម្រាប់ពលករនៅតាមភូមិ/ឃុំ/ស្រុក។ **១១**-កិច្ចការពារកុមារ ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដល់ក្រុមអ្នកស្ម័គ្រចិត្ត នៅតាមសហគមន៍។ **១២**-ការកំណត់ និងឆ្លើយតបបែបកុមារមេត្រីទៅនឹងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ **១៣**-កិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារនៅកម្ពុជា។ **១៤**-ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ **១៥**-បទប្បញ្ញត្តិពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ ដើម្បីស្វែងរកការងារប្រកបដោយសុវត្ថិភាព ការជ្រើសរើសប្រកបដោយក្រមសីលធម៌ និងសេវាកម្មដែលឆ្លើយតបនឹងយេនឌ័រ។ ១៦-កិច្ចការពារកុមារ ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការរំលោភបំពាន នៅកន្លែងចត្តាឡីស័ក។

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៧៩ | ២.៧០៦ | ១.០២៦ |
| ក្រសួង ស.អ.យ បានសហការជាមួយអង្គការដៃគូ | ០៧ | ៣២៤ | ១១៩ |
| ក្រសួងកិច្ចការនារី | ០៤ | ១៩៦ | ១៤៨ |
| អគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយអង្គការដៃគូ | ១៨ | ៨៥៦ | ១៦៧ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយអង្គការដៃគូ | ២៣ | ៧៨២ | ២៦១ |
| អង្គការសម្ព័ន្ធចាប់ដៃ សហការជាមួយអង្គការក្តីស្រឡាញ់គ្មានព្រំដែន និងអង្គការ ERIKS | ០២ | ៦៨ | ៣៣ |
| អង្គការមូលនិធិអេ២១(ខេត្តបាត់ដំបង) | ០១ | ៣០ | ០៤ |
| អង្គការសម្ព័ន្ធចាប់ដៃ(ខេត្តត្បូងឃ្មុំ) | ០២ | ៩១ | ២៦ |
| អង្គការសាម៉ារីតាន់ភឺស(ខេត្តបាត់ដំបង) | ១០ | ៣៤៧ | ២៣៦ |
| អង្គការ UNFPA (ខេត្តព្រះវិហារ) | ០១ | ៣៨ | ១៧ |
| អង្គការមូលនិធិហាកា (HAGAR) (ខេត្តសៀមរាប) | ០១ | ២៨ | ១២ |
| អង្គការដៃនដីមនុស្ស-ហូឡង់កម្ពុជា(TDH)(ខេត្តសៀមរាប) | ០១ | ៤៥ | ២៩ |
| អង្គការសកម្មភាពដើម្បីកុមារ(ខេត្តសៀមរាប) | ០៣ | ១២០ | ៤១ |
| អង្គការបន្ទាយស្រី (ខេត្តសៀមរាប) | ០១ | ២០ | ០៩ |
| អង្គការ MOI (ខេត្តសៀមរាប) | ០១ | ២០ | ០៩ |
| អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប) | ០២ | ៨០ | ៤៥ |
| អង្គការ (APLE) | ០១ | ៤៤ | ៣៤ |
| អង្គការ(IJM) (ខេត្តស្វាយរៀង) | ០១ | ១៩ | ០៦ |
| រាជធានីភ្នំពេញ | ០៤ | ១១៤ | ៤៧ |
| ខេត្តបន្ទាយមានជ័យ | ០១ | ១១៦ | ៤៧ |
| ខេត្តបាត់ដំបង | ០១ | ៣២ | ០៣ |
| ខេត្តពោធិ៍សាត់ | ០១ | ៦៨ | ៥៥ |
| ខេត្តកោះកុង | ០១ | ៣៥ | ១៣ |
| ខេត្តសៀមរាប | ១៦ | ៦៣៥ | ២៣៧ |
| ខេត្តព្រះវិហារ | ០៣ | ១៦២ | ៤៥ |
| ខេត្តឧត្តរមានជ័យ | ០១ | ៥៥ | ២៥ |

| | | | |
|---|---|---|---|
| ខេត្តកំពង់ធំ | ០១ | ២៤ | ០៤ |
| ខេត្តស្វាយរៀង | ៨៥ | ១.៦២០ | ៩៥៤ |
| ខេត្តកែប | ០៣ | ១៦៧ | ១០៨ |
| ខេត្តតាកែវ | ០៨ | ៤០៦ | ៣១៦ |
| ខេត្តរតនគីរី | ០៣ | ៦២ | ៣៤ |
| ខេត្តស្ទឹងត្រែង | ០៧ | ២២០ | ១២២ |
| ខេត្តកំពង់ចាម | ០៦ | ៥៦៩ | ២២៤ |
| ខេត្តត្បូងឃ្មុំ | ០៧ | ៦៥៥ | ៣២៣ |
| ខេត្តព្រៃវែង | ០៧ | ៣៨៥ | ៣៣៨ |
| ខេត្តព្រះសីហនុ | ០៧ | ២៣២ | ១២៩ |
| ខេត្តកំពត | ០១ | ៣៥ | ០៧ |
| ខេត្តកំពង់ឆ្នាំង | ០៨ | ២១៥ | ៩៣ |
| សរុប | **៣២៩វគ្គ** | **១១.៦២១នាក់** | **៥.៣៤៦នាក់** |

## ២. សិក្ខាសាលា

ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំសិក្ខាសាលាដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ បានចំនួន **៣៥០**វគ្គ មានសិក្ខាកាមចូលរួមចំនួន **១៧.៥៣៧**នាក់ ក្នុងនោះមានស្ត្រី **១០.០០៣**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ មាន៖ ILO, UNICEF, IOM, Asean-Act, UNDP, PLAN International, Cambodia ACTs, HAGAR , អង្គការមូលនិធិអេ ២១(A21), អង្គការបន្ទាយស្រី, RATANAK International, United Nations, UNODC និងសហភាពអឺរ៉ុប(EU)ប្រចាំនៅកម្ពុជា បានរៀបចំសិក្ខាសាលា ដើម្បីបង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ស្តីពី៖ ១-ផែនការអាជីព និងជ្រើសរើសជំនាញការងារសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ និងនិស្សិតនៅគ្រឹះស្ថានអប់រំ។ **២**-ការចែករំលែកបទពិសោធន៍ពីកម្មវិធី SaverAsia ស្តីពីសេវាឌីជីថលក្នុងការលើកកម្ពស់សុវត្ថិភាពផ្នែកហិរញ្ញវត្ថុ សម្រាប់ពលករទេសន្តរប្រវេសន៍។ **៣**-ការណែនាំសៀវភៅភាសាជប៉ុន អ៊ីរ៉ូដូរី និងតេស្តភាសាជប៉ុន JFT-Basic ក្នុងគម្រោងពលករជំនាញកម្ពុជាទៅប្រទេសជប៉ុន ។ **៤**-ទម្រង់គ្រប់គ្រងជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស តាមសារាចរណ៍ណែនាំ លេខ០០៩។ **៥**-ដំណើរមាតុភូមិនិវត្តន៍ជនរងគ្រោះ និងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស។ **៦**-ការអនុវត្តរបស់កម្ពុជា លើផែនការសកម្មភាពមហាអនុតំបន់មេគង្គ(ខមមីតទី៤) និងការពិគ្រោះយោបល់ថ្នាក់ជាតិលើកទី១ លើការរៀបចំយន្តការបញ្ជូនឆ្លងដែន។ **៧**-សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ **៨**-ការជំរុញការចូលរួមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។ **៩**-ការរៀបចំផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ **១០**-បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។ **១១**-លើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ។ ១២-បិទបញ្ចប់ដំណើរការគម្រោង "បញ្ឈប់ការកេងប្រវ័ញ្ចលើកុមារ តាមរយៈការទទួលបានសេវាសមស្រប"។ **១២**-សិទ្ធិកុមារ និងច្បាប់នានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។ **១៣**-កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

| **សកម្មភាពរៀបចំសិក្ខាសាលា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ** | **ចំនួនលើក** | **ចំនួនអ្នកចូលរួម** | **ចំនួនស្រី** |
|---|---|---|---|
| គ.ជ.ប.ជ សហការជាមួយអង្គការ APLE | ០១ | ៦៥ | ២១ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣១២ | ១៥.៧៣១ | ៩.២៥៧ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការគូ | ០៨ | ២៦៧ | ៩០ |
| ក្រសួងកិច្ចការនារី | ០២ | ៩៦ | ៥២ |
| ក្រសួងទេសចរណ៍ | ០២ | ១១២ | ៤២ |

| | | | |
|---|---|---|---|
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ០១ | ១៥០ | ៤៥ |
| អគ្គលេខាធិការដ្ឋាន នៃគ.ជ.ប.ជ | ០២ | ១០៧ | ២៤ |
| អង្គការ We World (ខេត្តសៀមរាប) | ០១ | ៤៦ | ១៥ |
| អង្គការ PLAN International (ខេត្តសៀមរាប) | ០១ | ៥៧ | ៣៦ |
| អង្គការ (APLE) (ខេត្តសៀមរាប) | ០១ | ៥០ | ២៨ |
| អង្គការវីនរ៉ក់អន្តរជាតិ(ខេត្តសៀមរាប) | ០១ | ៤០ | ២៨ |
| អង្គការ Save the children (ខេត្តកំពង់ចាម) | ០២ | ១៧ | ១០ |
| អង្គការក្ដីសង្ឃឹម និងយុត្តិធម៌(ខេត្តកណ្ដាល) | ០១ | ៤០ | ១១ |
| អង្គការសម្ព័ន្ធចាប់ដៃ | ០១ | ៣៦ | ១៣ |
| ខេត្តបន្ទាយមានជ័យ | ០១ | ៥៦ | ៣៤ |
| ខេត្តបាត់ដំបង សហការជាមួយអង្គការ ASEAN-ACT | ០១ | ១១៦ | ៦២ |
| ខេត្តស្វាយរៀង សហការជាមួយអង្គការហាការ(HAGAR) | ០១ | ៥៤ | ៣៧ |
| ខេត្តកណ្ដាល សហការជាមួយអង្គការហាការ(HAGAR), អង្គការក្ដីសង្ឃឹម និងយុត្តិធម៌ | ០៣ | ១៣៣ | ៥៦ |
| ខេត្តព្រៃវែង សហការជាមួយអង្គការហាការ (HAGAR) និងអង្គការ IOM | ០២ | ៩១ | ៣៥ |
| ខេត្តតាកែវ | ០៣ | ៩០ | ៤១ |
| ខេត្តកំពង់ចាម | ០១ | ១២០ | ៦០ |
| ខេត្តកំពង់ឆ្នាំង | ០១ | ១០ | ០៦ |
| ខេត្តកំពង់ស្ពឺ សហការជាមួយអង្គការហាការ (HAGAR) | ០១ | ៥៣ | ០០ |
| **សរុប** | **៣៥០លើក** | **១៧.៥៣៧នាក់** | **១០.០០៣នាក់** |

## ខ. កិច្ចប្រជុំ សន្និសីទ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

#### ១.១. កិច្ចប្រជុំក្នុងប្រទេស

- **ថ្នាក់ជាតិ**

សមាជិកនៃគ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំកិច្ចប្រជុំដើម្បីពង្រឹងសមត្ថភាព ដល់មន្ត្រីពាក់ព័ន្ធ សរុបចំនួន **៤៦១**លើក មានអ្នកចូលរួមចំនួន **១៣.២៦១**នាក់ ក្នុងនោះមានស្ត្រី **៦.២៧៣**នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| |
|---|
| ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ មាន៖ CPU, South Asia, IOM, Asean-Act, EU បានរៀបចំកិច្ចប្រជុំពិភាក្សាដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ដើម្បីពង្រឹងសមត្ថភាពការងារដល់មន្ត្រីពាក់ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ដីពី៖ ១-ការកែសម្រួលខ្លឹមសាររបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២។ ២-បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប។ ៣-ពិភាក្សាអំពីផែនការសកម្មភាពដែលត្រូវអនុវត្តដោយអង្គការដៃគូលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២។ ៤-ការធ្វើបទបង្ហាញពីសេវាកម្ម និងព័ត៌មាននៃគម្រោងមជ្ឈមណ្ឌល CASA យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត។ ៥-"រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ"។ ៦-ករណីពពោះជំនួស ដើម្បីរកដំណោះស្រាយ និងពន្លឿននីតិវិធីតុលាការ។ ៧-ការគ្រប់គ្រងព្រំដែន និងលំហូរទេសន្តរប្រវេសន៍ការងារនៅក្នុងបរិបទនៃការស្តារឡើងវិញបន្ទាប់ពីវិបត្តិកូវីដ-១៩។ ៨-កិច្ចសហការសម្រាប់ការអនុវត្តគម្រោងបង្ការ |

ទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស។ **៩**-វឌ្ឍនភាពការងាររបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១០**-គម្រោងអភិវឌ្ឍសមត្ថភាពភាសាបរទេស(ខ្មែរ-ថៃ) និងការចុះសួរសុខទុក្ខការអនុវត្តគម្រោងនៅតាមសាលារៀនក្នុងខេត្តកោះកុង។ **១១**-ការងារសាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះ។ ១២-វាយតម្លៃពាក់កណ្តាលអាណត្តិ ពីលទ្ធផលការងារបញ្ហាប្រឈម និងលើកផែនការបន្តឆ្នាំ២០២៣។ **១៣**-បូកសរុបរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ២០២២។ **១៤**-ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ។ **១៥**-ការរួមចំណែកក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជន។

| សកម្មភាពរៀបចំកិច្ចប្រជុំរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ៧៣ | ៥៨០ | ២១៥ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០៩ | ១៥២ | ១១៣ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០២ | ៣៥ | ១៨ |
| ក្រសួងកិច្ចការនារី | ០២ | ៨៧ | ៤០ |
| រាជធានីភ្នំពេញ | ០៥ | ៤១១ | ១៩០ |
| ខេត្តបន្ទាយមានជ័យ | ០៣ | ២០៣ | ១៤៤ |
| ខេត្តបាត់ដំបង | ០៥ | ៨៩៩ | ៤៣៨ |
| ខេត្តសៀមរាប | ៧៦ | ២.៣៨៤ | ៩៤៣ |
| ខេត្តព្រះវិហារ | ០១ | ១០០ | ៦០ |
| ខេត្តឧត្តរមានជ័យ | ១០ | ៤១ | ១៧ |
| ខេត្តកោះកុង | ០៣ | ៤៩ | ២៨ |
| ខេត្តស្ទឹងត្រែង | ០២ | ១២៤ | ៨២ |
| ខេត្តក្រចេះ | ០៥ | ៣០៣ | ២២៤ |
| ខេត្តកំពង់ចាម | ១៦ | ៤០៥ | ១៩២ |
| ខេត្តត្បូងឃ្មុំ | ០២ | ៥៦២ | ១១៣ |
| ខេត្តស្វាយរៀង | ០៤ | ១២៧ | ៤២ |
| ខេត្តកណ្តាល | ៨៧ | ២.៦៥៣ | ១.២១៤ |
| ខេត្តព្រៃវែង | ១៥ | ៥៩៥ | ១៨៣ |
| ខេត្តព្រះសីហនុ | ០២ | ៤៩ | ៣២ |
| ខេត្តកំពត | ៥៩ | ១.១៣៦ | ៨២៤ |
| ខេត្តតាកែវ | ១២ | ៥៩៣ | ២៦៧ |
| ខេត្តកែប | ០៣ | ៦៦ | ០៨ |
| ខេត្តកំពង់ធំ | ០២ | ៨១ | ២៩ |
| ខេត្តកំពង់ឆ្នាំង | ៣៤ | ១.០១៤ | ៥៧១ |
| ខេត្តកំពង់ស្ពឺ | ២៤ | ៣៦៥ | ១៨៥ |
| ខេត្តមណ្ឌលគិរី | ០៣ | ១៧៦ | ៦៨ |
| អង្គការសេម៉ាតែនកីស(ខេត្តបាត់ដំបង) | ០២ | ៧១ | ៣៣ |
| **សរុប** | **៤៦១លើក** | **១៣.២៦១នាក់** | **៦.២៧៣នាក់** |

## ១.២. កិច្ចប្រជុំក្រៅប្រទេស

### ▪ ថ្នាក់ជាតិ

• **គ.ជ.ប.ជ៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជាអនុប្រធានក្រុមប្រឹក្សាជាតិដើម្បីកុមារ បានដឹកនាំ៖ (១)-ចូលរួមក្នុងកិច្ចប្រជុំ ការពាររបាយការណ៍ថ្នាក់ជាតិលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារក្នុងកិច្ចប្រជុំលើកទី៩០ របស់គណៈកម្មាធិការសិទ្ធិកុមារ (CRC) អង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ (២)-គណៈប្រតិភូកម្ពុជា មានតំណាង: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីចូលរួមក្នុងវេទិកាអន្តរជាតិពិនិត្យឡើងវិញនូវការអនុវត្ត GCM ក្នុងនាមកម្ពុជាជាប្រទេស Champion Country នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។ (៣)-គណៈប្រតិភូកម្ពុជា មានតំណាងក្រុមការងារជំនាញអន្តរក្រសួងទាំង៦ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីចូលរួមកិច្ចប្រជុំចុះហត្ថលេខាលើស្តង់ដារនៃនីតិវិធីប្រតិបត្តិ (SOP) ស្តីពីកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស។

• **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ ដឹកនាំមន្ត្រីជំនាញនាយកដ្ឋាន និងមន្ត្រីពាក់ព័ន្ធបានសហការ និងចូលរួមជាមួយប្រតិភូភាគីថៃ ក្នុងការចុះពិនិត្យការ ដ្ឋានសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

• **ក្រសួងកិច្ចការនារី៖** ១-លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី បានដឹកនាំកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីខមមីតលើកទី៥ ក្រោមប្រធានបទ "ពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគីឱ្យបានរឹងមាំ និងប្រកបដោយនិរន្តរភាព ដើម្បីបញ្ចប់អំពើជួញដូរមនុស្ស" រៀបចំដោយប្រទេសថៃ តាមប្រព័ន្ធសន្និសីទវីដេអូ ដែលមានតំណាងប្រទេសកម្ពុជា ចិន ឡាវ ថៃ វៀតណាម និងមីយ៉ាន់ម៉ា។ ២-បានដឹកនាំប្រតិភូនៃក្រុមការងារខមមីតកម្ពុជា រួមមានតំណាងពីក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គលេខាធិការដ្ឋាន នៃគ.ជ.ប.ជ និងអគ្គស្នងការដ្ឋាននគរបាលជាតិ និងបានសហការជាមួយអង្គការ UNODP ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ពហុភាគី លើយន្តការបញ្ជូនឆ្លងដែន (Trans National Referral Mechanism) នៃប្រទេសមហាអនុតំបន់មេគង្គ នៅទីក្រុងបាងកកប្រទេសថៃ។

• **ខេត្តបាត់ដំបង៖** រដ្ឋបាលខេត្តបានសហការជាមួយនឹងរដ្ឋបាលខេត្តបន្ទាយមានជ័យ ដឹកនាំគណៈប្រតិភូចំនួន ០៨រូប ទៅចូលរួមប្រជុំពិភាក្សាទ្វេភាគីកម្ពុជា-ថៃ ស្តីពីការជួយសម្រួលដល់ការឆ្លងដែនរបស់ប្រជាពលរដ្ឋទៅវិញទៅមក និងដើម្បីងាយស្រួលដល់ការដឹកទំនិញចេញចូលនៃប្រទេសទាំងពីរ នៅក្នុងស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ នៃព្រះរាជាណាចក្រថៃ។

• **ខេត្តកណ្តាល៖** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំក្រុមប្រតិភូសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលសហប្រតិបត្តិការដំណាក់កាលឆ្នាំ២០១៧-២០២១ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការដំណាក់កាល ២០២២-២០២៧ រវាងសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកណ្តាល ខេត្តតាកែវ និងសម្ព័ន្ធសមាគមនារីខេត្តអានយ៉ាង នៅប្រទេសវៀតណាម ដើម្បីពង្រឹងសមត្ថភាពក្នុងការផ្តល់ប្រឹក្សាដើម្បីការពារសិទ្ធិស្របច្បាប់របស់ស្ត្រី និងកុមារ និងការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។

• **ខេត្តស្ទឹងត្រែង៖** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំក្រុមប្រតិភូសមាគមនារីកម្ពុជាដើម្បីសន្តិភាព រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលសហប្រតិបត្តិការដំណាក់កាលឆ្នាំ២០១៨-២០២២ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការដំណាក់កាល ២០២២-២០២៥ រវាងសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងសម្ព័ន្ធសមាគមនារីខេត្តយ៉ាឡាយ ប្រទេសវៀតណាម ស្តីពីការពង្រឹងសមត្ថភាពរួមគ្នាក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។

## ២. ជំនួបពិភាក្សាការងារ

### ▪ ថ្នាក់ជាតិ

• **គ.ជ.ប.ជ៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញទទួលជួបពិភាក្សាការងារនៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយ៖ **១-** អ្នកស្រាវជ្រាវឯករាជ្យនៃវិទ្យាស្ថានឯករាជ្យក្រៅប្រទេស (ODI) ដែលមានទីតាំងនៅទីក្រុងឡុងប្រទេសអង់គ្លេស និងជាអ្នកសិក្សាស្រាវជ្រាវឱ្យកម្មវិធី ASEAN-ACT និងអនុញ្ញាតឱ្យសួរសំណួរស្រាវជ្រាវមួយចំនួនពាក់ព័ន្ធភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្សរបស់ពលករចំណាកស្រុកកម្ពុជា **២-**លេខានៃស្ថានទូតអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងករណីពពោះជំនួស **៣-**តំណាងអង្គការ UNICEF ទទួលបន្ទុកអភិវឌ្ឍន៍យុវជននិងវ័យជំទង់ ដើម្បីពិភាក្សាការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសកិច្ចការពារកុមារជាជនរងគ្រោះ ងាយរងគ្រោះ នៅក្នុងចំណោមពលករទេសន្តរប្រវេសន៍ **៤-**តំណាងអង្គការ JICA ប្រចាំនៅកម្ពុជា ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **៥-**ប្រធានអង្គការវីនរ៉ក់ បានប្រគល់-ទទួលសៀវភៅរបាយការណ៍វាយតម្លៃពាក់កណ្ដាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ ២០១៩-២០២៣ **៦-**តំណាងអង្គការការីតាសស្វីស ដើម្បីសំណេះសំណាល និងស្វែងយល់ពីបច្ចុប្បន្នភាពនៃការអនុវត្តគម្រោងរបស់ខ្លួន **៧-**តំណាងអង្គការសេរីភាពកម្ពុជាអូស្ត្រាលី ដើម្បីស្វែងយល់បន្ថែមអំពីលទ្ធភាពបង្កើនកិច្ចសហប្រតិបត្តិការជាមួយ គ.ជ.ប.ជ **៨-**អង្គការណូមីណេតវើក (Nomi Network) ស្ដីពីទស្សនវិស័យ និងគោលបំណង ដែលមានបេសកកម្មចម្បងៗ គឺការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការផ្ដល់ដើមទុនសម្រាប់អាជីវកម្មខ្នាតតូចដល់ស្ត្រីងាយរងគ្រោះ ដើម្បីចូលរួមកាត់បន្ថយការធ្វើចំណាកស្រុក។

• **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖** បានជួបពិភាក្សាការងារជាមួយ៖ **១-**លោក POTTLER Maximilian នាយកគ្រប់គ្រងគម្រោងប្រចាំតំបន់ នៃអង្គការ IOM ដើម្បីសិក្សាលទ្ធភាពពង្រីកកិច្ចសហការក្រោមគម្រោង PROMISE ដំណាក់កាលទី២ ស្ដីពីការកាត់បន្ថយភាពក្រីក្រតាមរយៈទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ការអភិវឌ្ឍជំនាញ និងការលើកកម្ពស់សេវាស្វែងរកការងារឱ្យធ្វើ ដើម្បីគាំពារ និងគាំទ្រដល់ពលករទេសន្តរប្រវេសន៍ក្នុងការត្រៀមចូលទីផ្សារការងារទទួលបាននូវឱកាសការងារសមរម្យ បន្ទាប់ពីវិលត្រឡប់ចូលមាតុភូមិវិញ **២-**អង្គការ IOM លើ៖ **(ក)**គម្រោងបណ្ដុះបណ្ដាលវគ្គខ្លីដល់ពលករទេសន្តរប្រវេសន៍នៅកម្ពុជា និងចុះកម្មសិក្សា ឬហាត់ការងារនៅប្រទេសថៃ (តាមម៉ូដែលនៃគម្រោង PROMISE ដំណាក់កាលទី១) **(ខ)**គម្រោងសហការជាមួយនឹងភ្នាក់ងារស្វែងរកការងារឱ្យធ្វើក្នុងស្រុក ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលវគ្គខ្លីដល់ពលករទេសន្តរប្រវេសន៍ និងការស្វែងរកការងារក្នុងស្រុក **(គ)** ព័ត៌មានអំពីបណ្ដាញគោលនយោបាយសកល (Global Policy Network) **៣-**អ្នកជំនាញការអង្គការ ILO ក្រោមគម្រោង Ship to Shore Rights South East Asia Programme ដើម្បីពិភាក្សាការងារ និងធ្វើបច្ចុប្បន្នភាពពាក់ព័ន្ធនឹងការអនុវត្តគម្រោងកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ និងកិច្ចសហប្រតិបត្តិការនៅកម្ពុជា ដើម្បីពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព លើកកម្ពស់សមត្ថភាពមន្ត្រី និងជួយរកការងារជូនពលករដែលវិលត្រលប់មកវិញ **៤-**អង្គការ WINROCK INTERNATIONAL ស្ដីពីកិច្ចសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **៥-**អង្គការ JICA លើការរៀបចំមូលដ្ឋានផែនការសម្រាប់គម្រោងថ្មី ស្ដីពីការអភិវឌ្ឍសមត្ថភាពក្នុងការជួយដល់ជនរងគ្រោះពីការជួញដូរមនុស្ស **៦-**អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី (LSCW) និងបណ្ដាញទេសន្តរប្រវេសន៍មេគង្គ ដើម្បីស្វែងយល់ពីយន្តការក្នុងការគ្រប់គ្រង និងការសម្របសម្រួលឱ្យពលករទទួលបាននូវរបបសន្តិសុខសង្គម។

• **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ បានដឹកនាំមន្ត្រីជំនាញអគ្គនាយកដ្ឋាន នៃក្រសួងស.អ.យ បានជួបពិភាក្សាការងារជាមួយ៖ **១-**សមភាគីថៃតាមការស្នើសុំ ដើម្បីចុះត្រួតពិនិត្យកំណត់ព្រំប្រទល់ដីសម្រាប់សាងសង់មណ្ឌលសំចត និងស្ដារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ **២-**ក្រុមការងារនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ពិភាក្សារៀបចំផែនការសកម្មភាពដើម្បីជួយគាំទ្រដល់ជនរងគ្រោះពីការជួញដូរមនុស្ស **៣-**តំណាងJICA លើសំណើសុំផ្ដល់ព័ត៌មានបន្ថែមសម្រាប់គម្រោងអភិវឌ្ឍន៍សមត្ថភាព ដើម្បីជួយអ្នករស់រានមានជីវិតពីការជួញដូរមនុស្ស

ក្នុងប្រទេសកម្ពុជាតាមប្រព័ន្ធអនឡាញ(ZOOM) ៤-អង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) និងអង្គការ UN-WOMEN លើគម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើសំណាកស្រុកដោយសុវត្ថិភាព តាមប្រព័ន្ធអនឡាញ។

- **ថ្នាក់ក្រោមជាតិ**

•**ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ ក្រុមការងារទេសន្តរប្រវេសន៍ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលប្រជុំពិភាក្សាការងារជាមួយៈ ១-អង្គការ IJM ស្តីពីកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរកម្លាំងពលកម្ម ២-អង្គការមូលនិធិA21 ស្តីពីការអនុវត្តផែនការសកម្មភាពឆ្នាំ២០២២ លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៣-អង្គការជីវិតថ្មីនៅកម្ពុជា ក្នុងការត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាព ស្តីពីកិច្ចការពារកុមារ និងច្បាប់យុត្តិធម៌អនីតិជន (វិធានការបង្វែរអនីតិជនជំទាស់នឹងច្បាប់) ៤-អង្គការ WeWorld Onlus ស្តីពីការលើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជាដែលមានជំនាញទាបនៅក្នុងប្រទេសថៃ ៥-អង្គការ JICA ស្តីពីការជួញដូរមនុស្សនៅក្នុងបណ្តាប្រទេសអនុតំបន់មេគង្គ (កម្ពុជា ថៃ ឡាវ វៀតណាម...) ៦-អង្គការហាការ និងអង្គការ Hope Trust នៃប្រទេសស្វូឡម៉ុន ដើម្បីស្វែងយល់អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៧-អង្គការ UN Women ស្តីពីការលើកកម្ពស់ និងគាំទ្រលើស្ត្រីពលករទេសន្តរប្រវេសន៍ នៅក្នុងវិបត្តិជំងឺកូវីដ-១៩ ៨-អង្គការ IOM ស្តីពីការចុះសម្ភាសន៍ពលករចំណាកស្រុកដែលត្រឡប់មកពីធ្វើការងារនៅប្រទេសថៃ។

•**ខេត្តបន្ទាយមានជ័យ** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បាន៖ ១-ផ្តល់បទសម្ភាសជាមួយក្រុមការងាររបស់ក្រុមហ៊ុន RESEARCH និង Communication Group (RCG) សហការជាមួយអង្គការ IJM ក្នុងគោលបំណង៖ (ក)សិក្សាស្វែងយល់ពីបទពិសោធន៍នៃដំណើររឿងក្តី និងការងារប្រយុទ្ធប្រឆាំងបទល្មើសជួញដូរពលកម្មក្នុងស្រុក និងឆ្លងដែន (ខ)ស្នើសុំមតិយោបល់ពីភាពខ្វះចន្លោះនៃការងារប្រយុទ្ធប្រឆាំងបទល្មើសខាងលើ និងអនុសាសន៍អំពីការធ្វើឱ្យប្រសើរឡើងនូវការងាររឿងក្តី ក៏ដូចជានីតិវិធីក្នុងកិច្ចសហការប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម ជាមួយស្ថាប័នពាក់ព័ន្ធនានា ២-អង្គការ JICA ស្តីពីគម្រោងពង្រឹងបណ្តាញក្នុងតំបន់សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមតំបន់មេគង្គ(២០២១-២០២៤) ៣-អង្គការចិត្តសង្គមអន្តរវប្បធម៌ ស្តីពីការជ្រើសរើស និងចាត់តាំងមន្ត្រីជួរមុខដែលបម្រើការងារជូនពលករចំណាកស្រុកដែលវិលត្រឡប់មកវិញ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលទាក់ទងនឹងសុខភាពផ្លូវចិត្តអ្នកទទួលសេវា។ ៤-អង្គការជំនួយផ្លូវច្បាប់កុមារ និងស្ត្រី ស្តីពីការអនុវត្តគម្រោងយុត្តិធម៌សម្រាប់ពលករចំណាកស្រុកក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រ។ ៥-អង្គការណ្វេមីណែតវើកកម្ពុជា ទាក់ទងនឹងស្ថានភាពជួញដូរស្ត្រីនៅក្នុងខេត្តបន្ទាយមានជ័យ។

•**ខេត្តឧត្តរមានជ័យ៖** បានទទួល និងការពិភាក្សាការងារ គណៈប្រតិភូ គណៈកម្មាធិការទី១ ព្រឹទ្ធសភា ក្នុងគោលបំណងដើម្បីពិភាក្សាស្វែងយល់អំពីការអនុវត្តការងាររបស់មន្ទីរកន្លងមក លើការអនុវត្តសិទ្ធិនារី ទទួលបានសុខភាព ការជួញដូរមនុស្ស អំពើហិង្សា ជាពិសេសស្ត្រី និងកុមារ ក្នុងអំឡុងពេលមានវិបត្តិជំងឺកូវីដ-១៩ ។

•**ខេត្តព្រះវិហារ៖** តំណាងស្នងការដ្ឋាននគរបាល បានជួបប្រជុំពិភាក្សាការងារជាមួយភាគីថៃ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អប្រសើរនៅតាមច្រកព្រំដែនអានសេះ ដើម្បីជួយសម្រួលឱ្យប្រជាពលរដ្ឋឆ្លងដែនទទួលបានសុវត្ថិភាព។

•**ខេត្តបាត់ដំបង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបប្រជុំពិភាក្សាការងារជាមួយ៖ ១-នាយកមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (American Center For International Labor Solidarity) លើកិច្ចសហការក្នុងការការពារពលករទេសន្តរប្រវេសន៍ និងបញ្ហាប្រឈមនានា។ ២-អង្គការ ILO ស្តីពីការអនុវត្តសកម្មភាពសម្រាប់គម្រោងទេសន្តរប្រវេសន៍។

•**ខេត្តកណ្តាល៖** ឯកឧត្តម **គង់ សោភ័ណ្ឌ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ បានជួបពិភាក្សាជាមួយអភិបាលក្រុង Choi Dinh-in of Heupect នៃសាធារណរដ្ឋកូរ៉េ ស្តីពីលទ្ធភាពនៃការបញ្ជូនពលកររបស់ខេត្ត ទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ និងពង្រឹងកិច្ចសហការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ ។

•**ខេត្តស្វាយរៀង៖** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបប្រជុំពិភាក្សាការងារជាមួយ៖ ១-ក្រុមការងារស្ថានទូតសហរដ្ឋអាមេរិក លោក **ចូណាថាន អាដាម** ប្រធានផ្នែកនយោបាយ និងសហការី ស្តីពីការងារប្រយុទ្ធ

ប្រឆាំងអំពើជួញដូរមនុស្ស និងពលកម្មកុមារ។ **២**-អង្គការ LSCW ស្តីពីការអនុវត្តគម្រោង "ការពង្រឹងសិទ្ធិទទួលបានការអប់រំ និងការងារ តាមរយៈការចូលរួមរបស់សហគមន៍ ក្នុងគោលបំណងចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងផ្តល់សេវាគាំទ្រសម្រាប់ពលករ។

• **ខេត្តតាកែវ៖** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយលោកជំទាវ **ទូច សារ៉ុម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ស្តីពីការបញ្ជ្រាបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងពុទ្ធចក្រ និងអាណាចក្រ។

•**ខេត្តកោះកុង៖** អនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាជាមួយអង្គការវីនរ៉ក់អន្តរជាតិ ស្តីពីការកំណត់ស្រុកគោលដៅ ដើម្បីអនុវត្តគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

•**ខេត្តត្បូងឃ្មុំ៖** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំក្រុមការងារជំនាញទាំង០៦ សមាជិកលេខាធិការដ្ឋានថ្នាក់ខេត្ត ជួបពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រីនិងកុមារ(LSCW) លើគម្រោងស្តីពីការជំរុញឱ្យទទួលបានភាពយុត្តិធម៌ និងសេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

•**ខេត្តកំពង់ចាម៖ ក**-ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយ៖ (១)-អង្គការ LSCW ស្តីពីបញ្ហារបស់ប្រជាពលរដ្ឋចំណាកស្រុកមិនស្របច្បាប់ ដែលទៅធ្វើការងារជាពលករតាមរដូវកាល នៅសាធារណរដ្ឋកូរ៉េ។ (២)-អង្គការរតនៈអ៊ីនធើណេសិនណល ប្រចាំប្រទេសកម្ពុជា និងក្រុមការងារ ស្តីពីកិច្ចសហការសម្រាប់ការអនុវត្តគម្រោង "បង្ការទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស។ **ខ**-តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបពិភាក្សាការងារជាមួយទីប្រឹក្សាបច្ចេកទេសអង្គការ ISSARA ស្តីពីបញ្ហាប្រឈមរបស់ពលករធ្វើការនៅប្រទេសថៃ។

## គ. ការចារសម្របសម្រួល

គ.ជ.ប.ជ/គ.រ.ប.ជ/គ.ខ.ប.ជ និងអង្គការដៃគូមានដូចជា៖ វីនរ៉ក់អន្តរជាតិ, ការីតាសស្វីស, តំណក់ទឹក ASEAN-Acts, IOM, ILO, UNICEF, UNW-SAF, UNICEF, យៃអេន្តរជាតិ, Cambodia Acts, Plan International, World Vison, USAID, EU, សង់ត្រាល់, IJM, ក្តីសង្ឃឹម និងយុត្តិធម៌, UNDP, APLE, LSCW សម្ព័ន្ធចាប់ដៃ, ឆាលហ្វាន, បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗទៀត ដោយផ្ទាល់ និងតាមប្រព័ន្ធ Zoom ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្អែកលើផែនការជាតិយុទ្ធសាស្ត្រជាតិទាំងបួន (ការបង្ការ ទប់ស្កាត់ ការការពារ និងជួយជនរងគ្រោះ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងអំពើជួញដូរមនុស្ស) សរុបចំនួន **៩៧៥**លើក មានអ្នកចូលរួមសរុប **១០.៦៧៥**នាក់ (ស្រី **៤.៦១៣**នាក់) ដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាពចូលរួមរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្រី |
|---|---|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ៣៨១ | ៣.២២៥ | ១.៣២៣ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥៥ | ៣២៦ | ១៦១ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១៥០ | ៩៥២ | ៤៦៣ |
| ក្រសួងទេសចរណ៍ | ០៣ | ៩១ | ៣៨ |
| រាជធានីភ្នំពេញ | ២៩ | ១៨៩ | ៨៩ |
| ខេត្តបន្ទាយមានជ័យ | ៤០ | ៨៣៣ | ២១៩ |
| ខេត្តព្រះវិហារ | ០៩ | ៧៩ | ៤២ |
| ខេត្តបាត់ដំបង | ៣៥ | ៣៨០ | ២៣៣ |
| ខេត្តពោធិ៍សាត់ | ១១ | ៩៥ | ៦៦ |
| ខេត្តសៀមរាប | ២៥ | ៣៥១ | ១៦៧ |
| ខេត្តឧត្តរមានជ័យ | ០៩ | ៩៩ | ៤៥ |

| | | | |
|---|---|---|---|
| ខេត្តប៉ៃលិន | ១៣ | ១២៩ | ៨៧ |
| ខេត្តកោះកុង | ១២ | ១១៧ | ៦៧ |
| ខេត្តក្រចេះ | ១០ | ១០៩ | ៥៨ |
| ខេត្តស្ទឹងត្រែង | ១០ | ១៣៦ | ៩៣ |
| ខេត្តរតនគិរី | ០៨ | ៨៦ | ៣៤ |
| ខេត្តកំពង់ចាម | ១៦ | ១៦០ | ៩៦ |
| ខេត្តត្បូងឃ្មុំ | ០៩ | ៧៤ | ៤៧ |
| ខេត្តមណ្ឌលគិរី | ១១ | ៥៩ | ១៩ |
| ខេត្តស្វាយរៀង | ១១ | ៩៥ | ៤៤ |
| ខេត្តកណ្ដាល | ២៨ | ៣៦៤ | ១៤០ |
| ខេត្តព្រៃវែង | ១១ | ១៤៥ | ៨៧ |
| ខេត្តព្រះសីហនុ | ១១ | ២៧៩ | ១៤៤ |
| ខេត្តកំពត | ១០ | ១០៥ | ៧៦ |
| ខេត្តកែប | ០៩ | ៧៦ | ២៥ |
| ខេត្តតាកែវ | ១២ | ៦៥០ | ២៩៨ |
| ខេត្តកំពង់ឆ្នាំង | ០៩ | ១៥៧ | ៩២ |
| ខេត្តកំពង់ស្ពឺ | ២២ | ៩៩៥ | ២១៥ |
| ខេត្តកំពង់ធំ | ១៣ | ១៩០ | ៨៩ |
| អង្គការ RATANAK international | ១០ | ១០១ | ២៩ |
| អង្គការសម្ព័ន្ធចាប់ដៃ | ០១ | ២៨ | ២៧ |
| **សរុប** | **៩៧៥លើក** | **១០.៦៧៥នាក់** | **៤.៦១៣នាក់** |

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក. ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- រាជរដ្ឋាភិបាលកម្ពុជា នៅតែកំណត់យកបញ្ហាជួញដូរមនុស្សជាអាទិភាព ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- អនុសាសន៍ **០៤ចំណុច** របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ នៅតែមានគុណតម្លៃ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព ។
- កម្ពុជាមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលអនុលោមតាមច្បាប់អន្តរជាតិ (ពិធីសារប៉ាឡឺម៉ូ) ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ធ្វើជាមូលដ្ឋានបង្អែកសម្រាប់ការអនុវត្តច្បាប់ ប្រឆាំងអំពើជួញដូរមនុស្ស
- ជាមួយបណ្តាប្រទេសពាក់ព័ន្ធក្នុងតំបន់ និងជាអន្តរជាតិ យើងបានចុះសន្ធិសញ្ញា កតិកាសញ្ញា បត្យាប័នអនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។

- យន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រហូតដល់សមត្ថកិច្ចព្រំដែន គឺជាកម្លាំងស្នូលក្នុងការអនុវត្តការងារ ដែលពង្រាយនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធ អង្គការ ជាតិ អន្តរជាតិ វិស័យឯកជន។
- មានការបង្កើនការយល់ដឹង និងការចូលរួម តាមវេទិកាសាធារណៈ នៃគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលបានបង្កើតជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ត្រូវការពង្រឹងសមត្ថភាពដល់មន្ត្រីដែលត្រូវទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សអំពីបទល្មើសថ្មីៗ ជាពិសេស ដល់មន្ត្រីថ្មីមួយចំនួន ដែលមានការផ្លាស់ប្តូរមកទទួលតួនាទីភារកិច្ច ។
- ត្រូវការពង្រឹងរចនាសម្ព័ន្ធ និងរបៀបរបបការងារក្រុមការងារទាំង០៦ ដើម្បីបំពេញតួនាទីភារកិច្ចតាមការកំណត់ក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេច ការធ្វើរបាយការណ៍ និងឲ្យមានរបបប្រជុំទៀងទាត់ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ។

### គ. សន្និដ្ឋាន

- ជនជួញដូរមនុស្ស មិនព្រមបោះបង់អាជីវកម្មរបស់ខ្លួនងាយៗឡើយ ហើយព្យាយាមរិះរកគ្រប់មធ្យោបាយដើម្បីកេងប្រវ័ញ្ច ទាញយកផលចំណេញពីមនុស្សផងគ្នា ដោយមិនខ្វាយខ្វល់អំពីទុក្ខវេទនារបស់ជនរងគ្រោះឡើយ។ ហេតុនេះ រាជរដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធដែលមានឆន្ទៈប្រយុទ្ធប្រឆាំងដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស មិនអាចឈរឈប់បានឡើយ ហើយត្រូវខិតខំស្វែងរកឬសគល់នៃភាពរងគ្រោះ និងត្រូវការបោសសម្អាតជាបន្ទាន់ ដើម្បីកុំឲ្យវាក្លាយជាគ្រោះមហន្តរាយដែលពិបាកនឹងទប់ស្កាត់ និងបំផ្លាញមនុស្ស និងសង្គមជាតិកាន់តែធ្ងន់ធ្ងរបាន ។
- កិច្ចសហប្រតិបត្តិការជាសេចក្តីត្រូវការចាំបាច់មិនអាចខ្វះបាន ទាំងនៅផ្ទៃក្នុងជាតិ ទាំងជាមួយអន្តរជាតិ ដោយត្រូវការប្រមូលផ្តុំជាកម្លាំងសរុប ធនធានសរុប មធ្យោបាយសរុបពីគ្រប់វិស័យ គ្រប់ថ្នាក់ គ្រប់បញ្ញាញាណ និងត្រូវការការរួមគ្នា និងចែកភារកិច្ចគ្នាដើម្បីឆ្លើយតបនៅគ្រប់តំណាក់កាលនៃការប្រឆាំងការជួញដូរមនុស្ស ។
- គោលនយោបាយភូមិឃុំសង្កាត់មានសុវត្ថិភាព និងសេវាមូលដ្ឋាន ជាមូលដ្ឋានគ្រឹះនៃភាពសុខដុមរមនារបស់ប្រជាពលរដ្ឋ និងជាបរិយាកាសសង្គម ដែលជួយលុបបំបាត់រាល់បទល្មើស រាប់ទាំងអំពើជួញដូរមនុស្សផងដែរ ។

## V. ទិសដៅអនុវត្តបន្ត ឆ្នាំ២០២៣

ដើម្បីឆ្លើយតបទៅនឹងភាពប្រែប្រួលនៃបទល្មើសដែលបាន និងកំពុងតែបង្កភាពរងគ្រោះដល់ជនដែលងាយរងគ្រោះ គ្រប់វ័យ គ្រប់ស្ថានភាព គ្រប់ទីកន្លែង ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ទៅតាមយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងដើម្បីពង្រឹងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

ការងាររួមនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖

### ក. ការរៀបចំច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

១.បន្តរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលជាតម្រូវការចាំបាច់សម្រាប់បម្រើដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

២.ពង្រឹងកិច្ចសហការ រវាងក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ដើម្បីបន្តពិគ្រោះយោបល់ និងពិនិត្យឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សក្រោមរូបភាពពពោះជំនួស។

៣.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ។
៤.បន្តជំរុញការអនុវត្តអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធដែលបានចុះហត្ថលេខារួចហើយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល។
៥. ពិនិត្យសម្រេចផែនការអនុវត្ត ស្តង់ដារនៃនីតិវិធីប្រតិបត្តិ(SOP) ស្តីពីកិច្ចសហការក្នុងការអនុវត្តច្បាប់ ដើម្បីប្រឆាំងការជួញដូរមនុស្ស ដែលបានចុះហត្ថលេខាហើយក្នុងឆ្នាំ២០២២ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស នៃព្រះរាជាណាចក្រថៃ។
៦.ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ របស់ក្រសួងសុខាភិបាល។
៧.រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីកសាងបទដ្ឋានគតិយុត្តនានា សម្រាប់ការពារសិទ្ធិ សុវត្ថិភាព ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទសមុទ្រ។
៨.ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការ ការពារ និងបង្ការទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក។
៩.ត្រៀមបន្តចុះហត្ថលេខាអនុស្សរណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធ។
១០.បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តវិធានការច្បាប់ វិធានការបង្ការទប់ស្កាត់ វិធានការសង្គ្រោះ និងការពារជនរងគ្រោះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
១១.បន្តពង្រឹងយន្តការដឹកនាំបញ្ជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ទាំងលើការងារផ្សព្វផ្សាយអប់រំ និងការចាត់តាំងអនុវត្តច្បាប់ ព្រមទាំងជំរុញការតាមដានត្រួតពិនិត្យ និងកែលម្អជាប្រចាំចំពោះកិច្ចប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់ សំដៅជំរុញឱ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាន់តែទទួលបានប្រសិទ្ធផលខ្ពស់។
១២. ត្រៀមរៀបចំកិច្ចប្រជុំ រវាងប្រទេស កម្ពុជា វៀតណាម ឡាវ និងចិន ស្តីពី ការបង្ការទប់ការស្កាត់ការនាំមនុស្សឆ្លងដែនខុសច្បាប់ ។
១៣.រៀបចំកិច្ចពិភាក្សាថ្នាក់ជាតិ ដើម្បីរកនីតិវិធីក្នុងការគ្រប់គ្រង និងផ្តល់ភាពស្របច្បាប់ដល់ពលករទេសន្តរប្រវេសន៍ នៅប្រទេសថៃ ។

## ខ. ការងារបង្ការ ទប់ស្កាត់

១.បន្តសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំយុទ្ធនាការ «គាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម»។
២.សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំសិក្ខាសាលាច្រកចេញចូលតែមួយ ស្តីពី «សេវាកម្មកុមារ»។
៣.ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ បន្តបើកវគ្គបណ្តុះបណ្តាលសៀវភៅសិក្សាអប់រំស្តីពី «ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន» ដល់គ្រូឧទ្ទេសថ្នាក់ជាតិ គ្រូឧទ្ទេសក៏គរុកោសល្យភូមិភាគ និងគ្រូបង្គោល តាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នៅទូទាំងប្រទេស និងតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតខាងលើ។
៤.ក្រសួងទេសចរណ៍ បន្តការរៀបចំសិក្ខាសាលា ស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេចរណ៍ដល់ម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍តាមបណ្តារាជធានី-ខេត្ត។
៥.សហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា(TRC) ធ្វើការផ្សព្វផ្សាយសារអប់រំ ដល់ប្រជាពលរដ្ឋ តាមរយៈទូរស័ព្ទចល័ត នៅថ្ងៃទិវាជាតិពាក់ព័ន្ធ។

៦.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដើម្បីជំរុញ និងពង្រីកការផ្សព្វផ្សាយអំពីឱកាសការងារឱ្យកាន់តែទូលំទូលាយនៅតាមសហគមន៍ ជាពិសេសសហគមន៍ដែលងាយរងគ្រោះ រួមទាំងពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់។

៧.សហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនីតិវិធីងាយស្រួលក្នុងការផ្សារភ្ជាប់ទំនាក់ទំនង និងការទទួលបានការប្រឹក្សាយោបល់ពីទីភ្នាក់ងារជាតិមុខរបរ និងការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីជម្រើសការងារ ឬមុខរបរ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងៗសម្រាប់ក្រុមជនងាយរងគ្រោះ ជាពិសេស ពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីបរទេស។

៨.បន្តជំរុញការគ្រប់គ្រង និងធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាការអនុវត្តគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារ ក្នុងការការពារសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ពលករក្នុងការធ្វើទេសន្តរប្រវេសន៍ការងារ។

៩.បន្តរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងវេទិកាជាតិអន្តរសាសនានៅកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១០.បន្តសហការជាមួយអង្គការសហប្រជាជាតិ (IOM, WHO, UNFPA, UNICEF) និងដៃគូផ្សេងៗទៀត ដើម្បីរៀបចំកម្មវិធី ឆ្លើយតបទៅនឹងផលប៉ះពាល់លើសុខភាព និងជីវភាពពលករទេសន្តរប្រវេសន៍ និងគ្រួសារ ក្នុងស្ថានភាពនៃការរាតត្បាតដោយជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយផ្សេងៗទៀត។

១១.បន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ការផ្សព្វផ្សាយអំពីការបង្ការ ទប់ស្កាត់ ការឆ្លង និងចម្លងជំងឺកូវីដ-១៩ និងផលប៉ះពាល់ ព្រមទាំងចុះតាមដានការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។

១២.បន្តលើកកម្ពស់ការងារផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយ អំពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងនិងក្រៅសាលារៀន និងជនងាយរងគ្រោះដទៃទៀត។

១៣.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ដើម្បីកំណត់រកអំពើកេងប្រវ័ញ្ចផ្សេងៗ និងមានវិធានការក្នុងប្រភេទការងារដែលមានភាពរងគ្រោះខ្ពស់ ដូចជានៅតាមទីភ្នាក់ងារជ្រើសរើសពលករឯកជន រោងចក្រ សហគ្រាស សហគ្រាសឡដុត កសិដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ កន្លែងសេវាកម្សាន្តជាដើម។

១៤.លើកកម្ពស់ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងការអនុវត្តក្រមសីលធម៌ របស់ទីភ្នាក់ងារ និងកាត់បន្ថយការយកថ្លៃឈ្នួលពីពលករ ក្នុងនីតិវិធីនៃការជ្រើសរើសពលករទេសន្តរប្រវេសន៍។

១៥.បន្ត និងជំរុញរៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន។

## គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ

១.បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

២.បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោស បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុង និងក្រៅប្រទេស ជាពិសេសបទល្មើសថ្មី ដែលបង្កដោយជនបរទេស។

៣.បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេតប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស។

៤.បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន។

៥.ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។
៦.ពង្រឹង និងជម្រុញការងាររបាយការណ៍ និងការចងក្រងទិន្នន័យ។

**ឃ. ការងារការពារជនរងគ្រោះ**

១.ជំរុញប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ ជាពិសេស ពលករដែលមិនមានឯកសារស្របច្បាប់ នៅក្នុងវដ្តនៃទេសន្តរប្រវេសន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ និងវិធានការសម្រាប់ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ និងការផ្តល់សេវាឱ្យបានសមស្រប ។

២.បន្តពង្រឹងយន្តការសម្រាប់ការទទួលពលករ ការគ្រប់គ្រង និងដំណើរការមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង ដោយមានកិច្ចសហការពីបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូក្នុងការផ្តល់សេវា។

៣.រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ ក្នុងទេសន្តរប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន។

៤.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តរៀបចំវគ្គបណ្តុះបណ្តាលៈ
- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- គោលការណ៍ណែនាំ ស្តីពី «បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដល់មន្ត្រីជួរមុខ។

៥.ធ្វើបច្ចុប្បន្នភាពលើនីតិវិធីប្រតិបត្តិបទដ្ឋាន(SOPs) ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

៦. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បន្តកិច្ចសហប្រតិបត្តិការជាមួយៈ
- ក្រសួងសុខាភិបាល ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទទួលបានសេវាពិនិត្យសុខភាព និងការព្យាបាលសង្គ្រោះបន្ទាន់ដោយឥតគិតថ្លៃ នៅតាមមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។
- ស្ថានទូត និងកុងស៊ុល នៅក្រៅប្រទេស(តាមរយៈក្រសួងការបរទេស) ដើម្បីជួយដល់ជនរងគ្រោះ និងសម្រួលដល់ដំណើរការមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាឱ្យបានឆាប់រហ័ស និងមានសុវត្ថិភាព។
- ក្រសួងស្ថាប័ន និងអង្គការដៃគូ ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៧.បន្តចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៨.ធ្វើបច្ចុប្បន្នភាពសៀវភៅ គោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

៩.ពិនិត្យលទ្ធភាព ដើម្បីបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះជារបស់រដ្ឋ។

១០.គាំទ្រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនៅ ក្នុងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសគោលដៅ អំពីគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

១១.រៀបចំឧបករណ៍វាយតម្លៃអំពីភាពប្រឈមនៃមេរៀន ស្តីពី«ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ក្នុងខេត្តដែលបានបណ្តុះបណ្តាលរួចហើយ។

១២.រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍។

## ខ. ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ

១.ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន ការងាររបាយការណ៍ ការកសាងផែនការ និងការងារត្រួតពិនិត្យ វាយតម្លៃ។

២.បន្តធ្វើការប៉ាន់ប្រមាណ និងវាយតម្លៃពាក់កណ្តាលអាណត្តិ ទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំយន្តការប្រមូលទិន្នន័យថ្នាក់ជាតិ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសទិន្នន័យនៃការអនុវត្តច្បាប់ ការផ្តន្ទាទោស និងការងារការពារជនរងគ្រោះឱ្យមានសង្គតិភាព។

៤.គាំទ្រពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រង គ្រប់ផ្នែក ដល់មន្ត្រីជំនាញក្នុងក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត ដើម្បីពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥.បន្តធ្វើសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត។

៦.រៀបចំប្រព័ន្ធប្រមូល ចងក្រង និងចែកចាយទិន្នន័យ តាមផ្នែកពាក់ព័ន្ធសំខាន់ៗ។

ថ្ងៃ ច័ន្ទ ១៤ កើត ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ(១) បញ្ជាបល្មើស និងសង្ខេបជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ (ប្រចាំឆ្នាំ ២០២២)

| ល.រ | ប្រភេទបទល្មើស | មាត្រា | ករណី | ជនល្មើស | | | | | | ជនរងគ្រោះ | | | | | | | | នីតិវិធី | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | រូប | ស | អនីតិជន | | បរទេស | | សរុប | | ក្រោម១៥ឆ្នាំ | | ១៥-១៧ឆ្នាំ | | ១៨ឆ្នាំឡើង | | សង្គមកិច្ច | | គ្រួសារ | |
| | | | | | | រូប | ស | រូប | ស | រូប | ស | រូប | ស | រូប | ស | រូប | ស | រូប | ស | រូប | ស |
| 2 | ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១០ | 2 | 2 | 1 | 0 | 0 | 0 | 0 | 2 | 2 | 1 | 1 | 1 | 1 | 0 | 0 | 0 | 0 | 2 | 2 |
| 3 | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | 13 | 17 | 2 | 0 | 0 | 1 | 0 | 76 | 32 | 7 | 1 | 41 | 18 | 28 | 13 | 29 | 13 | 47 | 19 |
| 4 | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ១២ | 1 | 1 | 0 | 0 | 0 | 1 | 0 | 1 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 1 | 0 |
| 5 | អំពើលក់ដូរមនុស្ស | ១៤ | 7 | 17 | 0 | 0 | 0 | 17 | 0 | 15 | 1 | 0 | 0 | 15 | 1 | 0 | 0 | 0 | 0 | 15 | 1 |
| 6 | អំពើលក់ដូរមនុស្សដោយមានគោលដៅ | ១៥ | 3 | 5 | 0 | 0 | 0 | 3 | 0 | 11 | 4 | 1 | 1 | 8 | 3 | 2 | 0 | 0 | 0 | 11 | 4 |
| 7 | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១៦ | 1 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 8 | ការដឹកជញ្ជូនដោយមានគោលដៅ | ១៧ | 1 | 1 | 0 | 0 | 0 | 0 | 0 | 12 | 6 | 0 | 0 | 12 | 6 | 0 | 0 | 0 | 0 | 12 | 6 |
| 11 | ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ២០ | 3 | 3 | 0 | 0 | 0 | 0 | 0 | 9 | 5 | 4 | 3 | 5 | 2 | 0 | 0 | 0 | 0 | 9 | 5 |
| 12 | ការទិញពេស្យាចារកុមារ | ៣៤ | 4 | 5 | 1 | 1 | 0 | 1 | 0 | 5 | 5 | 5 | 5 | 0 | 0 | 0 | 0 | 1 | 1 | 4 | 4 |
| 13 | អំពើអូសទាញពេស្យាចារកុមារ | ៣៥ | 1 | 1 | 1 | 0 | 0 | 0 | 0 | 2 | 2 | 2 | 2 | 0 | 0 | 0 | 0 | 2 | 2 | 0 | 0 |
| **សរុបជួញដូរមនុស្ស** | | | 36 | 53 | 6 | 1 | 0 | 23 | 0 | 133 | 57 | 20 | 13 | 83 | 31 | 30 | 13 | 32 | 16 | 101 | 41 |
| 4 | សញ្ញារកម្មមានអនីតិជន | ២៦ | 1 | 3 | 3 | 4 | 0 | 0 | 0 | 7 | 7 | 4 | 4 | 3 | 3 | 0 | 0 | 0 | 0 | 7 | 7 |
| 5 | សញ្ញារកម្ម | ២៦ | 2 | 3 | 3 | 0 | 0 | 0 | 0 | 10 | 10 | 1 | 1 | 6 | 6 | 3 | 3 | 3 | 3 | 7 | 7 |
| 6 | ស្ថានទម្ងន់ទោសនៃសញ្ញារកម្ម | ២៧ | 7 | 12 | 5 | 0 | 0 | 6 | 2 | 47 | 40 | 4 | 4 | 37 | 30 | 6 | 6 | 16 | 16 | 31 | 24 |
| 7 | សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២៨ | 8 | 12 | 8 | 0 | 0 | 0 | 0 | 39 | 38 | 21 | 21 | 18 | 17 | 0 | 0 | 29 | 28 | 10 | 10 |
| 13 | រូបភាព និងសម្ភារៈអាសអាភាស | ៣៩ | 4 | 4 | 1 | 0 | 0 | 1 | 0 | 4 | 4 | 1 | 1 | 3 | 3 | 0 | 0 | 0 | 0 | 4 | 4 |
| 14 | រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ៤១ | 2 | 2 | 1 | 0 | 0 | 0 | 0 | 1 | 1 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 |
| 15 | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២ | 77 | 84 | 0 | 15 | 0 | 1 | 0 | 87 | 78 | 86 | 78 | 1 | 0 | 0 | 0 | 0 | 0 | 87 | 78 |
| 16 | អំពើអាសប្រផាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤៣ | 29 | 29 | 0 | 0 | 0 | 2 | 0 | 30 | 30 | 30 | 30 | 0 | 0 | 0 | 0 | 0 | 0 | 30 | 30 |
| **សរុបអាជីវកម្មផ្លូវភេទ** | | | 130 | 149 | 21 | 19 | 0 | 10 | 2 | 225 | 208 | 148 | 140 | 68 | 59 | 9 | 9 | 48 | 47 | 177 | 161 |
| **សរុបរួម** | | | 166 | 202 | 27 | 20 | 0 | 33 | 2 | 358 | 265 | 168 | 153 | 151 | 90 | 39 | 22 | 80 | 63 | 278 | 202 |

**(ឧបសម្ព័ន្ធទី១)** **លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំ ឆ្នាំ២០២២)**

**គិតចាប់ពីថ្ងៃទី ០១-០១-២០២២ ដល់ថ្ងៃទី ៣១-១២-២០២២**

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបរួម | | | | | | | | ជួញដូរមនុស្ស | | | | | | | | អាជីវកម្មផ្លូវភេទ | | | | | | | | បញ្ជូនជនរងគ្រោះទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រតិបត្តិ | ជនល្មើស | | | ជនរងគ្រោះ | | | | ប្រតិបត្តិ | ជនល្មើស | | | ជនរងគ្រោះ | | | | ប្រតិបត្តិ | ជនល្មើស | | | ជនរងគ្រោះ | | | | មជ្ឈមណ្ឌលរដ្ឋ | អង្គការ | គ្រួសារ |
| | | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | រួម | ស្រី | បរទេស | រួម | -15 | 15-17 | 18+ | | | |
| 1 | បន្ទាយមានជ័យ | 7 | 9 | | | 30 | 8 | 1 | 21 | 3 | 5 | | | 26 | 4 | 1 | 21 | 4 | 4 | | | 4 | 4 | | | | | 30 |
| 2 | បាត់ដំបង | 23 | 26 | 1 | | 30 | 20 | | 10 | 5 | 6 | | | 10 | 1 | | 9 | 18 | 20 | 1 | | 20 | 19 | | 1 | | | 30 |
| 3 | កំពង់ចាម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | កំពង់ឆ្នាំង | 1 | 1 | | | 1 | 1 | | | | | | | | | | | 1 | 1 | | | 1 | 1 | | | | | 1 |
| 5 | កំពង់ស្ពឺ | 2 | 5 | 5 | | 14 | 1 | 7 | 6 | | | | | | | | | 2 | 5 | 5 | | 14 | 1 | 7 | 6 | | | 14 |
| 6 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | កំពត | 1 | 1 | 1 | | | | | | 1 | 1 | 1 | | | | | | | | | | | | | | | | |
| 8 | កណ្ដាល | 10 | 11 | | 1 | 11 | 9 | 2 | | 1 | 2 | | 1 | 2 | 1 | 1 | | 9 | 9 | | | 9 | 8 | 1 | | | | 11 |
| 9 | កោះកុង | 2 | 2 | | | 2 | 2 | | | | | | | | | | | 2 | 2 | | | 2 | 2 | | | | | 2 |
| 10 | ក្រចេះ | 1 | 1 | | | 1 | 1 | | | | | | | | | | | 1 | 1 | | | 1 | 1 | | | | | 1 |
| 11 | មណ្ឌលគិរី | 2 | 3 | | | 3 | 3 | | | 1 | 1 | | | 1 | 1 | | | 1 | 2 | | | 2 | 2 | | | | | 3 |
| 12 | ភ្នំពេញ | 25 | 28 | 2 | 3 | 36 | 20 | 5 | 11 | 1 | 1 | | 1 | 1 | | | 1 | 24 | 27 | 2 | 2 | 35 | 20 | 5 | 10 | 14 | | 22 |
| 13 | ព្រះវិហារ | 5 | 5 | | | 5 | 5 | | | | | | | | | | | 5 | 5 | | | 5 | 5 | | | | | 5 |
| 14 | ព្រៃវែង | 5 | 6 | | | 6 | 5 | | 1 | 1 | 2 | | | 2 | 1 | | 1 | 4 | 4 | | | 4 | 4 | | | | | 6 |
| 15 | ពោធិ៍សាត់ | 3 | 3 | 1 | 1 | 4 | 2 | | 2 | 1 | 1 | | 1 | 2 | | | 2 | 2 | 2 | 1 | | 2 | 2 | | | | | 4 |
| 16 | រតនគិរី | 4 | 4 | | | 4 | 4 | | | | | | | | | | | 4 | 4 | | | 4 | 4 | | | | | 4 |
| 17 | សៀមរាប | 8 | 10 | 2 | 1 | 43 | 11 | 9 | 23 | 2 | 2 | | | 13 | | 1 | 12 | 6 | 8 | 2 | 1 | 30 | 11 | 8 | 11 | 16 | | 27 |
| 18 | ព្រះសីហនុ | 16 | 27 | 1 | 19 | 35 | 10 | | 25 | 5 | 14 | | 14 | 15 | | | 15 | 11 | 13 | 1 | 5 | 20 | 10 | | 10 | | | 35 |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 2 | 3 | | 3 | 6 | | | 6 | 2 | 3 | | 3 | 6 | | | 6 | | | | | | | | | | | 6 |
| 21 | តាកែវ | 3 | 3 | | | 3 | 3 | | | 1 | 1 | | | 1 | 1 | | | 2 | 2 | | | 2 | 2 | | | | | 3 |
| 22 | ឧត្ដរមានជ័យ | 6 | 6 | 1 | 1 | 6 | 4 | | 2 | 2 | 2 | 1 | 1 | 2 | | | 2 | 4 | 4 | | | 4 | 4 | | | | | 6 |
| 23 | កែប | 2 | 2 | | | 2 | 2 | | | | | | | | | | | 2 | 2 | | | 2 | 2 | | | | | 2 |
| 24 | ប៉ៃលិន | 6 | 7 | 1 | | 10 | 7 | 3 | | | | | | | | | | 6 | 7 | 1 | | 10 | 7 | 3 | | | | 10 |
| 25 | នាយកដ្ឋាន | 14 | 17 | 11 | | 55 | 6 | 7 | 42 | 6 | 7 | 4 | | 33 | 4 | | 29 | 8 | 10 | 7 | | 22 | 2 | 7 | 13 | 50 | | 5 |
| 26 | កងរាជអាវុធហត្ថ | 13 | 16 | 1 | 4 | 45 | 8 | 3 | 34 | 4 | 5 | | 2 | 19 | 1 | 3 | 15 | 9 | 11 | 1 | 2 | 26 | 7 | | 19 | | | 45 |
| 27 | ត្បូងឃ្មុំ | 5 | 6 | | | 6 | 6 | | | | | | | | | | | 5 | 6 | | | 6 | 6 | | | | | 6 |
| | **សរុបរួម** | 166 | 202 | 27 | 33 | 358 | 138 | 37 | 183 | 36 | 53 | 6 | 23 | 133 | 14 | 6 | 113 | 130 | 149 | 21 | 10 | 225 | 124 | 31 | 70 | 80 | | 278 |

**(ឧបសម្ព័ន្ធទី១)** **លទ្ធផលបង្ក្រាបបទល្មើស ជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំ ឆ្នាំ២០២២)**
**គិតចាប់ពីថ្ងៃទី ០១-០១-២០២២ ដល់ថ្ងៃទី ៣១-១២-២០២២**

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបសរុប | | | | | | | | មាត្រា៩ ការនាំយកអនីតិជន ជាអាទិ៍ចេញដោយមិនស្របច្បាប់ | | | | | | មាត្រា១០ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | | | | | | មាត្រា១១ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | | | | | | មាត្រា១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | | | | | | មាត្រា១៤ អំពើលក់ដូរមនុស្ស | | | | | | មាត្រា១៥ អំពើលក់ដូរមនុស្សដោយមានគោលដៅ | | | | | | មាត្រា១៦ អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | | | | | | មាត្រា១៧ ការដឹកជញ្ជូនដោយមានគោលដៅ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បង្ក្រាប | ជនរងគ្រោះ សរុប | -15 | 15-17 | 18 | ជនល្មើស សរុប | ប | ស | បង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បង្ក្រាប | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស |
| 1 | បន្ទាយមានជ័យ | 3 | 26 | 4 | 1 | 21 | 5 | 5 | | | | | | | | | | | | | | 3 | 4 | 1 | 21 | 5 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | បាត់ដំបង | 5 | 10 | 1 | | 9 | 6 | 6 | | | | | | | | | | | | | | 3 | | | 6 | 4 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 3 | កំពង់ចាម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | កំពត | 1 | | | | | 1 | | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | | | | | 1 | | | | | | |
| 8 | កណ្ដាល | 1 | 2 | 1 | 1 | | 2 | 2 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 9 | កោះកុង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | 1 | 1 | 1 | | | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 12 | ភ្នំពេញ | 1 | 1 | | | 1 | 1 | 1 | | | | | | | | | | | | | | | | | | | | 1 | | | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | 1 | 2 | 1 | | 1 | 2 | 2 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | 2 | | | | | | | | | | | | | |
| 15 | ពោធិ៍សាត់ | 1 | 2 | | | 2 | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | | | 2 | 1 | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | 2 | 13 | | 1 | 12 | 2 | 2 | | | | | | | | 1 | | 1 | | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | | | 12 | 1 | |
| 18 | ព្រះសីហនុ | 5 | 15 | | | 15 | 14 | 14 | | | | | | | | | | | | | | | | | | | | | | | | | | 4 | | | 8 | 12 | | 1 | | | 7 | 2 | | | | | | | | | | | | | |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 2 | 6 | | | 6 | 3 | 3 | | | | | | | | | | | | | | | | | | | | | | | | | | 2 | | | 6 | 3 | | | | | | | | | | | | | | | | | | | |
| 21 | តាកែវ | 1 | 1 | 1 | | | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 22 | ឧត្ដរមានជ័យ | 2 | 2 | | | 2 | 2 | 1 | 1 | | | | | | | | | | | | | 2 | | | 2 | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 23 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | 6 | 33 | 4 | | 29 | 7 | 3 | 4 | | | | | | | 1 | | | 1 | | 1 | 3 | 1 | | 28 | 3 | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 26 | កងរាជអាវុធហត្ថ | 4 | 19 | 1 | 3 | 15 | 5 | 5 | | | | | | | | | | | | | | 2 | | 1 | 12 | 2 | | | | | | | | 1 | | | 1 | 2 | | | | | | | | | | | | | | | | | | | |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **សរុបរួម** | | 36 | 133 | 14 | 6 | 113 | 53 | 47 | 6 | | | | | | | 2 | | 1 | 1 | 1 | 1 | 13 | 5 | 2 | 69 | 15 | 2 | 1 | | | 1 | 1 | | 7 | | | 15 | 17 | | 3 | 1 | | 10 | 5 | | 1 | | | | | 1 | 1 | | | 12 | 1 | |

## (ឧបសម្ព័ន្ធទី១) លទ្ធផលបង្ក្រាបបទល្មើស ជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំ ឆ្នាំ២០២២)
### គិតចាប់ពីថ្ងៃទី ០១-០១-២០២២ ដល់ថ្ងៃទី ៣១-១២-២០២២

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | មាត្រា១៨ អំពើនាំឆ្លងដែន | | | | | | មាត្រា១៩ ការទទួលយកមនុស្សដោយមានគោលដៅ | | | | | | មាត្រា២០ ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បណ្តឹង | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បណ្តឹង | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បណ្តឹង | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស |
| 1 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | |
| 2 | បាត់ដំបង | | | | | | | | | | | | | 2 | 1 | | 3 | 2 | |
| 3 | កំពង់ចាម | | | | | | | | | | | | | | | | | | |
| 4 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | | | | | | | | | | | | | | | | | | |
| 7 | កំពត | | | | | | | | | | | | | | | | | | |
| 8 | កណ្តាល | | | | | | | | | | | | | | | | | | |
| 9 | កោះកុង | | | | | | | | | | | | | | | | | | |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | |
| 12 | ភ្នំពេញ | | | | | | | | | | | | | | | | | | |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | | | | | | | | | | | | | | | | | | |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | | | | | | | | | | | | | | | | | | |
| 18 | ព្រះសីហនុ | | | | | | | | | | | | | | | | | | |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | |
| 21 | តាកែវ | | | | | | | | | | | | | | | | | | |
| 22 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | |
| 23 | កែប | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | | | | | | | | | | | | | | | | | | |
| 26 | កងរាជអាវុធហត្ថ | | | | | | | | | | | | | 1 | 1 | 2 | 2 | 1 | |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | |
| | **សរុបរួម** | | | | | | | | | | | | | 3 | 2 | 2 | 5 | 3 | |

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | មាត្រា៣៤ ការទិញពេស្យាចារកុមារ | | | | | | មាត្រា៣៥ អំពើអូសទាញពេស្យាចារកុមារ | | | | | | មាត្រា៣៦ ការអោយខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បណ្តឹង | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បណ្តឹង | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បណ្តឹង | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស |
| 1 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | |
| 2 | បាត់ដំបង | | | | | | | | | | | | | | | | | | |
| 3 | កំពង់ចាម | | | | | | | | | | | | | | | | | | |
| 4 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | | | | | | | | | | | | | | | | | | |
| 7 | កំពត | | | | | | | | | | | | | | | | | | |
| 8 | កណ្តាល | 1 | 1 | 1 | | 2 | | | | | | | | | | | | | |
| 9 | កោះកុង | | | | | | | | | | | | | | | | | | |
| 10 | ក្រចេះ | | | | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | 1 | 1 | | | 1 | | | | | | | | | | | | | |
| 12 | ភ្នំពេញ | | | | | | | | | | | | | | | | | | |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | | | | | | | | | | | | | | | | | | |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | |
| 16 | រតនគិរី | | | | | | | | | | | | | | | | | | |
| 17 | សៀមរាប | | | | | | | | | | | | | | | | | | |
| 18 | ព្រះសីហនុ | | | | | | | | | | | | | | | | | | |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | |
| 21 | តាកែវ | 1 | 1 | | | 1 | | | | | | | | | | | | | |
| 22 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | |
| 23 | កែប | | | | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | 1 | 1 | | | | 1 | 1 | 2 | | | | 1 | | | | | | |
| 26 | កងរាជអាវុធហត្ថ | | | | | | | | | | | | | | | | | | |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | |
| | **សរុបរួម** | 4 | 4 | 1 | | 4 | 1 | 1 | 2 | | | | 1 | | | | | | |

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | មាត្រា៣៧ កិច្ចសន្យានៃអំពើពេស្យាចារកុមារ | | | | | | មាត្រា៤៥ កិច្ចសន្យាសំរាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | | | | | | ជនរងគ្រោះ បញ្ជូនទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បណ្តឹង | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | បណ្តឹង | ជនរងគ្រោះ -15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18+ | ជនល្មើស ប | ជនល្មើស ស | ម.ស.អង្គភាព | អង្គការ | គ្រួសារ |
| 1 | បន្ទាយមានជ័យ | | | | | | | | | | | | | | | 26 |
| 2 | បាត់ដំបង | | | | | | | | | | | | | | | 10 |
| 3 | កំពង់ចាម | | | | | | | | | | | | | | | |
| 4 | កំពង់ឆ្នាំង | | | | | | | | | | | | | | | |
| 5 | កំពង់ស្ពឺ | | | | | | | | | | | | | | | |
| 6 | កំពង់ធំ | | | | | | | | | | | | | | | |
| 7 | កំពត | | | | | | | | | | | | | | | |
| 8 | កណ្តាល | | | | | | | | | | | | | | | 2 |
| 9 | កោះកុង | | | | | | | | | | | | | | | |
| 10 | ក្រចេះ | | | | | | | | | | | | | | | |
| 11 | មណ្ឌលគិរី | | | | | | | | | | | | | | | 1 |
| 12 | ភ្នំពេញ | | | | | | | | | | | | | | | 1 |
| 13 | ព្រះវិហារ | | | | | | | | | | | | | | | |
| 14 | ព្រៃវែង | | | | | | | | | | | | | | | 2 |
| 15 | ពោធិ៍សាត់ | | | | | | | | | | | | | | | 2 |
| 16 | រតនគិរី | | | | | | | | | | | | | | | |
| 17 | សៀមរាប | | | | | | | | | | | | | | | 13 |
| 18 | ព្រះសីហនុ | | | | | | | | | | | | | | | 15 |
| 19 | ស្ទឹងត្រែង | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | 6 |
| 21 | តាកែវ | | | | | | | | | | | | | | | 1 |
| 22 | ឧត្តរមានជ័យ | | | | | | | | | | | | | | | 2 |
| 23 | កែប | | | | | | | | | | | | | | | |
| 24 | ប៉ៃលិន | | | | | | | | | | | | | | | |
| 25 | នាយកដ្ឋាន | | | | | | | | | | | | | 32 | | 1 |
| 26 | កងរាជអាវុធហត្ថ | | | | | | | | | | | | | | | 19 |
| 27 | ត្បូងឃ្មុំ | | | | | | | | | | | | | | | |
| | **សរុបរួម** | | | | | | | | | | | | | 32 | | 101 |

(ឧបសម្ព័ន្ធទី១)

## លទ្ធផលបង្ក្រាបបទល្មើស អាជីវកម្មផ្លូវភេទ ទូទាំងប្រទេស (ប្រចាំ ឆ្នាំ២០២២)
## គិតចាប់ពីថ្ងៃទី ០១-០១-២០២២ ដល់ថ្ងៃទី ៣១-១២-២០២២

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | បង្ក្រាបសរុប | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | បណ្ដឹង | ជនរងគ្រោះ | | | | ជនល្មើស | | |
| | | | សរុប | -15 | 15-17 | 18 | សរុប | ប | ស |
| 1 | បន្ទាយមានជ័យ | 4 | 4 | 4 | | | 4 | 4 | |
| 2 | បាត់ដំបង | 18 | 20 | 19 | | 1 | 20 | 19 | 1 |
| 3 | កំពង់ចាម | | | | | | | | |
| 4 | កំពង់ឆ្នាំង | 1 | 1 | 1 | | | 1 | 1 | |
| 5 | កំពង់ស្ពឺ | 2 | 14 | 1 | 7 | 6 | 5 | | 5 |
| 6 | កំពង់ធំ | | | | | | | | |
| 7 | កំពត | | | | | | | | |
| 8 | កណ្ដាល | 9 | 9 | 8 | 1 | | 9 | 9 | |
| 9 | កោះកុង | 2 | 2 | 2 | | | 2 | 2 | |
| 10 | ក្រចេះ | 1 | 1 | 1 | | | 1 | 1 | |
| 11 | មណ្ឌលគិរី | 1 | 2 | 2 | | | 2 | 2 | |
| 12 | ភ្នំពេញ | 24 | 35 | 20 | 5 | 10 | 27 | 25 | 2 |
| 13 | ព្រះវិហារ | 5 | 5 | 5 | | | 5 | 5 | |
| 14 | ព្រៃវែង | 4 | 4 | 4 | | | 4 | 4 | |
| 15 | ពោធិ៍សាត់ | 2 | 2 | 2 | | | 2 | 1 | 1 |
| 16 | រតនគិរី | 4 | 4 | 4 | | | 4 | 4 | |
| 17 | សៀមរាប | 6 | 30 | 11 | 8 | 11 | 8 | 6 | 2 |
| 18 | ព្រះសីហនុ | 11 | 20 | 10 | | 10 | 13 | 12 | 1 |
| 19 | ស្ទឹងត្រែង | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | |
| 21 | តាកែវ | 2 | 2 | 2 | | | 2 | 2 | |
| 22 | ឧត្តរមានជ័យ | 4 | 4 | 4 | | | 4 | 4 | |
| 23 | កែប | 2 | 2 | 2 | | | 2 | 2 | |
| 24 | ប៉ៃលិន | 6 | 10 | 7 | 3 | | 7 | 6 | 1 |
| 25 | នាយកដ្ឋាន | 8 | 22 | 2 | 7 | 13 | 10 | 3 | 7 |
| 26 | កងរាជអាវុធហត្ថ | 9 | 26 | 7 | | 19 | 11 | 10 | 1 |
| 27 | ត្បូងឃ្មុំ | 5 | 6 | 6 | | | 6 | 6 | |
| | សរុបរួម | 130 | 225 | 124 | 31 | 70 | 149 | 128 | 21 |

| ល.រ | នាយកដ្ឋាន រាជធានី-ខេត្ត | មាត្រា២១ ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | | | | | | មាត្រា២២ ស្ថានទម្ងន់ទោស (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | | | | | | មាត្រា២៤ អំពើអូសទាញសញ្ជារកម្ម | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បណ្ដឹង | ជនរងគ្រោះ | | | ជនល្មើស | | បណ្ដឹង | ជនរងគ្រោះ | | | ជនល្មើស | | បណ្ដឹង | ជនរងគ្រោះ | | | ជនល្មើស | |
